ជិតវត្តនាទ្វីថ្ងៃ ប្តូអាកាសបួលទៅដល់ខាងកន្លងដំបៅវិញ ទើបមេពេត
កើតឡើងយ៉ាងរហ័ស ប្រសិនបើមុខដំបៅធំប្តូបានលាងសំអាតល្អហើយ
មេពេតនេះក៏ស្ងាប់អស់ទៅជាមិនខាន ។ មេដម្លឹគ្រុនញាក់ ជាមេពេត
មានជីវិតរស់នៅបានតែក្នុងក្រពះមួស ១ ពួក បើមិនមានមួសចំពូកនេះ
ប្តូបើយើងមិនត្រូវមួសចំពូកនេះទាំងទេ យើងក៏មិនកើតពេតគ្រុនញាក់
នេះសោះឡើយ ។ ក្រៅពីពេតដែលបានចេញឈ្មោះមកនេះ នៅ
មានពេតដទៃទៀតជាច្រើន ហើយឲ្យគោសតិចច្រើនតាមទំនងដែល
គោលមកនេះ ។ មានសេចក្តីសំខាន់មួយយ៉ាងទៀត គឺថាយើងអាច

ងារពោរពេតអស់នេះបាន ។ បើយើងយកចិត្តទុកដាក់រឿងចំណេះចង្អាវ
ពេកទុកខ្លះ ។ កាលបើដឹងថា វេលានេះជួរនេះកំពុងមានពេតធ្ងន
ចំពួកនេះ តាមទំនៀមតាមច់ណីអាហារ យើងត្រូវតែប្រយ័ត្នរក្សាសំអាត
របស់អស់នេះឲ្យហ្មត់ចត់ ទំពាំងស្ងួចស្ងាត់ជាតំពៅវិញ ។ យើងដឹង
ថា មុខរបួសដំបៅជាទ្វារចូលនៃមេពេត យើងត្រូវតែរក្សាសំអាតមុខ
របួសដំបៅទំពាំងតែជាស្រេចទេ ។ ប្រសិនបើចេះវិធីបង្ការនូវការរក្សា
ជាក់ច្បាស់ហើយ យើងមិនចាប់មានសេចក្តីព្រួយបារម្ភឡើយ ។
យើងគួររក្សាការសំអាតជួនក្បែរបស់យើងឲ្យល្អ ដើម្បីឲ្យបាន
សុខកាយសុខចិត្ត តែកុំបង់រង្គើការសំអាតខ្លួនឯង ដើម្បីជ្រាសចាត
បុលខ្នើយ ប្រយោលនូវការសំអាតក្បែរនេះទៀតកុំប្រព្រឹត្តដល់ពៅត្រូវ
តែចរិកោតអាហារឆ្អិនក្តៅគ្រប់មុខគ្រប់ប្រការពេក កុំប្រយ័ត្នដល់មិន
ព្រមផឹកទឹកក្តៅទឹកត្រជាក់ ។ កុំប្រយ័ត្នដល់មិនព្រមចំពាល់គ្រឿង
ស្មោកគ្រោកមិនឲ្យប្រឡាក់ខ្លួនសោះឡើយ ហើយកុំប្រយ័ត្នតាំលែង
ឃើញអ្នកដទៃមានសេចក្តីរង្កៀសដល់គេ ដែលគេមិនបានសំអាតស្ទើនឯង
ខ្លួន ។ ប្រសិនបើយើងប្រតិបត្តិដល់ថ្នាក់នេះ មុខជាជីវិតយើងមិនបាន
កបសាស្រួលឡើយ ហើយចួនជាប៉ះពាល់នឹងមេជម្ងឺ មុខជាកើតទៅស
ដល់ពន់កាយជាភ្លាំងមិនខាន ។ ក្នុងលោកនេះ មិនមានអ្នកណាមួយ
ចៀសវាងពីបុលខ្នើយផ្សេង ។ បានឡើយ ។ ការដែលយើងត្រូវប្រយ័ត្ន
ដល់ថ្នាក់នេះ លុះតែមានហេតុកេរខ្មុសពីប្រក្រតីកើតឡើងប៉ុណ្ណោះ ។

ម្ដុនទឹងបញ្ចប់គ្គនេះ លោកអ្នកតែងបានសុំឲ្យអស់លោកអ្នកមើលសេចក្ដីនេះ ដោយមានពិចារណាមើលពាក្យ របស់អ្នកស្រែចំការរបស់យើងចុះ ជនពួកនេះ នៅឆ្ងាយពីតំបន់ដែលមានសេចក្ដីចំរើនទុងរឿង ដែលមានលុយច្រើនច្រាសទាន់ប្រសព្វ អ្នកស្រែចំការអស់នោះ មិនសូវមានឧបាសាមានកាន់ក្រែង ល្មមឲ្យជាទីស្និទ្ធស្នាលនឹងអ្នកក្រងឹងឹតេ ទើបពួកអ្នកក្រងជារឿន សំឡឹងយើញបងប្អូនពួកនេះថោកទាបស្មោកគ្រោក មិនស៊ីវិលើយដូចខ្លួន ។ តែតាមដោយសេចក្ដីពិតជនចំពួកនេះ ចាន់រស់នៅរួមនឹងធម្មជាតិ គ្រាន់តែមានទូមប្ដូរសំពាប់ជួកក្ងៀងនឹងកំដៅ នឹងការស្រយាដេត ចិញ្ចឹមជីវិតដោយការងារដែលត្រូវប្រឹងឡាំងការយកគ្រាមកំដៅថ្ងៃនឹងក្ងៀងលើងឲ្យខ្លួនច្រណែប-ឡាក់ច្រឡូសដោយធូលីការចម៍ដី នឹងកក់ល្បាប់ផ្សែង។ បើទុកជាមានការសំអាតខ្លះ ក៏ចំពោះការដើរមើលបុណ្យឬដើរលេងកំសាន្ត ឬពេលចូលដំណេកប៉ុណ្ណោះ ឯទឹងប្រើកន្ធរ, ពែក ច្រឡាយសោតទៀត ក៏ច្រើនតែល្អក់តក។ ទឹងនេះហើយសម្រាប់ជម្រះលាងកាយរបស់គេ គ្រាឃ្វានក៏ប៉ះពាល គ្រាឈឺរាំងបត់ដើងក៏ទៅបត់ដើងភ្លាមមិនបង្អង់ រីលោទំនេរពីការងារ ក៏សប្បាយហ៊ឺហាទៅចូលលេងកំសាន្តទៅ ដល់ពេលត្រលប់ក៏នាំគ្នាចូលដំណេក មិនដើរលេងយប់មើលកុនល្ខោនឲ្យអត់ងងុយដូចអ្នកក្រងទេ ហើយមិនសូវតែឆ្លៀតកងការប្រែតំនិតប៉ុន្មានឡើយ ។

ពួកអ្នកជនបទអស់នេះយើងនឹងឃើញថា តែមានទឹកមុខនឹងសាច់ឡៅ
ក្រៃមែនឯណា តំណៅថ្ងៃនឹងខ្យល់ មានដៃតគ្រាតរឹងមិនខន់ភ្លន់-សាច់មិន
ជ្រាយដូចអ្នកក្រុងទេ ទើបយើងឃើញថា ពួកអ្នកជនបទអស់នោះ
មានទឹកមុខនឹងសាច់ឈាមមិនដាច់ស្រួចហាសោះឡើយ តែជនពួកនេះ
ជាអ្នកប្រតិបត្តិតាមសេចក្តីត្រូវការរបស់ធម្មជាតិយ៉ាងម៉ឺងម៉ាត់ ទើបមិន
សូវមានជម្ងឺដំកាត់ច្រើនពេក ដូចពួកជនដែលច្រេះច្រែតច្រវែងគ្នា
ខោ ។ ទុតជាអ្នកជនបទខេត្តក្រៃ មានកំឡាំងកាយរឹងប៉ឹងម៉ាំមួន
ហើយមានសេចក្តីអត់ធន់ច្រើនជាងពួកអ្នកក្រុងគំរាមមែន តែនៅមាន
ការខ្វះខាតហេតុ ២ ប្រការទៀត ដែលជាចង្កួយនាំឲ្យបានសុខកាយ
សុខចិត្តនឹងអាយុយឺន គឺប្រការទី ១ អាហារ សេចក្តីពាល់ត្រូវនឹងការ
មិនបេះបោរបំសុខកិច្ចល នាំឲ្យជនពួកនេះបានចរិកោងអាហារស្រស់ល្អ
ឲ្យល្មមនឹងសេចក្តីត្រូវការរបស់ពងកាយ ។ ប្រការទី ២ គឺពេទ្យវេលា
មានជម្ងឺឈឺចាប់ ជនពួកនេះ មិនសូវមានការព្យាបាលរក្សាត្រឹមត្រូវតាម
វិជ្ជាពេទ្យឡើយ ច្រើនជួបប្រទះតែថ្នាំបែបបុកណា ទំរឹងក្សាដោយមន្តអា-
គមឬអារក្ស អ្នកគាំដែលសះជាចាត់ពេតវៀងបាន ដោយអំណាចពងកាយ
របស់គេ មានកំឡាំងតស៊ូទំនឹងមេរោគយ៉ាងម៉ាំមួន ។ ការប្រែសួតបុត្រ
តាមជនបទខេត្តក្រៃសោតទៀត ក៏មុនត្រូវឲ្យស្ទាប់ស្ទែងអត្តពលណាស់
ដែរ ប៉ុន្តែនៅតុកាសតវៀមុនទៀត វិជ្ជាពេទ្យចំរើនឡើងសាយភាយខ្ជួ

ទៅជាល់ជនបរទេសត្រៃផង ហើយអ្នកស្រែ-ចំការអស់នោះ បេះរំដែមភ្លោះ
ពេតជាយខ្លួនឯងផង ទើបទាំឲ្យកងកាយចេស់គេ ចែកបជាយកំឡាំង
តែកុំឲ្យនឹងអាបុយីនយូរ មានសេចក្តីសុខសប្បាយតាមធម្មជាតនៃសង្ខារ
កងកាយរបស់មនុស្សជាច្រើនជាពុំមាន ។

ចប់

ឃុនសុន្ទរមេធី ញ្ញង-សឿង ប្រែ
លោក ហង់-គឹមសេង ពិនិត្យ

(តទៅ)

តាមខ្ញុំយល់ឃើញ បងត្រូវតែចែកចាយទ្រព្យសម្បត្តិរបស់ខ្លួនដល់កូនស្រីខ្លួន ខ្ញុំថាដូច្នេះ តើមិនសមរំលុយាំងណា ? ។

សូម្បីខ្លួវេទិន-អលី និយាយពាក្យនេះចាំងសើចញញឹមផង ប៉ុន្តែបងនោះជាអ្នកមានចិត្តស្រាលពេក ក៏ត្រឡប់ជាអាក់អន់ចិត្តនឹងប្អូនរបស់ខ្លួន ទើបនិយាយឡើងដោយកំហឹងថា "កូនប្រុសរបស់ឯងមានគ្រោះធំហើយ ព្រោះឯងហ៊ានយកមកផ្ដឹមនឹងកូនស្រីអញ ! អញសំគាល់ឃើញថា ឯងជាមនុស្សព្រៃហើនកែងកាចហ៊ានម៉ាលជាយកូនស្រីអញ គិតឲ្យអញលើកឲ្យទៅកូនប្រុសឯងទេ?, មិនមែនជាយដូចជាសេចក្តីប៉ុនប៉ងរបស់ឯងទេ កុំថាតែត្រឹមប៉ុណ្ណោះ ទោះបីឯងជូនសម្បុងសម្បត្តិឲ្យច្រើនកើនហួសពីឯងមានទៅទៀត ក៏អញមិនខ្វល់ឲ្យដែរ" ។ ការផ្ដែផ្ដួលប្រែឥតគ្នាលេងរវាងបងប្អូនពាំងពីរនាក់ចំពោះអាពាហ៍ពិពាហ៍ នៃកូនប្រុសស្រីរបស់ខ្លួនដែលមិនពាន់ពាំងកើតមកផងនោះ នាំឲ្យមានរឿងជាប់គាំងធ្ងាយទៅទៀត ។ ចំណែកខាងសេមសេខិន ម៉ូហាម្មេ ខេរខិន

រហូតដល់បងគំនុំគុំកួន ហើយក៏និយាយតំកមប្អូនថា "ថ្ងៃស្អែកនេះទាស់តែអញមានកិច្ចរវល់ជួនព្រះរាជដំណើរស្តេចទៅប្រពាតត្រៃទេ កុំអីអញនឹងធ្វើឃាបឯងឲ្យសមតាមឫកម្ពស់មើលប៉ុន្តែមិនអីទេ. ចាំដល់ត្រឡប់មកវិញអញនឹងធ្វើឲ្យឯងដឹងអំពីរឿងដែលប្អូនហ៊ានប្រមាទមើលងាយបង" ។ កាលនិយាយដូច្នេះហើយ បងនោះចូលទៅក្នុងបន្ទប់ខ្លួនបាត់ទៅ, ចំណែកឯប្អូនក៏ទៅដេកក្នុងបន្ទប់គាត់វែរ ។

លុះដល់ថ្ងៃស្អែកឡើងពេលព្រលឹមស្រាង។ សេមសេខ-ឱនម្ចុហម្នេះ ក្រោកឡើងហើយចូលក្នុងព្រះរាជវាំង ចេញទៅជាមួយនឹងព្រះរាជាធ្វើដំណើរតាមផ្លូវគោចរលើគ្រុងកែវ ក្បែរចេតិយអនុស្សាវរីយ៍ដើម្បីប្រពាតត្រៃ ។ ចំណែកខាងខ្លួរេខិន-អលី ដេកសញ្ជប់សញ្ជឹងសន្ធឹងសង្ឃឹមព្រួយប្រាណក្នុងវេលាពត្រីនោះឯង ហើយនឹកពិចារណាសព្វៗទៅឃើញថា នឹងទៅរួមសុខរួមទុក្ខជាមួយនឹងបងឲ្យយូរយារតទៅទៀតពុំបានឡើយ គោងតែគេចចេញទៅឲ្យផុតអំពីទីនេះ ព្រោះតែគាត់អន់រហូតដល់បងគំនុំគុំកួនទៅហើយ, លុះគិតឃើញដូច្នេះហើយទើបរៀបចំអីវ៉ាន់ផ្សេងៗ មានចាំងការុងមាសពេជ្រ នឹងស្បៃឆ្នាងជាដើម ដាក់ផ្ទុកលើខ្នងសេះមួយ ហើយនិយាយផ្តែផ្តាំនឹងប្អាស្រីក្នុងផ្ទះថាខ្លួនត្រូវទៅធ្វើដំណើរទៅខាងក្រៅក្រុងប្រហែលជាពីរ-បីថ្ងៃ រួចហើយក៏ដឹងលាចេញទៅតែម្នាក់ឯង ។

លោកន្ទរេខិន-អលី កាលចេញទៅដល់អាងត្រីក្រុងកែវហើយ
ទើបដឹងលោចរកាត់ផ្លូវធ្វាយដាច់ស្រយាល ត្រូវទៅកាន់ប្រទេសអាព័ប ។
ប៉ុន្តែដោយផ្លូវនោះវែងធ្វាយពេក លាដែលជាភាហនៈនោះគ្មានចំ
ត្រង់តណ្ហាលផ្លូវនោះទៅ, ន្ទរេខិន-អលី ខំត្រាំស្លាយអស់កំនើរទៅ
ដោយដើងមុខគួរឲ្យតំសត់ខ្លួនពន់ពេក ។ ដោយឃើញសំណាងល្អណាស់
មានអ្នកនេះតេសំបុត្រឆ្នាក់មានដំណើរទៅកាន់ក្រុងចាល់សូរ៉ា ជាន
ប្រទេសឱ្យលោកត្រង់ភាក់កណ្តាលផ្លូវ ហើយក៏ឲ្យលោកដំរើតាងត្រីឲ្យ
ធ្វើដំណើរតែពោះទៀត ។ កាលបុរសអ្នកបរនេះនោះបានទៅដល់ក្រុង
ចាល់សូរ៉ាហើយ លោកន្ទរេខិន - អលី ក៏ថ្លែងសេចក្តីអរគុណជា
ខ្លាំងផុត ដោយបានជួយចំឡងលោកអំពីផ្លូវធ្វាយដាច់ស្រយាល រួច
ហើយលោកដើរទៅតាមផ្លូវថ្នល់ដើម្បីស៊ើបសួរកេតុនៃដំណាក់ស្រាប់
តែឃើញមន្ត្រីជាន់ខ្ពស់ម្នាក់ដើរមកដល់ មានទាំងមនុស្សជាច្រើនដើរជូន
ដំណើរតាមក្រោយផង· ហើយពួកមហាជនអ្នកដើរតាមផ្លូវនាំគ្នាឈប់
គំនាប់គាប់គួរយ៉ាងលំអុតលំទន ដកឋដល់មន្ត្រីនោះដើរហួសផុតទៅ ។
ចំណែកខាងលោកន្ទរេខិន-អលី ក៏ឈប់គំនាប់គួរសមដូចជាអ្នកឯទៀត
ដែរ, មន្ត្រីជាន់ខ្ពស់នោះគឺជាអគ្គមហាសេនានៃព្រះពាជាក្រុងចាល់សូរ៉ា,
លោកដើរតួនទៅក្រុងដើម្បីត្រួតត្រាមើលរបៀបរៀបរយ នឹងសេចក្តីសាន្ត
ត្រាណរបស់បណ្តាកស្រុក ។

សេនាបតីនោះ ចោលភ្នែកចំពោះមនុស្សកំឡោះ ឧបវេឌិន-អាលី យើញទម្រង់មុខមាត់ល្អស្រស់ថ្លៃបែបគួរឲ្យពិតពិលរមិលមើល ទើបលោកសំឡឹងហើយសំឡឹងទៀតដោយសេចក្តីពេញចិត្ត ។ អគ្គមហាសេនាដើរចូលទៅជិត យើញសំលៀកបំពាក់ជារបៀបអ្នកដំណើរលោកក៏ឈប់សាកសួរដំណើរដើមទង្គិចគ្នា ។ ឧបវេឌិន-អាលី ជំពាក់តាមត្រង់ថា "សូមជំពាក់ប្រសាសន៍លោក ; ខ្ញុំបាទនាំស្រុកអេស៊ុប្ត, កើតនៅក្នុងកែរ៉ូ, ឯដំណើរដែលខ្ញុំបាទដើរមោលស្រុកតំណើតមកក្នុងទីនេះព្រោះមានសេចក្តីគាក់គន់ចិត្តនឹងម្នាក់ ហេតុដូច្នេះបានជាខ្ញុំបាទរដើរផ្តេសផ្តាសទៅគាន់លោងតាំងមូល ដោយបំណងថាសូមឲ្យស្តាប់ទៅប៉ុះប៊ះរើជាងគាវៀលត្រឡប់ទៅវិញ" ។ លោងអគ្គមហាសេនា ជាមនុស្សចាស់ពុំគួរគោរព កាលបានឮពាក្យនោះហើយ ក៏គោលថា "កូនប្រុសឥតុក, គំនិតរបស់អ្នកថែបនេះមិនត្រូវសោះ ព្រោះក្នុងលោកតាំងមូល មានសុទ្ធតែសេចក្តីទុក្ខលំបាកផ្សេងៗ ចំណែកប្អូនអ្នកមិនដឹងថាសេចក្តីទុក្ខលំបាកនោះ ធំធេងមកប៉ះពាល់ដល់ខ្លួនក្នុងកាលណាទេ, ល្អើយប្អូនអ្នកទៅតាមខ្ញុំឥឡូវនេះចុះ ប្រហែលជាខ្ញុំធ្វើអ្នកឲ្យក្លេចដើមចមដែលនាំចណ្តាលឲ្យអ្នកដើរចោលស្រុកមកនេះ ។

ឧបវេឌិន អាលី ក៏ដើរទៅតាមលោកអគ្គមហាសេនាត្រង់ចាល់ស្តាំរហូតទៅដល់ផ្ទះហើយនៅអស្ចារ្យថាសុទ្ធសប្បាយក្នុងនោះ ; កាល

លោកអគ្គមហាសេនាបានស្គាល់កិរិយាមារយាទសណ្ដាប់ធ្នាប់ដ៏ល្អរបស់
ខ្លួនរួចខ្លួន - អលីហើយ លោកក៏មានសេចក្ដីស្រឡាញ់ពេញចិត្ត ដុកដូច
ជាកូនបង្កើត, កន្លងមកថ្ងៃមួយចេកំពុងជជែកគ្នាលេងតែពីរនាក់ លោក
មានប្រសាសន៍ចំពោះខ្លួនរួចខ្លួន - អលីថា "កូនប្រុសទុកៗ, ខ្លួនយើងនេះ
ដូចអ្នកយើញស្រាប់ គឺចាស់តែចាស់ត្រាំគ្រាណាស់ហើយ, តាមស្ថាន
មើលទៅយើងមិនបានជារស់នៅយូរប្រៃវែងម៉ានទៀតទេ ។ ទេពួកបាន
ដាក់ទានកូនស្រីតែមួយឲ្យយើង, ខ្លាចមានរូបឆោមក៏ល្មមគួរសមហើយ
សព្វថ្ងៃនេះមានអាយុកំពុងពេញការ ពួកនាហ្មឺនសព្វមុខមន្ត្រីធំធំសឹង្ហ-
គហបតីជារាប់រួនគ្នានៅកន្លែងនេះ បានមកនិយាយដណ្ដឹងឲ្យកូនប្រុស
របស់គេអស់កាលជារាប់ជនណាស់ហើយ, ប៉ុន្តែយើងមិនព្រមឲ្យ
សោះ ។ ចំពោះរូបថ្លៃឯងវិញ, យើងមានសេចក្ដីស្រឡាញ់ដោយ
ស្មោះត្រង់ ហើយយល់ឃើញថាគួរនឹងឯងភ្ជាប់ជាញាតិពន្ធទៅវិញទៅ
មក តែយើងយល់ព្រមខ្លួយកឯងធ្វើជាកូនប្រសាបាន, ប្រសិនបើបាយល់ព្រមស្មោះស្ម័គ្រ ដោយសេចក្ដីពេញចិត្តតាមបំណងរបស់
យើងនេះ យើងនឹងបួលទៅគ្រាបខ្លួលព្រះពរជាដើម្បីនឹងរៀបចំធ្វើអាពាហ៍
ពិពាហ៍ ហើយយើងនឹងសូមព្រះពរជានុញ្ញាតឲ្យដែរដើម្បីផ្ទេរហានន្តរ
របស់យើងជាអគ្គមហាសេនាសព្វថ្ងៃនេះទៅឲ្យអ្នកវិញ, យើងនឹង
ឈប់សម្រាកខ្លួនតែបច្ចុប្បន្នវ័យហើយចូរអ្នកជឿជាក់ច្បាស់ជាចុះថា យើង

មិនមែនប្រគល់ឲ្យតែត្រឹមតែព្យុសម្បត្តិក្តៅមិតតែប៉ុណ្ណោះទេ ពោះតាំងតែក្តួតរាជការក្នុងនគរចាំងមូលនេះ ក៏យើងប្រគល់ជាចំមុខឲ្យអ្នកតាន់តាប់ត្រួតត្រាតាំងអស់" ។

លោកអគ្គមហាសេនាក្រុងចាល់សូរ៉ា និយាយពាក្យដ៏ប្រកបដោយសេចក្តីសប្បុរសសន្តោសក្រៃសុំណានេះមិនតាន់តាំងចប់សព្វគ្រប់ផងន្ទរពេលនិង-អលី ក៏លុតជង្គង់ក្រាបក្រុះក្បៀបជើនរបស់លោកដើម្បីសំដែងសេចក្តីគ្រែតអរនឹងសេចក្តីជំនឹងគុណជាអនេក ចំពោះលោកដែលមានចិត្តស្មប្បុរសយ៉ាងនេះឯង ហើយបានទទួលត្រមតាមសេចក្តីដួងផងនោះដោយអំណរយ៉ាងក្រៃលែង ។ គ្រានោះ អគ្គមហាសេនាហៅមេទាហានធំៗដែលនៅប្រចាំសម្រាប់ផ្ទះលោក ឲ្យមកជួបជុំគ្នាហើយបង្គាប់ឲ្យរៀបតាក់តែងចម្ងាំងនៃភោជនាតារ (ផ្ទះស៊ីលៀង) របស់លោង ព្រមទាំងឲ្យចាត់ចែងគ្រឿងភោជនីយាហារនឹងទទួលហារ យ៉ាងដូច្នេះ សម្រាប់ទទួលភ្ញៀវរួចហើយ លោកឲ្យទៅអញ្ជើញអស់ព្រះពជវង្សានុវង្សនាហ្មឺនសព្វមុខមន្ត្រីនឹងពួកសេដ្ឋីគហបតីក្នុងទីក្រុងនោះទាំងអស់ សូមឲ្យអញ្ជើញមកជាមង្គលកងគេហដ្ឋានរបស់លោក ។ កាលដល់កំណត់ពេលវេលា ពួកភ្ញៀវមកជួបជុំគ្នាហើយ, ចំណែកខាងនិង-អលីបានដំកល់បិតាក្មេកឲ្យបានជ្រាបអំពីហានៈរបស់ខ្លួនជាស្រេចដោយប្រការផ្សេងៗ ។ លោកអគ្គមហាសេនាជាបិតាក្មេក ក៏និយាយប្រគាស់ប្រាប់

ដល់អស់លោកដែលបានមកសុំដណ្តឹងកូនស្រីលោកតាលពីជាន់មុន តែលោកច្រែកមិនព្រមឲ្យនោះ ដើម្បីឲ្យគេបានដឹងច្បាស់ ដោយពាក្យលុបលាងដោះសាថាដូច្នេះ «អស់លោកអ្នកចាំន៏ឡាយ, ពេលនេះខ្ញុំសូមដំណាងអស់លោក អ្នកឲ្យបានច្បាស់អំពីការសម្ងាត់មួយដែលខ្ញុំចិត្តចាំន៏លាក់ទុកមកអស់កាលយូរហើយ ដំណាងដល់ថ្ងៃនេះឯង គឺ: ខ្ញុំមានបងប្រុសម្នាក់ធ្លាប់ជាអគ្គមហាសេនានៃព្រះពុទ្ធចៅក្រុងសេតសុីប្តី ដូចជាខ្ញុំដែលមានឋានៈជាអគ្គមហាសេនានៃព្រះពុទ្ធក្នុងប្រទេសយើងនេះដែរ បងខ្ញុំនោះមានតែកូនប្រុសមួយ ហើយគាត់មិនពេញចិត្តឲ្យកូនយកច្រែពន្ធនៅស្រុកសេតសុីប្តីនោះ សោះ គាត់បានបញ្ជូនកូនប្រុសគាត់មកឲ្យខ្ញុំរៀបចំអាពាហ៍ពិពាហ៍ជាមួយនឹងកូនស្រីខ្ញុំ ដើម្បីនឹងថ្លើសាខាចាំន៏ពីរបស់យើងឲ្យបានមូលត្រកូលជាតិស្និទ្ធតទៅទៀត, កូនប្រុសនោះខ្ញុំទើបនឹងបានស្គាល់ដាក់ដាក់ឈ្មោះខ្ញុំកន្លងវេលាដែលវាមកដល់ ហើយខ្ញុំក៏ព្រមទទួលយកធ្វើជាកូនច្រែសាតាមចំណងរបស់បងខ្ញុំ, កូនច្រែសានោះគឺជាខ្លួនកំណើរនេះឯង (លោកចង្អុលបង្ហាញ) ដូចអស់លោក-អ្នកបានឃើញស្រាប់ ។ ខ្ញុំសូមឲ្យអស់លោក-អ្នកអញ្ជើញមកជាមង្គល ក្នុងកិច្ចអាពាហ៍ពិពាហ៍ដែលខ្ញុំបានសម្រេចថានឹងរៀបចំធ្វើក្នុងថ្ងៃនេះ ។ បណ្តាពួកនាហ្មឺនធំ-តូចចាំន៏ឡាយនោះ គឺមានអ្នកណាមួយយល់ឧទ្ធំថាស់ថាដូចម្តេចឡើយ សុទ្ធសឹងតែធ្វើយព្រមគ្នាថាដំណើរដែលលោកគិតគូរៀបចំ អាពាហ៍-

ពិពាហ៍នោះជាការប្រពៃណាស់ហើយ ! អ្នកចាំងអស់គ្នាយល់ព្រមអប
អរសាទរស្មោះស្ម័គ្រមកជាមង្គលតុំហ៊ានខាន ហើយបានចាំងជូនពរសូ
សាធុការសូមឲ្យព្រះជួយចំរុងចំរើនអស់កាលជាអង្វែងតទៅ ដើម្បីនឹង
ចាទបួបប្រែទន្ទេរផលប្រយោជន៍ ដែលលួតលាស់ដុះដាលអំពីការមួល
មិត្រនៃវង្សត្រកូលដ៏សុខក្សេមក្សាន្តនេះឯង ។

ពួកនាហ្នឹងមុខមន្ត្រីធំ - តូចចាំងអស់ដែលបានមកជួបជុំគ្នានៅផ្ទះ
លោកអគ្គមហាសេនាក្រុងបាល់សូរ៉ាំ ក៏មានសេចក្តីរីករាយសប្បាយ
ចំពោះរឿងដែលអគ្គមហាសេនា រៀបចំការកូនស្រីជាមួយនឹងនាងខេមិន.
អាល់; ក្នុងពេលនោះ គេចាប់ដើមលឿងក្បែរតាមទំនៀម, ក្បែរចាំងឡាយ
ក៏នៅស៊ីផឹកក្នុងទីនោះអស់កាលយូរណាស់ លុះចរិះគាត់ឆាន់ឆ្ងាហារ
រួចហើយ ពួកអ្នកបំរើក្បែរបានលើកខាទនីយាហារ (បង្អែម) មានដំណាប់
ផ្សែងៗជាដើមយកមកជូនក្បែរជាកិច្ចបង្ហើយចុងក្រោយតាមទំនៀមស្រុក
ក្បែរម្នាក់ៗតែងវេចខ្ចប់នំបានប៉ុន្មានក៏យកប៉ុណ្ណោះទៅផ្ទះ ។ តពីនោះទៅ
ពួកទៅក្រមការនំសំបុត្រសញ្ញានៃអាពាហ៍ពិពាហ៍ចូលមក ហើយអស់
លោកមន្ត្រីជាន់ខ្ពស់ចាំងឡាយ ក៏ចុះហត្ថលេខាជាសាក្សីជួយដឹងឮផង
រួចហើយក្រុមក្បែរចាំងអស់ជាប់ចលាលោកអគ្គមហាសេនា ថយទៅ
ឆាន់តែហ្នឹងរឿង ។ ។

(មានត)

អ្នកឧកញ៉ាឥស្សរវង្ស សំ-ស៊ុន រៀបរៀង

រឿងអាជ្ញាជីង

(តទៅ ទំព័រ ចប់)

តាជូជកតាត់ក៏ខ្វះខ្វែង ស្រែងរកឲ្យនាងបរិភោគបានត្រប់យ៉ាង ក្រែយមកតាជូជកតាត់ធ្វើទាន់ការបំរើនាងពុំបានដោយគ្រាណាតាត់តាំងតែចាស់កំឡាំងក៏ខ្សោយ ទើបតាត់ទឹកដល់ព្រះបាទស្រីវេស្សន្តរមានព្រះរាជបុត្រាបុត្រី ២ ព្រះអង្គនាំចេញទៅនៅឯកុំតំរីវង្កត ។ បើជាតាត្នាអញទៅសុំយកមកឲ្យបរម្រីនាងអមិត្តតាបែហែលជាបាន ព្រោះលោកកំពុងចំពេញទានបារមី តាជូជកគិតដូច្នេះហើយ ក៏នាំដំចាំតែនាងអមិត្តតាសម្រាលកូនរួចទើបចេញ ឃាត្រាទៅសុំ ព្រះរាជកុមារ មកបរម្រីនាងអមិត្តតា ។

លុះនាងអមិត្តតាមានគតិត្រប់ ១២ ខែក៏សម្រាលកូន (តគិនេះប្លែក?) ។ ឯតាជូជកតាត់ក៏ស្ងាត់កូនការសម្រាលកូន ព្រោះតាត់មានក្តួនខ្លាតព័ទ្ធជុំវិញដោយតាត់ធ្លាប់ធ្វើជាហ្មូ ១ ដែរ កាលសម្រាលចេញតាត់ឃើញជាកេនប្រុស តាត់ក៏ទឹកត្រេកអរណាស់ តាត់ទះដៃហើយលោតខ្ទួនបីជាន ទើបលើតលាងដុសខាត់ស្អាតហើយ តាត់ដាក់ឲ្យដេកក្នុងស្នាបជ្រក ហើយលើកដាក់កន្ទុយសង្កែកព្យួរខ្សែន បង្គាប់កុំឲ្យសត្វឆ្កើចវាយ ព្រោះផ្ទះតាត់

មានសង្កើចកុះកណាស់ លុះកើតបាន ៧ ថ្ងៃ គាជូជកគាត់រៀបពិធី ១ សម្រាប់តាំងឈ្មោះកូនគាត់ៗ យកក្បួនកេទមកបើកមើលឫក្សាពេលឲ្យកូនគាត់រួចគាត់ថាយ៉ាងម្តេចថា កូននេះស៊ីខ្សែផងទៀតហើយ ត្រែះលេខធ្វើយ៉ាងថាអត្តៈ មនជាលាភៈ លាភៈមកជាហ៊ានៈ អាននេះកេស៊ីសុំបានខេត្តជួរជាងធ្វើការឯទៀត តែលាភៈនោះមានអន្តរាយ ដូចជាអញចង់មាស ១០០ តម្លឹងវៅបានឯម៉ែកមក ទើបគាត់ឲ្យឈ្មោះកូននោះថាគាជូជំនង ។

ចាប់តាំងអំពីថ្ងៃដែលគាជូជំនងកើតមក នាងអមិត្តតាជាមាតាបេះតែពុំស្រួលកន្លះខួបអស់កំឡាំងហ្មិតល្ហែ ធ្វើការអ្វីៗ ពុំសូវបាន ជាចំរើនដល់គាជូជូង ។ ទំនៀមនៅបម្រើនាងអមិត្តតាពុំបានក៏ចាត់បែងរៀបចំប្រជាប់ប្រជាទំនិងចេញដំណើរវៅគាន់នគរដេតុត្តរ ដើម្បីវៅសុំព្រះពជ្ជានាងកណ្ហាទំនិងបាជាលើជាព្រះពជ្ជបុត្រា-បុត្រីនៃព្រះបាទវេស្សន្តរ យកមកឲ្យបម្រើនាងអមិត្តតា ទំនិងការបើពគាជូជំនង ។ គាជូជកគាត់រៀបចំនាងផ្ទះសំបែងមានស្រួរអង្គរ តែងតែង សាប់ឆ្នើរ អំបិល ប្រហុកទុកឲ្យនាងអមិត្តតាបរិភោគតំណាក់ ១ ឆ្នាំទើបប្រែអស់ រួចគាត់ផ្តាំនាងអមិត្តតាថាបូរនាងនៅឲ្យសុខសម្រាន្ត កុំដើរវៅលេងទីហានអ្នកជាដៃ កុំបង្ខូលក្បៀវប្រុសចំឡោះ កុំញ៉ាះញ៉ាំនឹងអ្នកព្រៃង តាវៅនេះបើជាមានលាភដូចបំណងនឹងលែមកវិញជាធាប់មុនតំណាក់ ១ ឆ្នាំ បើជាឥតលាភទេ ទំនិងស្វែង

រកលាក់ផ្សងៗគេចៀត ។ តាជូដតគាត់ផ្លុំរួច គាត់ថើបបង្កោស
អង្គុលនាងអមិត្តតា រួចគាត់លើងតាជូដដំងបីខ្នើង ហើយគាត់ចំរៀងថា:

"កូនអើយនាងដេកគេ ខុកពេលឲ្យខុសអង្គុលម៉ែ
ខុបែនគេយូរខ្លះ ណែកូនចាំបណ្តាំខុ ។
ដេកយប់កូនកុំយំ ខ្លាចមៀមមុំវាចាំផ្លូវ
ចាប់យកត្រលាំងគេ កូនគេអើយនាងឈឺថ្កាត់" ។

ហើយគាត់ដាងគេលោមនាងអមិត្តតាថា:

អមិត្តតាចៅតាអើយ តាលាគេហើយណាចៅណា
ចូរនៅសុខសាន្តក្នុងកាយា កុំគិតនឹងតាណាចៅអើយ ។
តាគេមិនយូរប៉ុន្មានទេ ចូរមេក្បាកូនគ្រាណាត្រឡប់
តែបានខួលលាកស្រេចហើយ ចៅអើយតាវិលមកវិញភ្លាម ។

តាជូដតគាត់លោមលាស្រេចហើយ គាត់ក៏ស្ពាយសជូរាវាតាងតាន់
ឈើច្រត់ចេញទៅដល់កំពង់តាវ៉ែងតបានជួបព្រះនឹងព្រះវេស្សន្តរ គាត់ក៏
ចូលទៅសុំយកនាងកណ្ហាខឹងបាងាលីបានសម្រែចជូបក្តីប្រាថ្នាចេះគាត់។
តាជូដតក៏នាំយកនាងកណ្ហា ប្រាងាលីមកពាន់លើនគរជេតុត្តរ ។

គ្រានោះ ព្រះបាទសញ្ជ័យដែលត្រូវជាព្រះអយ្យកោឃើញតាជូដត
នាំចៅកណ្ហា ប្រាងាលីមកក៏ច្រឡំងោងុក ដើម្បីលោះដោះសាយកនាង
កណ្ហា ប្រាងាលី។ បានត្រាបទូលសម្តេចព្រះអយ្យកោអយ្យិកាថា ព្រះ

របៀតាបានពាយដំឡៃខុកជាមុនតម្លាក់ ១០០ សែនជម្លឹងមាស ។ ព្រះអង្គ
ទ្រង់ឯញ្ជាក់តាជូជតា ក៏ក្រាបទូលថាមែន ទ្រង់ឲ្យជញ្ជូនយកមាសពី
ព្រះឃ្លាំងមកតាំងខុកឲ្យតាជូជតពិនិត្យចំនួន ២០០ សែនជម្លឹង ។ តា
ជូជតបានឃើញគំនរមាសដ៏ច្រើនតន្ទឹកដូច្នោះហើយ ក៏មានសេចក្តីឆេ
ឆួជាអនេកអនន្ត តាត់គិតថាអាត្មាអញនឹងក្លាយទៅជាមហាសេដ្ឋីកង
ជាន់ហ្នឹងហើយ ។ ព្រះបាទស្រីសញ្ជ័យព្រះអង្គចាត់ឲ្យពួកពិសេសរៀប
គោជនាហារជប់លៀងតាជូជតជាការឧបស្ថាន ដែលបាននាំព្រះពជនភ្លោ
ព្រះពជនភ្លាមកដល់ព្រះនគរព្រះអង្គ ។ តាជូជតក៏ចរំកោងអាហារដែល
ព្រះពជាននលៀងនោះ បណ្តាលឲ្យកើតជាជម្ងឺចុកពុះសៀតស្ទាប់
ក្តីឯតែនោះទៅ ព្រះបាទស្រីសញ្ជ័យក៏ទ្រង់ចាត់ការរំលាយសពតា
ព្រាហ្មណ៍តាមរៀបរបបទ្រង់ឲ្យចាំវាគន់រកអ្នកឯណា ដែលជាញាតិទំង
ខ្មោចតាជូជត ក៏រកគ្មានម្នាក់សោះ ហេតុដូច្នេះទ្រង់ឲ្យបង្វិលមាសទាំង
នោះបញ្ចូលទៅជាព្រះពជទ្រព្យ ក្នុងព្រះឃ្លាំងមហាសម្បត្តិរបស់ព្រះអង្គ
វិញទៅ ។

រីឯនាងអមិត្តញ្ញា នាងក៏ខំធ្វើតង្ឃន់តម្រង់ចិត្តកេរ្តាកូនរង់ចាំស្វាមី ជាយូរ
ឆ្នាំណាស់ពុំមានឮដំណឹងអ្វីអំពីស្វាមីសោះ ដកបដល់តាជូជតាអាយុបាន
១៥ ឆ្នាំ ក៏នៅតែពុំបានដំណឹងអ្វី ឯតាជូជតាជាក្មេងចាំតែអប្សល់កូណ
ធំឡើងជាដំណើរការណា ក៏បេះតែប្រព្រឹត្តអនាចារពោលាផ្សេង ។ ហើយ

គាចព្រៃហ៊ានមិនស្គាល់ខុសត្រូវ អ្នកស្រុកជិតខាងគ្នាញាត្រូវធ្វើញឲ្យទាន់ ឲ្យសម្បត្តិដែលជួបកុងឲ្យបន្តិចបន្តួច កំលួចលាក់បញ្ចាំស៊ីជាទម្លន់ លេងល្បែងអស់លេង / ។ នាងអមិត្តតាក៏ព្រួយចិត្តឥតស្រាកស្រាន្ត ញាតិសន្តានជិតខាងគេក៏ខឹងស្អប់គ្រប់ៗគ្នា មានវេលាថ្ងៃ១អ្នកស្រុកជិតខាងគេក្តៅក្រហាយណាស់ គេក៏នាំគ្នាលួចដុតផ្ទះនាងអមិត្តតា។ ក៏ស្អាប់នៅក្នុងភ្លើងនោះទៅ សល់នៅតែគាជួជំងឺ ដោយវាទៅក្នុងខានកំឡាំងច្រើនក៏លោតរួចផុតចេញពីភ្លើង ។ ថ្ងៃក្រោយមកជួលឺងត្រូវជាមាអាជួជំងឺតគាត់ត្រូវជាប្អូនតាជួជបង្កើត ក៏រើសយកអាជួជំងឺទៅចុកឲ្យនៅជាមួយ ដើម្បីថែទាំប្រៀនប្រដៅឲ្យបានបទតាមសណ្តាប់អ្នកស្រុក ។ អាជួជំងឺនៅមិនសុខដោយមាប៉ិនប្រៀនហួសពេក កំលាមាទៅទៅវត្តតាកែក មាក៏នាំយកវាទៅឆ្លើឲ្យទៅវត្តតាមបំណង ។ អាជួជំងឺវាបានទៅទៅវត្តវេហាណា វាទាំកូនសិស្សក្នុងវត្តនោះខូចអស់ រៀលយប់វាទាំពួកសិស្សវត្តចេញទៅលួចចេកអំពៅនឹងលួចមាន់ពាអ្នកស្រុកយកទៅលក់ឲ្យចិនដើម្បីយកប្រាក់ទៅជាក់តំណល់គ្រួស្នេហ៍ អាជួជំងឺចូលចិត្តផ្គាប់គ្រួស្នេហ៍ដើម្បីរៀនស្នេហ៍យកទៅជាក់ស្រី។ ។ គ្រួស្នេហ៍បានតំណល់ច្រើនក៏បង្រៀនស្នេហ៍ឲ្យអាជួជំងឺ ។ មេ គឺស្នេហ៍ករកថា ៖ ខុម: ខ្ញុំនហ្គួតែក ខ្ញុំនចែកស្នេហា ឃើញអញសន្ធប់ឡឺនឡាន់ ម:ម:ឯហ៊ាឯចា'' ។ គ្រួប្រាប់ថា បើស្រឡាញ់ស្រីណាឲ្យយកផ្ចុំដ៏មកសូត្រ ៧ចប់ ផ្ចុំដ៏ហើយ

ចោលដម្រន់ខ្លួនស្រីនោះ។ ខ្លឹងដេញអ្នកឯងរហូតដល់ផ្ទះ ។ អាជូដឹងរឿងបានមេស្នេហ៍ហើយ ក៏ដើរចូលទៅមើលស្រី។ ដែលគេកំពុងតូចក្បូនក្បុំខ្សឹបខ្សៀវនៅវត្តតាក្រែ លុះសំគាល់ឃើញស្រីម្ចាស់ជាទីពេញចិត្តហើយ ក៏ចាប់ផ្តើមដងកមកសួរគាថានោះបាន ៧ បទ កំចោលដម្រន់ទៅត្រូវក្បាលស្រីនោះ។ ខ្លឹងក៏នាំចង់ប្លន់ដេញ អាជូដឹងក៏ទំរន់ដម្រន់ទៅផ្ទះ ស្រីមានក្តីខានជាស់ ក៏ចេះតែដេញតាមអាជូដឹងរត់ចាប់ណ្តើរគិតថាណ្តើរថាស្នេហ៍អញតូចតែឈឺស់ អញដាក់តែ ១ ត្រូវស្រី ១ ហ្វូង។ លុះដេញពន់ឆ្ងាយគេជាក់ពាត់ហ៊ាន់គេដេរដៀលពូជប្រជូចសន្ធាន គេចាប់ចង់នាំយកទៅប្រគេនលោកត្រូវតូចតាក្រែ។ លោកខ្ញាល់ចង្អាប់ឲ្យចង់ហាលថ្ងៃវាល់ល្ងាច ។ អាជូដឹងចេះតែនឹកឆ្ងល់ថា អញបានរឿនស្នេហ៍អស់ប្រាក់តែតោះអញបានប្រទះតែគ្រោះកាចយ៉ាងនេះ អញនឹងខុកស្នេហ៍នេះគេទៅទៀតពុំបានទេ តិតហើយក៏ដកស្នេហ៍នោះទៅប្រគល់ឲ្យគ្រូវិញ ។ គ្រូសួរថា តាលឯងចោលគេនោះ តើពាក្យត្រូវត្រង់ណា អាជូដឹងថា ត្រូវត្រង់ក្បាល គ្រូស្នេហ៍ថា ឯងខុសហើយអញបង្គាប់ឲ្យចោលខ្លួន ឯងទៅចោលក្បាលបានជាកន្ត្រៃយ៉ាងម្តេច ល្ងើយឯងលែងរៀនទៅ តែម្តងទៀត ឯងមុខតែជាប់តុកមិនខានឡើយ ។

ក្រោយជូលីងជាប្អូនតាជូដងបានឮដំណឹងថា តាជូដងតាត់ខ្លួលអនិច្ចកម្មទៅក្រុងដេងតូចនេតទៅហើយ តាត់មានមតិត ២០០ សែន

តម្លឹងមាសខុងនៅក្នុងព្រះឃ្លាំង ជូលីងគាត់គិតថា ជូជនគាត់មានកូនប្រុសឈ្មោះអាជូជីង ឥឡូវអាឃុំទើបបាន ១៩ ឆ្នាំ អាគ្មាកញ្ជូរទាំងចូលទៅខ្លួលមតិកចាំងនោះ ព្រោះថាជាអ្នកស៊ុមតិកមានជំហ្មៃ ជូលីងគិតជូរួចហើយក៏ចាត់ចែងរៀងអាហារនឹងសោហ៊ុយផ្សេងៗ បានស្រេចហើយគាត់ក៏នាំអាជូជីងចេញពីនគរលង្កាជូដម្រង់ទៅនគរជេតុត្តរៈអស់ ២ ទៅ ២០ ថ្ងៃទើបបានដល់ ជូលីងគាត់នាំអាជូជីងចូលទៅជួបនឹងពាងហ្វាងព្រះឃ្លាំងមហាសម្បត្តិ។ តបថា ពិតមែន តែបើអ្នកបង់បានមតិកនេះត្រូវតែអ្នកជួនក័ស្តុតាង គឺសំបុត្រអត្រាខ្ទុកូលជាដើម។ ដូចតទៅនេះ :

๑) សំបុត្រវៀចការខ្ចោចតាជូជនឹងខ្ចោចនាងអមិត្តតាដែលបានវៀចការយកគ្នាជាប្តីប្រពន្ធតាមច្បាប់ -

๒) សំបុត្រកំណើតខ្ចោចតាជូជនឹងសំបុត្រកំណើតនាងអមិត្តតា-

๓) សំបុត្រមរណភាពខ្ចោចតាជូជនឹងសំបុត្រមរណភាពខ្ចោចនាងអមិត្តតា -

๔) សំបុត្រកំណើតតាជូជីង -

๕) សេចក្តីឆ្លើយតបហេតុ ពីវង្សត្រកូលតាជូជនឹងនាងអមិត្តតា ឯសេចក្តីបញ្ជាក់ពីវង្សត្រកូលនេះ ត្រូវសេ្តចនគរលង្កាជូដម្រង់ប៉ាប់រងផង ។

លិខិតទាំងឡាយដូចរៀបរាប់ខាងលើនេះ ត្រូវចំណែកមក្នុង ១ សន្ធឹក ១,៦០ ហើយមានសេចក្តីបញ្ជាក់ពីព្រះមហាក្សត្រនានាកាលទ្រង់ផ្ទុតទើបត្រៃការបាន ។

លិខិតទាំងឡាយនេះ ត្រូវអ្នកនាំយកមកជូនតុលាការខាងនគរជេតុត្តរ ព្រមជាមួយនឹងពាក្យ ១ បណ្តាប់ដែលសុំខ្ចីយកមកតិកនៃភ្នែកគាជូដក ។ រឿងនេះត្រូវអ្នកគិតគូរឲ្យបានឆាប់ឲ្យទាន់ពេលវេលា ព្រោះមតិកនេះមានអាយុតែត្រឹម ៨ ខែទៀតទេ ទំនងផុតកំណត់ ៩ ខែហើយទំនងតាមការគ្រាន់តែអ្វីទៀតពុំបាន ។ លោកចាងហ្វាងព្រះឃ្លាំងមហាសម្បត្តិអធិប្បាយប្រាប់ប្រាប់ប្រៀបប្រាប់ឲ្យជូលីងស្តាប់ដូចខាងលើនេះ ជាការស្រេចតាមប្រាប់ឆន្ទៈរបស់នគរជេតុត្តរមែន ។

ឯជូលីងលុះបានស្តាប់សព្វគ្រប់ទៅគាត់គិតឃើញថារឿងមតិកនេះជាការធំធ្ងន់ពេកណាស់ ព្រោះលិខិតទាំងប៉ុន្មានដែលលោកព្រះឃ្លាំងមហាសម្បត្តិប្រាប់ពន្យល់ឲ្យធ្វើនោះ នៅនគរលិង្គដ្ឋ ឥតមានធ្វើទេ គ្មានអ្នកឯណាដែលស្គាល់ដីធ្លីសោះ ទើបគាត់ដាក់ទៅនិយាយទំនងគាជូដីធំថា ណ្លើយគាជូដីធំយើងនូវត្រឡប់ទៅស្រុកយើងវិញចុះ មើលទៅគ្មានសង្ឃឹមអ្វីដល់តិចតួចសោះឡើយ ទើបគាជូដីធំតបថា អើបើយតមតិកមិនបានក៏ប៉ាហ៊ាទៅចុះ តែលោកមាតិតាយកតែជាតុដុតកុំឲ្យបាននាំយកទៅស្រុកវិញចុះ ។ ជូលីងឮដូច្នោះក៏ទំនងឃើញថា មែនហើយ។

ចូលទៅដួចនឹងលោកព្រះឃ្លាំងម្ដងទៀត ដើម្បីសួរនេធាតុនៃខ្លួច
តាជូដក ។ លោកព្រះឃ្លាំងតបថា ចំខ្ញែមស្រុងនេះ នេមិនដែល
ពុកធាតុខ្លួចមនុស្សអីនាថា អតញ្ញាតិសន្ដានខ្លោះទេ តែនៅតែឯយតទៅ
ជុតលោលយ៉ាដពាប ចូរអ្នកកុំពាំនឹងនេធាតុខ្លោះឡើយ ។ ដូលឯងនឹង
ឆជួជឯងមើលមុខគ្នាទៅវិញទៅមក ហើយក៏លាលោកព្រះឃ្លាំងចេញមក
ខាងក្រៅ ក៏នាំគ្នាបេះតែដើរដែកដៀតតាមផ្សារតួចផ្សារធំ ស្រាប់តែ
ទៅជួចនឹងស្នាក្ដីម្នាក់កំពុងស៊ីផឹកនៅផ្សារ ។ ឯស្នាក្ដីបានឃើញមនុស្ស
ចំឡែកចណ្ដើរគ្នាតាមផ្សារ ក៏ហៅទៅសាកសួរជំនឹងរឿងសព្វគ្រប់ហើយ
ស្នាក្ដីនោះក៏និយាយប៉ាប់រំលឹចាំនឹងយចមកតិចនោះឲ្យបាន ជានានឹងរកលិខិត
ទាំងប្ដឹងគ្នាន ដែលលោកព្រះឃ្លាំងបង្គាប់នោះឲ្យបានផង តែអ្នកខ្លួច
ឲ្យយើងប្ដឹងគ្នា ។ ដូលឯងតបថា ខ្ញុំមានតំណែរណាស់ តែថាខ្ញុំជាអ្នក
ជំណើរមកពីឆ្ងាយ មានប្រាក់ឯសបន្ដិចបន្ដួចសម្រាប់ធ្វើជាសោហ៊ុយ
រឹលទៅស្រុងវិញ ។ ស្នាក្ដីថា បើមិនទាន់បានមតិតមិនទាន់យចនេះផ្ទាន់
ភ្លាមទេ ដូលឯងក៏ឆ្លូនៃឯងចន្ដិច ហើយស្នាក្ដីនិយាយថា ណ្ហើយការនេះ
យើងឈប់និយាយសិន ជ្រាតដល់ពេលបរិភោគអាហារហើយ ចាំ
ក្រោយសឹមជួបនិយាយគ្នាម្ដងទៀត ប៉ុន្ដែអ្នកត្រូវលៀងយើង ១ ពេល
សិន ព្រោះយើងជួយពាក្រងរឿងដល់អ្នកឥស ១ ព្រឹកទៅហើយ ។
ដូលឯងគិតថា ស្នាក្ដីនោះបេះនិយាយជ្រាបជ្រះគ្រាន់បើ គួរខ្លួលលៀង

ចាយ ១ គេលទៅចុះ ដើម្បីខុតទំយាយការគេទៅទៀត តែឥឡូវនេះ
ហើយក៏នាំស្មាក្តីទៅផ្ទះលក់ចាយ បង្គាប់ឲ្យពួកពិសេសរៀបអាហារឲ្យ
ស្មាក្តីបរិភោគរួមជាមួយនឹងខ្លួន រួចស្រែចតែសោហ៊ុយអស់ ២០ រូបិយ
ហើយស្មាក្តីប្រាប់ថា អ្នកថយទៅស្រុកសិនចុះរកសោហ៊ុយខ្លះ យកមក
ពេញលិខិតផ្សេងចូលតក៏យកមកតែ ។ ដូលនឹងកំនាំអាដូដឹងតែឡប់ទៅ
ស្រុកវិញ លុះនាំគ្នាដើរកាត់ព្រៃក្តុំកែថ្មទៅ ស្រាប់តែប្រទះនឹង
មេខ្លាឃណ្តើរកូន ខ្លានោះក៏ទាំងនាំនឹងពីនោះស្រាប់យកទៅបរិភោគអស់
ទៅ ។

ចប់រឿងអាដូដឹងតែប៉ុណ្ណោះ ។

សំ - ស៊ុន

ព្រះគ្រូបញ្ញាលិខិត ភៅ-សឹម

គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

(តទៅ)

ឯយើងនាំគ្នាមកនេះ ដើម្បីនឹងលះបង់ចោលគ្នាឬ ដើម្បីឲ្យបញ្ជូនកិរិយាខ្ញុំទៅកាន់ព្រៃហិមពាន្តមុនហើយ សូមទ្រង់សម្លាប់ខ្លួនឆ្កួតជាមុនសិន ហើយសឹមបញ្ជូនកិរិយាខ្ញុំទៅជាមួយគ្នា ។ ព្រះរាជាទ្រង់ត្រែកអាវ្យកន្ទុរពាំង ២ ដំលើស្មាឆ្អែតហើយគ្រាស់ឲ្យហៅព្រានព្រៃមកឲ្យយកទៅលែងឯព្រៃហិមពាន្តពាំង ២ក៏ កន្ទុរពាំង ២ រួបដែលបានរួបខ្លួនមិនស្លាប់ ព្រោះមិនពោលពាក្យទុក្ខសិត ។

ចប់រឿងសេចក្តីស្អាត ៣ យ៉ាងនឹងប្លាប់ស្មៀត ៣ យ៉ាង

ភទ្ទសោណ្ណា [1]

សេចក្តីថា៖ ពួកសត្តនិករដែលកើតមកក្នុងសង្សារលោកពាំងមូលសុទ្ធតែជាសត្វបរិភោគអាហារចំណី គ្មានអ្នកណាមួយចៀសវាងបានឡើយ សូម្បីតែទេវបុត្ត-ទេពតា ក៏បរិភោគចំណីអាហារទាំងអស់ដែរ តែថាចំណីអាហារពាំងនោះ ជាវត្ថុមានរសជាតិ មានទ្រង់ទ្រាយនឹងពណ៌សម្បុរ

---

១ ជាឧត្តរលេងសុីភក្តីពាំងល្អាយ ។

ថ្ងៃ១អំពីគ្នា, ខ្លះមានទុជាសេធ្លាញ់ពីសា ខ្លះមានសេជ្ឈ-ចត់-ល្ងីង-ហ៊ីរ ថ្លៃជាដើម ខ្លះមានពណិស-ក្រហម-លឿងជាដើម ខ្លះចំអិនទឹងក្តៅ ខ្លះមិនចំអិនទឹងក្តៅ សុទ្ធសឹងតែចម្រុះលាយជាយវត្ថុផ្សេងៗ ទើបកើតឡើងជាចំណីអាហារ ។ ក៏ចំណីអាហារទាំងនេះ មានដម្លៃខុសៗ អំពីគ្នា ខ្លះមានថ្លៃច្រើន ខ្លះមានថ្លៃតិច តាមបែបផែនដែលគេផ្សំគ្រឿងធ្វើ ទឹងតាមបែបប្រទេសស្រុកដែលប៉ុនប្រសប់ធ្វើទឹងមិនប៉ុនប្រសប់ធ្វើប៉ុណ្ណោះ ជាវេសមានទុជាសេថ្លៃតៗ គ្នាជាដរាប ។

ចំណីអាហារជាគុណសម្បត្តិ ឲ្យអ្នកបរិភោគ ចំរើនសរីរៈជាតំណ្ដ ឲ្យមានកំឡាំងរឹងប៉ឹងល្អ ឲ្យមានស្មារតីដំណើរទឹងទួន ទឹងឲ្យមានជាតុទាំង ៤ ប្រព្រឹត្តទៅស្មើគ្នាស្រួល ត្រមទាំងឲ្យមានឥរិយាណសម្បុរស្បែកល្អផង ។

ឯចណីអាហារដ៏ខ្ពង់ខ្ពស់ មានទុជាសេធ្លាញ់ក្រៃលែងជាងចំណីអាហារនោះ ត្រូវដឹងថាជាអាហារដែលទឹងទឹងទាំមនុស្សដែលធ្លាប់បរិភោគឲ្យញ៉ាំមមិនក្ងេចក្ងេបមិនផុត ចូលទៅរចនាដំណើរនៃទឹងលក់រឿយៗ ឲ្យជាប់ចិត្តភាន់ភាំទឹតក្ងេចទឹតនាដល់សេចក្តីចាស់ក្រ ទឹងសេចក្តីអន្តរាយផ្សេងៗ ហាក់ដូចជាចាប់មនុស្សក្នុងស្រុកទេសទៅលក់ជូរវេងដែរ ព្រោះថាចណីអាហារមែងទាញចូលស្រួចមនុស្សឲ្យលុះជាប់ដោយទុជាវេសបែបនោះ ។

មនុស្សណាចូលចិត្តតែនឹងបណ្ដាអាហារបែបនេះ រៀងៗខ្លួនចង់អាហារវិចិត្រប្រណីតសួនឲ្យខ្លាំងតាមកាលៈទំនើបសម័យហើយ មុខជាត្រូវប្រឈមនឹងគ្រោះថ្នាក់ ធ្លាក់ដល់សេចក្ដីទុក្ខយ៉ាងធំជាងមនុស្សអ្នកបរិភោគអាហារតាមធម្មតាមានតាមមាន ។

ហាក់នឹងថា ដូចជាឥស្សរជនណាមិនចង់ឲ្យគេទទួលទានគោជនាហារដ៏ថ្លៃថ្លា ឬជួយកំណាញ់មិនឲ្យគេចាយលុយឆាប់ក្រោកឈរបស់គេ ពិតជាដូច្នោះខ្លះមែន ! ក៏សូមអស់លោក - អ្នកឡើងគាន់ចំណែងតែនឹងនោះ ត្រូវពិគ្រោះដល់ធនធានទំនិញសម្បត្តិរបស់ខ្លួនឲ្យជាក់ច្បាស់ ហើយសឹមបរិភោគឲ្យពាល់ពេលវេលាចុះ ។ តែថាត្រូវនឹកវិភាគដល់បច្ច័យ ២ ហ៊ាន:

១ - អន្តោបច្ចយ បច្ច័យដែលត្រូវគាក់តែងខាងក្នុងផ្ទះ

២ - ពាហិរបច្ចយ បច្ច័យដែលត្រូវគាក់តែងខាងក្រៅផ្ទះ ។

ឯអន្តោបច្ចយ បច្ច័យដែលត្រូវគាក់តែងខាងក្នុងផ្ទះនោះ ត្រូវចេះវិភាគថា: សព្វថ្ងៃនេះគ្រួអញមានគ្រឿងអាភរណៈស្អីកញាក់គ្រប់គ្រាន់ដល់ប្រពន្ធកូននឹងក្រមញាតិហើយឬ? មានគ្រឿងស្បែងអាហារបិញ្ចឹមជីវិតល្មមគ្រប់គ្រាន់ហើយឬ? មានទីលំនៅផ្ទះសំបែងក្នុងដេចគ្រួសារ ទំនិញគ្រឿងប្រដាប់ស់ពាប់ប្រើប្រាស់តែងតាំងនៅក្នុងផ្ទះគ្រប់គ្រាន់ហើយឬ? មានគ្រឿងកេសជ្ជៈកែរពេលគ្រប់គ្រាន់ជាប្រចាំហើយឬ? បើ

បច្ច័យទាន់ក្នុងមានបរិបូណ៌ហើយ តែខ្វះពាហារប្បច្ច័យ បច្ច័យទាន់ក្រៅ នោះចំបែរព្រឹត្តទៅមិនបួចដែរ គោរតែឲ្យមានពាហារប្បច្ច័យផង ទើបបែរព្រឹត្តទៅរួច ។

ឯពាហារប្បច្ច័យនោះ ត្រូវនឹងពាក្យថា សព្វថ្ងៃនេះគាត់អញ្ជើមានយានវាហនៈ ទីធនាគារមួយធំសំបើមដ៏ះបរាសេនីទាន់លើនោត លើទឹកគ្រប់គ្រាន់ដល់ខ្លួនទីធនីគ្រួសារហើយឬទ្ធ? តាលបើបច្ច័យទាន់ពីរនេះមានបរិបូណ៌ហើយ គោះបើទីធនីដើរចេញទៅឬចាយប្រាក់ការទិញបណ្ណាគារបរិភោគនោះទើបចេញសាធារណៈសេចក្តីអន្តរាយបានខ្លះ ។

មនុស្សខ្លះគិតតែធំតែទាន់ក្រៅ ឯទាន់ក្នុងមិនបានតែធំ គឺថា : ទីលំនៅៗជាតកោនសំណាក់គាស្រែយគ្មាន ·សម្បែងអាហារគ្រឿងចិញ្ចឹមជីវិតឲ្យល្មមគ្រប់គ្រាន់ដល់ប្រពន្ធកូនក្រុមញាតិ ដែលគ្រែតនៅរួមសុខទុក្ខជាមួយក៏គ្មាន គ្រឿងប្រដាប់សំពាក់ប្រើប្រាស់ក្នុងផ្ទះក៏គ្មាន ហើយប្រាំងតែធំតែទាន់ក្រៅ តែចាយលុយគាក់ស្ទើរពាក់យ៉ាងល្អ បរិភោគបណ្ណាគារលេចបួលទៅរួច ។

មនុស្សយើងត្រូវយោលតំនិតគិតដែងគាលជា ២ ចំណែក:

១ - កាលណែកុំដែងឲ្យខ្វី

២ - កាលខ្វីដែងឲ្យណែ ។

ឯការណ៍នៃកុំបែងឲ្យខ្ជិលនោះ ត្រូវដឹងថា៖ មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ សុទ្ធសឹងតែមានមាតាបិតាការិយាបុត្រ ក្រមញាតិពួជពង្សបង្អាប់ខ្ទម្ងាប់សំពាប់រក្សាជាតិគ្រប់ៗគ្នា ក៏ក្នុងគ្រកូលនិមួយៗនោះមានចរិយានឹងការប្រព្រឹត្តត្រឹមត្រូវក៏មាន មិនប្រព្រឹត្តត្រឹមត្រូវក៏មាន ការស្លៀកពាក់នឹងត្រឹងប្រើប្រាស់ស៊ីចុកលើសខ្លះជាងគ្នាខ្លះក៏មាន ដូចគ្នាខ្លះក៏មាន ស្មើគ្នាខ្លះក៏មាន ត្រមាំងឆោតយល់យឺតឲ្យសម្បត្តិលើសខ្លះដូចគ្នាខ្លះ ស្មើគ្នាខ្លះក៏មាន មិនសូវដូចគ្នាទាំងអស់ឡើយ ។ តែថាដែលដូចគ្នានោះ គឺមាតាបិតា ការិយាបុត្រ នឹងកេរ្តិ៍ឈ្មោះរបស់ខ្លួននេះហើយ ជាកេរ្តិ៍ចាំកោលដើមរបស់មនុស្សដែលសង់ឆៅក្នុងលោកនេះ ។ មនុស្សត្រូវតែគិតដល់សេចក្តីស្រេចឃ្លាន ការខ្វះខាតរបស់ជនទាំងនោះត្រូវជួយបីបាច់ចិញ្ចឹមថែរក្សាការពារ កុំឲ្យមានសត្រូវណាមួយមកបៀតបៀនបាន ព្រោះជនទាំងនេះហើយជាអ្នកដំណាងជាតិទឹកដី ប្រជៅកូនចៅប្រុសស្រីមិនឲ្យប្រព្រឹត្តធ្វើអំពើហួសមារ យសស័ក្តិ ពួជពង្សបង្អាប់ខ្ទម្ងាប់ នឹងទំនៀមរបស់ស្រុកដែលសម្រាប់ទុកឲ្យជាកេរ្តិ៍កាលរៀងដល់កូនប្រុសស្រី មិនគួរកូនប្រុសស្រីចៃដន្យនេះឲ្យខ្ជីខ្ជៀវឡើយ ត្រូវប្រមាណឲ្យសមគួរដល់ជាតិគ្រកូលរបស់ខ្លួនប៉ុណ្ណោះឯង (កុំស្តុះឲ្យហួសផុតបន្ទុលឡើយ) តែមានមនុស្សខ្លះមានគំនិតគិតយកសៅតែម្ចាក

ឯង ឥតមានតិតដល់មាតាបិតាត្រកូលញាតិបងប្អូនឡើយ ឈ្មោះថាជាមនុស្ស (រៃកប្រឡោះឲ្យចុះនៃខ្លួន ១) ។

ឯឈលខ្វីចែងឲ្យវែងនោះ ត្រូវដឹងថា: មនុស្សយើងកើតមកមានអាយុខ្លី បើរកស៊ីបុកគំខ្វី ទីលំនៅនឹងគ្រឿងប្រើប្រាស់ក៏ខ្វី បុណ្យស័ក្តិនឹងកេរ្តិ៍ឈ្មោះក៏ខ្វី មិនតាំងនៅយូរប៉ុន្មានឡើយ តង់នឹងវិនាសទាប់ មិនត្រូវធ្វើសេចក្តីចង្រៃអោយាជ ព្យាបាទគំនុំគេរឿងបៀតបៀនគ្នាទៅវិញទៅមកឲ្យចាល់តែដល់សេចក្តីវិនាសអន្តរាយខ្លួនឯងឬក្តី ខ្លួចកេរ្តិ៍ឈ្មោះយសស័ក្តិភ្ជាក់ទៅជាមនុស្សថោកទាបដល់ត្រកូលជាតិស្រុកទេសរៀងខ្លួនកេសេចក្តីសុខនោះគ្មានឡើយ ត្រូវធ្វើអ្វីមួយខុសជាប្រយោជន៍ដល់ជនដែលកើតមកខាងក្រោយ កុំឲ្យបាត់ឈ្មោះខ្លួនឲ្យបានកាលតវែងទៅ ។

សូមបំភ្លឺសេចក្តីជាពាក្យកាព្យយ៉ាងខ្វីដូចតទៅនេះ:

កាព្យពាក្យ ៧

លោក- អ្នកចរិតគោតអាហារថ្លៃ ចាយលុយសព្វថ្លៃមិនទំកនា
ដល់កូនប្រពន្ធមោរំហែ គ្មានកោដនាយ៉ាងដូចម្តេច ។
ខ្លើងលើកៅអីបង់ចំពែន លើកជើងតជ្រែងសង្កត់ដៃ
លើតុខ្ពែមុខសប្បាយក្រៃ កែងមើលរំពៃតួអក្ខរ ។

ដែលចិនវាក់តត់ឈ្មោះនៅផ្ទាក(១) កុំឲ្យពិបាកការឡូវឡា
តាំងហៅអាចឹងមកច្រែបាប់ថា ឲ្យធ្វើកក្ស(២) តាមត្រែវចិត្ត ។

ចិនលើតអាហារដាក់លើតុ ដបស្រាចំមុខបើកឆ្នុកចិច ចាប់តែវាក់
ស្រាដាក់មកជិត ស្លូវាលើតដតគិតធំក ១ ខ្ទីក ។ ចាប់សមស្វាបក្រាបូក
ជាយមួប អណ្តាតតាវស្រែបលេបបួលគ្រឹក ដាមីសាច់សោតដតមាន
ខ្លឹក ស្លាបព្រាសមញឹកចាក់ទ្រាត់ខ្លែង ។ ឆ្អែតស្រែបយកឈើមកចាក់
ធ្មេញ ស្អាតលើងឆេញអស់ឆ្អឹងឆ្អែង ដូតដៃជូតមាត់ខិនកខ្សែង ដក
ជាវីផ្សែងបង្គុយព្រាត ។ គ្រែកឡើងជិះកង់ត្រឡប់កាយ ជិះលេង
សប្បាយដល់អធ្រាត្រ ទើបមកដល់ផ្ទះឆ្កែព្រុសព្រាត ប្រពន្ធដៀល
មារយាទជាត់គ្រែកអរ ។ តើតឈ្មោះប្រែកែតដែកន្លា ទុកឲ្យមតិកដំ
បរែ ទំហូតេដ្រមាសខ្ទុកកំដរ ជាកត្តីអាងតាមាតា ។ លបលួចដៅលក់
ឬបញ្ចាំ កន្ទុនថ្ងៃទៃឆ្នាំឆុតប្តេជ្ញា បំផ្លាញគ្មានសល់ចេស់ណា យកដី
គ្រែហាបញ្ចាំទៀត ។ បញ្ចាំតាំងស្រែចំការចេត សូន្យឈ្មោះសូន្យស្រែ
ផុតអស់ស្លឹត មិនដឹងគិតតែលក់អ្វីទៀត ដើរវេរជ្រែតបៀតសុំតែស៊ី ។
ហៃអស់លោក-អ្នកតាំងប្រុសស្រី កុំធ្វើមេត្រីអ្នកញាំញី លក់ទ្រព្យ
សម្បត្តិអស់ខ្លួនខ្ចី ដល់ទីបួនថោកអស់ជន់ច្រាក់ ។ (មានត)

---

๑ ភាសាបារាំងសែល (plaque) (ក្តារសម្រាប់សរសេរអក្សរកត់ឈ្មោះម្ហូប) ។
๒ ពាក្យហារត្រែប់យ៉ាងដែលបុគ្គលចរិភោគ ។

លោកមហា "សៅរ៍-លីរ៍"

វត្តសោយ ឃុំមៀន ស្រុកកោះសូទិន ខេត្តកំពង់ចាម

(ត)

សដីវិតំ បរិច្ចជេ វុឌ្ឍិកាមោ សនេសកំ
តេហំ ជាវំ ករំ នភេ ជាតុអយំ បរិច្ចជេ ។

បង់ឲ្យចែចេសខ្លួនវឌ្ឍនា ត្រូវបង់ប្តូរគាលៈជីវិត បង់ដូច្នឹងហានាក់ឲ្យដឹង តាំងចិត្តលះឈើនឹងដែកកុំស្តាយ ។

សច្ចំ វេ អមតា វាចា ឯសធម្មោ ឧ ដីវតំ
អប្បមត្តា ឧ មីយន្តិ ឯឝ្ញាំ អដាមតំ ។

វាចាសត្យជាពាក្យមិនស្លាប់ពិត នាមគឺត្រកិត្តិដឹងស្លាប់សោះសាជនមិនច្រមាទមិនមរណា ឥឝ្ញានហានសុទាមិនចាស់ស្លាប់ ។

សុភាសិតថា

ស្លាប់រូបកាយកុំឲ្យតែស្លាប់កេរ្តិ៍ ស្លាប់តលរបៀបកុំឲ្យតែស្លាប់នាយ សូវស្លាប់ថ្មាកុំឲ្យតែស្លាប់ម្តាយ នេះពាក្យបរិយាយបុរាណ ។ យប់ធំដឹងកុំឲ្យតែភ្លាក់ខ្លួន ដល់ចក្ខុរកេកុំឲ្យតែភ្លាត់ចិត្ត សូវបង់ត្រៃព្យកុំតែបង់កាយ សូវបង់គាត្តកុំតែបង់ឆ្នូ ។

ពុទ្ធានុវាតោ សតីមតោ

សុចិកម្មស្ស ឯសម្មការិនោ

សញ្ញតស្ស ច ធម្មជីវិនោ

អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ជនដែលៗប្រាយោមប្រឹងប្រែងឃ្លាតខ្លី មានស្មារតីដឹងជាធម្មតា បេះចាត់ចាវងាវស្អាតចាកពោសា គ្រេរដោយប្រាជ្ញាមុនដែលនឹងធ្វើ ។ សង្រ្គមចប់កាយវាចាចូរចិត្ត ចិញ្ចឹមជីវិតតាមធម៌ស្មើ ។ មិនប្រមាទធ្វេសក្នុងកិច្ចសិពើ រវែងចំរើនទ្រឹះទ្រែងរដោយយសា ។

កមភនំ រតិ បុប្ផេ បក្កីនំ ឧកលយេ

ជុនិនំ រតិ សទ្ធម្មេ មហោសិនំ តថោវនេ ។

តមាជាតិត្រែតនឹងបុប្ផា បក្សីបក្សាត្រែតនកាល័យ ប្រាជ្ញមុនីត្រែតធម្មវិន័យ មហាឫសីត្រែតតថោវិន ។

ពុទ្ធានកាលញ្ញិ អនុដ្ឋហានោ

យុភ ពលី អាលសិយំ ឧបេតោ

សំសន្ទសង្កប្បមនោ កុសីតោ

បញាយ មគ្គំ អលសោ ន វិន្ទតិ ។

ជនឃុំនៃដែលមានកាយពល មិនប្រើដង្ហាយខ្លួលក្នុងកាលត្រូវប្រើ ប្រកបដោយក្តីខ្ជិលច្រអូសរឹង ស៊ុដេកពាំងចាក់សនាវិញ ។ លិចលង់តប់ក្នុងកក់តិចុបស្ងួត មានចិត្តមិច្ឆាតែក្តក់ជ្រែញ ឃុំនៃមហាកំដៅនោះពេញ ទើមិនបានមិញការមគ្គដោយញាណ ។

មិទ្ធី យទា ហោតិ មហាកាយោ ច
និទ្ទាយិតា សម្បរិវត្តសាយី
មហារុហោ ឋានសោ ន វិជម្ភិតា
បុនប្បុនំ កព្ភមុបេតិ មន្ទោ ។

ជនណាមានក្តីងងុយ ច្បាស់តែល្មោកស៊ុប្រើនជ្រុលមាត្រា និទ្រានៃខ្លួលក្តក់លង់កាលា ដូចមហាសូកែរជ្រួតស្រុតអង្រួយ ។ ដែលនេះបំប៉ន់បំកាន់សញ្ញា ដោយនិវាបាកណ្តូនចំណី នៃជននោះតែពេញពាលមុខ្លី តែងសម្លឹកងងឹតកំរើយ ។

មន្ទោ សទ្ធោ ឯឋ សតីមតោ
មត្តំ ជានតោ លទ្ធកោជនេ
តនុកោ សទ្ធ កវន្តិ វេទនា
សនិកំ ជីរតិ អាយុ ថាលយំ ។

ជនអ្នកមានស្មារតីជម្ងឹត ដឹងមាត្រាក្នុងលទ្ធកោជន តែងមានទុក្ខវេទនាតិចទន់ ទាំងជន្ត្រវិញាបាលក៏ជាស្បែត ។

ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ
មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ។

ធម្មតាចោរយើលចោរប្តូចោរ៉ ជនមានវេរីយល់ជនវាង បង់ព្យាបាទ
ព្យាបាទខ្លួនគ្នាឯងគ្នា កើតចោសវេទនាអុំពីក្នុយ ។ តែឯចិត្តដែលគេ
ដំណល់ខុស មានកំហុសលាមកលើសនោះទៀត ធ្វើគេឲ្យវេទនាក្នុង
អសង្ខ្យេយ្យ ដ្បិតនិស្ស័យចិត្តបាបអបាយទាញ ។

សប្បាយកុំសប្បាយមិនសប្បាយ សប្បាយកុំសប្បាយពាល់តែ
ភ្លាត់ សប្បាយកុំបែបសត្វតេតខ្លាត់ សប្បាយកុងវដ្តច្រាស្បត់រិះរិនខ្ន
សប្បាយកើតមកពីមានសម្បត្តិ សប្បាយខ្លាត់ច្បាត់មកពីសូន្យធន
សម្បត្តិមានមកពីសិល្បសាស្ត្រមន្ត ត្រូតត្រែនព្រោះមន្តធនសូន្យឆេង
ច្បាបឆ្កំបុណ្យខន់តិចខ្លិចខ្លុក ច្បាបបុកសុះចោលច្បាត់ភ្លាត់ខ្លុកត្រែង
បុណ្យមានច្បានសុខមិនសោកវង្វេង សូន្យបុណ្យត្រែងសុខច្រាស
ត្រឡាស់ឆាន ។

បុណ្យមានច្បាបមានសុខមានខ្លុកមាន មានផលតាមស្ថានមានធម្មតា
តែមើលមិនឃើញត្រូវច្បា ត្រូវតាំងចិត្តាចង្ការជាន់ច្ចុ ។

ទុំល្អកោ បុរិសោ ឥច្ឆេ ន សោ សព្ពត្ថ ជាយតិ
យត្ថ សោ ជាយតិ ធីរោ តំ កុលំ សុខមេធតិ ។

• បុរសអាជាមេយ្យក្រុងជ្រចំណាន ក្រែងបានពុំកើតសព្វស្ថានវ៉ា
បើកើតទៅកន្លែងក្រូលឯណា ត្រូលនោះបានដល់មហាសុខ ។

ឯក្ខត្តំ បដិមានេន្តំ អត្តោ ពាលំ ឧបច្ចគា
អត្តោ អត្តស្ស ឯក្ខត្តំ កឹ ករិស្សន្តិ តាវតា ។

ពួកពាលភ្លៅភៅធោតជើងជោគនក្សត្រ តែឆ័ណាញ្ញូវ្យសម្បត្តិ
ប្រយោជន៍អធឹក ប្រយោជន៍ដែលបានជាន់ក្តួលឫក្ស ដេកនឹកវ៉ាំពឹងតារា
បានការអ្វី ។

ទៃ- ពាលភ្លៅភៅធោតជើងជោគតារា ផ្សងតាមវាសនាពីន
បុណ្យផ្គាយត្រឹក មិនចំរូលភ្លាយទ្យេញសន្ធឹក សំកុកមមឹកពីន៍ផ្គាយ
លើមេឃ ញ្ញូវ្យជនប្រយោជន៍លោកចាំង៉ប៉ុន្មាន ដែលខ្លួនកេបាន
ដោយប្រឹងពន់ពេក លោកចាត់ជាន់ក្តួលឫក្សឯក ពីន៍ផ្គាយលើមេឃ
ផ្គាយធ្វើអ្វីឲ្យ ។

សេយ្យោ អមិត្តោ មេធាវី យតោ កាសានុកម្បកោ
មុនិ អមិត្តោ និទ្ទោសោ ពាលោ ទោសោ ឥទេ ឥទេ

បណ្ឌិតពុំជាមិត្តធំប្រសើរគប់ ជាងសន្តែ្លះពាលពប់ហ្មឺនភាន់
ពុំសង្ឃា បណ្ឌិតខឹះមិនមិត្តក៏ឥតឲ្យទោសា ឯពាលមោហាឲ្យទោស
ពស់ដំហាន ។

សុភាសិតថា

កូនមានមតិគួរបើត្រកង កូនសូន្យមតិលាន១ដងពុំស្មើក៏ កូនកបមតិ
តែង១ឲ្យសុខា កូនសូន្យមតិគ្មាតែន១ឲ្យពោសព្យសន៍ ។

ឧត្តា[1] ឧទី អនោទកា ឧត្តំ រដ្ឋំ អភាជិកំ
ឥត្ថីបិ វិឆវា ឧត្តរ យស្សឆាយំ ឧបេ ភាតរោ ។

ទន្ទេស្តេងឥតទឹកពុតជាស្រែត រដ្ឋឥតស្តេចបាត់ជារដ្ឋមេម៉ាយ ស្ត្រី
វិឆវាភាតាជាប់ថ្នាំយ តន់លោនម៉ាយថាជាកំព្រាសុទ្ធ ។

បភោសតំ វេបិ សមាភតានំ
ឈាយេយ្យ តេ វស្សសតំ អបញ្ញា
ឯកោវ សេយ្យោ ឃុរិសោ សបញ្ញោ
យោ ភាសិតស្ស វិជានាតិ អត្ថំ ។

ជនអ័ប្យត្រែចាប្រាជ្ញប្រែនពប់រយពាន់ ប្រជុំគ្នារគ្នាន់ដោះអាថិប្រស្នា
អស់សតវត្សត្រែតបានតាវ៉ា ហេតុតែមោហាដួចបសុសត្វ ។ រីជនតែម្នាក់
កបញ្ញាណបញ្ញា តាបដោះប្រស្នាតត្តបរមត្ថ ដឹងពាក្យសួរសៀត
តាបឆ្លើតឆ្លើយតាត់ ប្រសើរលើសក្តាត់បរិស័ទ្យគាល ។ (អាទត)

---

๑ ឧត្តា - សំដៅខេះ ប្រែបានច្រែនយ៉ាងថា, ត្រូងិល, ថ្មុយ, រនល, ស្រែត, ស្រែតរនល
អាក្រែត, ទទេ, មិនដាប់នៅ . . . ។



ទស្សនាវដ្តី ស្រាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនចក្កវិត្ត

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនចក្កវិត្ត

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវិន្ទញ្ញាណ សួរ - ហាយ
ក្រុមដំបូន្តែរតែមិនឯក នៅពុទ្ធសាសនចក្កវិត្ត

មាតិកា

ផ្នែកអក្សរសាស្ត្រ		ទំព័រ
ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម	សេចក្តីផ្តើមនិងដំណឹងអំពីកម្ពុជសុរិយោដ្ឋាន ១៩៤៨	៦១៧
លោក ភ័ឃ - ប៊ុក សម្ដេចបញ្ជីធំ នៅពុទ្ធសាសនចក្កវិត្ត	វិរៈបុរសពីរអ្នចទ្វីបអាស៊ី (តទៅនិងចប់) . . .	៦២១
ឃុនសុន្ទរមេធី ហ្លួង - សើង	ឯកសារហិរញ្ញវត្ថុ ភាគទី ១៤ (តទៅ)	៦៣៦
ឃុនសុវត្ថិវេទី ឃួ - អ៊ុន	រឿងព្រៃងខ្មែរ "រឿងតេឡាសំណាង" . . .	៦៤៦
ផ្នែកសាសនា		
ព្រះគ្រូបញ្ញាលង្កិត កៅ - សំម		
ត្រូចង្រៀនសាលាជាលីជាន់ខ្ពស់	អំពីការបិទទ្វារបស់សិស្សសាលាជាលីជាន់ខ្ពស់	៦៥៦
លោកមហា សៅ - លី	សុភាសិតនិងការកោតទ (តទៅ)	៦៦៧

ឆ្នាំទី ១៩ — លេខ ១២ ខែធ្នូ (ជេសឋបាទ) ឆ្នាំ ១៩៤៧ — ដំឡៃជាវ ១ ឆ្នាំ ៣៥ រៀល



ជូនពរសព្ទសាធុការ

គ.ស ១៩៤៨

ឆ្នាំចាស់ (គ.ស. ១៩៤៧)

កន្លងផុតទៅ ឆ្នាំប៉ី (គ.ស. ១៩៤៨) ចូលមក
ក្រអប់កាលានុកាល តាមជំណើរសុរិយគតិវិធ
ឬតាមសម័យលោកនិយម ។ ដូច្នេះ ចាប់តាំង
អំពីថ្ងៃ ១ ខែមករា (ឃ្លាំងវិយេរ) គ.ស. ១៩៤៨
ជាឱកាសចូលឆ្នាំប៉ី ពុទ្ធសាសនបណ្ឌិត្យកម្ពុជរដ្ឋ
សូមជូនពរសព្ទសាធុការ ដល់ពុទ្ធសាសនិកជន
ជាតិខ្មែរទូទៅ សូមឱ្យបានប្រកបដោយពរជ័ប្រសើរ
៤ ប្រការ គឺ: អាយុ វណ្ណៈ សុខៈ ពលៈ គ្រប់ទំរា
រាត្រីកុំបីឃ្លាតឡើយ ។

គ.ស. មួយពាន់ប្រាំ - ប្លុងយោសេសឆ្នាំ
សែសប់ប្រាំប៉ី សូមបងប្អូនខ្មែរ កែតំនែតថ្មី
សូមមានសិរី សូស្តីផយោ !!! ។

សេចក្តីថ្លែងដំណឹង

អំពីកម្ពុជសុរិយា ឆ្នាំ ១៩៨៩ ព.ស. ២៤៨០

ពុទ្ធសាសនបណ្ឌិត្យ សូមជូនដំណឹងដល់លោក-អ្នក ជាទេស្សនាវដ្តី «កម្ពុជសុរិយា» ទាំងឡាយ សូមជ្រាប ។

កម្ពុជសុរិយាឆ្នាំទី ១៩ ក្នុងគ. ស. ១៩៤៧ បានបោះពុម្ពផ្សាយតាំងពីលេខ ១ ដល់ ១២ គ្រប់ភ័ណ្ឌ ១ ឆ្នាំហើយ។ ក្នុងឆ្នាំ ១៩៤៨ គរប់ឆ្នាំទី ២០ កម្ពុជសុរិយានៅតែបោះពុម្ពផ្សាយរាល់ខែតទៅទៀត ទើបសូមជូនដំណឹងដល់បងប្អូនរួមជាតិ ដែលស្នេហ៍ជាតិកម្ពុជសុរិយា ក្នុងឆ្នាំ ១៩៤៨ ដើម្បីឲ្យបានជ្រាបរបៀបនឹងរឿងរ៉ាវប្រការខ្លះ ដែលយើងប្រុងនឹងនាំយកមកបុះផ្សាយ ក្នុងកម្ពុជសុរិយាឆ្នាំថ្មីនេះ

ផ្នែកគតិលោក

១ – ប្រវត្តិសាស្ត្ររបស់នានាប្រទេស ចាប់ផ្តើមតាំងពីប្រទេសចិន, ឥណ្ឌៀជាដើមទៅ ។

២ – ភូមិសាស្ត្រសាកល គឺភូមិសាស្ត្ររបស់ពិភពលោកទាំងមូល ។

๓ – រឿងឯកសរហស្រ្តាត្រី ឬរឿង ๑ ពាន់ ๑ យប់ នៅមានបុះផ្សាយជាលំដាប់ៗ តទៅទៀត ។

๔ – ពាក្យកាព្យផ្សេងៗ ដែលមានប្រយោជន៍ដល់អក្សរសាស្ត្ររបស់ជាតិ ។

๕ – រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់ជាតិដទៃ ។

๖ – សុភាសិតផ្សេងៗ ព្រមទាំងសេចក្តីអធិប្បាយ ។ល។

ផ្នែកគតិធម៌

๑ – យើងនឹងបុះផ្សាយរឿង «ប្រទីបទ្វីបអាស៊ី» ដែលយើងប្រែចេញពីភាសាតាងប្រទេស ជារឿងដំណាលពីព្រះពុទ្ធប្បវត្តិនិងពុទ្ធចរិយាយ៉ាងពីពោះ ។

๒ – យើងនឹងស្រង់ប្រែរឿងរ៉ាវគតិធម៌ ពីគម្ពីរបាលី ឬពីភាសាដទៃ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនទាំងគ្រហស្ថ ទាំងបព្វជិត ។

๓ – នឹងបុះផ្សាយដំណឹងសំខាន់ៗ ក្នុងសាសនា ។

๔ – ព្រះពុទ្ធភាសិត ឬព្រះពុទ្ធដីកា ដែលបារកទុកក្នុងគម្ពីរបាលី នឹងដកស្រង់មកប្រែស្រាយអធិប្បាយសេចក្តី ទុក

ជាសណ្តាប់ធ្នាប់ល្អ ដែលត្រូវការសិក្សានិង
ប្រតិបត្តិតាមប្បាប់ពុទ្ធសាសនា ។ ល ។

កម្ពុជសុរិយាឆ្នាំថ្មីនេះ យើងនឹងបោះពុម្ពដោយក្រដាសសដូចលេខ ១០ ១១-១២ ក្នុងឆ្នាំមុននេះ ហើយយើងនឹងបំពេញបំនួនទំព័រដល់ ៨០ ទំព័រយ៉ាងតិច ក្នុងសៀវភៅនីមួយៗ រួម ១២ ក្បាលដូចឆ្នាំមុនដដែល ។ ឯដំឡៃជារៀងក្នុងឆ្នាំ ១៩៤៨ ជាដំឡៃ ៦៨ រៀលក្នុង ១ ឆ្នាំ ដំឡៃជាវិញនេះឡើងដូច្នេះ ព្រោះយើងបង្កើនបំនួនទំព័រឡើងច្រើន ថែមទាំងប្រើក្រដាសល្អថែមទៀតផង ។ អស់លោកបានជ្រាបស្រាប់ហើយថា វត្ថុសព្វសារពើឡើងថ្លៃជានិច្ច សូម្បីតែប្រដាប់ប្រដាសំរាប់បោះពុម្ព ក៏ឡើងថ្លៃជាអនេក ។ ហេតុនេះ យើងសូមអង្វរបិត្តបងប្អូនរួមជាតិទាំងឡាយ ឲ្យជួយជ្រោមជ្រែងអក្សរសាស្ត្ររបស់ជាតិ នឹងបំណោះវិជ្ជារបស់ខេមរជាតិឲ្យបំពេញឡើងទាន់កាលសម័យដូចនានាប្រទេសឡើង ។

សូមបងប្អូនរួមជាតិទូទៅទទួលមេត្រីភាពអានដោយស្មោះត្រង់អំពីពុទ្ធសាសនបណ្ឌិត្យ ។

លោក រ៉ាយ-ប៊ុក

ចាត់ស្រង់ប្រែពីទស្សនាវដ្តីបារាំង Extrême-Asie ខែធ្នូសម្រាប់ ១៩២៤
និងខែមករាឆ្នាំ ១៩២៥

(តទៅទំព័រក្រោយ)

ផ្នែកសាលាមានសិទ្ធិចាត់តាំងបន្ទប់បញ្ជាក្តីបាន លុះត្រាតែផ្នែកតុលាការបានអនុញ្ញាតយល់ព្រមជាមុន ផ្នែកសាលាបញ្ជូនក្តីបាន លុះត្រាតែផ្នែកតុលាការយល់ព្រមប្តឹងមិនយល់ព្រម, ក្នុងករណីសម្រាប់ផ្នែកសាលារៀបចំថវិកាប្រចាំឆ្នាំ មានសិទ្ធិយល់ព្រមប្តឹងមិនយល់ព្រម ប៉ុន្តែផ្នែកតុលាការនៅតែមានសិទ្ធិខ្ពស់ជាងជានិច្ច ។ ថវិកានេះសោតទៀត ដែលផ្នែកសាលាមានអំណាចគ្រប់គ្រងបានប្រហែល ១ ក្នុង ៣ ភាគប៉ុណ្ណោះ តើសុខាភិបាល (Hygiène) សិក្សាធិការ និងមុខការដទៃទៀតដែលពុំសូវមានប្រយោជន៍ ។ ឯទាំងផ្នែកនយោបាយ, វរណៈបាយ, យុត្តិធម៌, ឧត្តរបាល, ពន្ធដែលគេហៅថា ការត្រួតពិនិត្យ (affaires réservées) នោះផ្នែកសាលាគ្មានសិទ្ធិគ្រប់គ្រងបានទេ ។

ចំណែកករណីយកិច្ចដែលយល់ព្រមឬមិនយល់ព្រមនៅលើផ្នែកឧត្តរបាលនោះ ។ ឯការញែកចែកមុខការនិងសមត្ថភាពរបស់ផ្នែកសាលាទៅជាអសារឥតការ ។ ផ្នែកសាលាទៅជាត្រឹងយន្តមួយមានតែសំដី

ពោល (Machine à discours) ឬជាប្រអប់សម្រាប់ដាក់គ្នាលេង ដែលជាហេតុឲ្យគេពោមនស្សនឹងកំពូតារ មិនអាចតវ៉ាអ្វីបាន ។ របៀបកែប្រែរបបសំលោកម៉ុងតាគុយ មានបញ្ហូលគតិព័រយ៉ាង ដែលនាំឲ្យសម្ដេចសង្ឃជាអធិបតីគ្រួស កាន់តែមានដង្ហិតលខ្លាំង ។

មិនប៉ុន្មានប៉ុណ្ណោះ ប្រជាជនឥណ្ឌាបានសន្យាដោយស្មោះត្រង់ថានឹងចំពេញការណាមួយតិច ដើម្បីធ្វើឲ្យរបៀបតែប្រែនោះប្រព្រឹត្តទៅបានដូចចំណង់ ។ ស្រាប់តែក្នុងពេលនោះ មានប្រព្រឹត្តិការណ៍ពីរយ៉ាងកើតឡើង ដែលនាំឲ្យប្រជាជនលែងខ្វល់ចិត្តរដ្ឋាភិបាលរបស់លោកទេ-ភាឥណ្ឌា) គឺមួយហ្នឹងដែលហៅថារូស្សឡាតអាក់ (ROSLAT ACT) កំពត់បំបាត់សេរីភាពត្រង់ជំពូកក្នុង គ. ស. ១៨១៩ ។ មួយយ៉ាងទៀតការរំលំជាតិខ្ពើ ។ សិទ្ធិដែលប្រគល់ឲ្យប្រជាជនដែលស្លាំ ស្រាប់តែដៃផ្ទេងជណ្ដើមយកៈទៅវិញ ថែមទាំងមានការចាញ់បោកដោយខ្សែតទៀតគឺយោគកម្មដែលលោកទ្រូមសេនីឌីយ៉ែបានធ្វើទៅស្រុកអម្រឹតសារ ។

អធិការណ៍ទាំងនេះ នាំឲ្យកើតចលាចលឡើង ដល់ប្រជាជាតិបាណ្ឌូទាំងមូល ។ លោកមហាត្មគន្ធីស៊ុំឲ្យដួសជុលសេចក្ដីអយុត្តិធម៌ដែលរដ្ឋាភិបាលបានធ្វើចំពោះប្រជាជន ។ ប៉ែនទេសឥណ្ឌាទាំងមូលកើតចលាចលឡើងគ្រប់ទីគ្រប់ចន្លោះ ហើយស្រុះស្រួលសុទ្ធចិត្តយកលោកធ្វើជាមគ្គុទ្ទេសក៍ ធ្វើជាអ្នកនាំផ្លូវ ទើបប្រគល់អំណាចឲ្យលោកគាន់

កាប់ ដោយមានជំនឿជឿជាក់ចំពោះរូបលោត ។ ហេតុដូច្នេះបាន ជាលោតប្តីឆ្កាងការជាច់ខាតដល់មហាឧបាសក កាលពីថ្ងៃ ៩ ហ្វេវ្រីយេ ៤២៦ ទ្បើកំណាត់ ៨ ថ្ងៃ ដើម្បីទ្បើរជ្ញាកិច្ចាលបោះបង់គំនិតដែលជាក់ទ្បើ រុលាការជំនុំជំរះពួកបះបោរ នឹងការបំពេញឆន្ទៈរបស់ប្រជាជាតិ បើមិនដូច្នោះទេ នឹងកើតសង្គ្រាមពលរដ្ឋទ្បើងនៅក្នុងស្រុកមិនខាន ។

តាមមតិរបស់ពួកបស្ចិមប្រទេសនោះ គេយល់ថាប្រទេសដែលមានពលរដ្ឋដល់ ៧០០,០០០,០០០ នាក់ បង់ធ្លាប់ជាវត្តន៍កុំឲ្យមានឈាម ១ តំណក់ស្រក់ជាដាច់ខាតជាការលំបាកពន់ពេកណាស់ ពួកជាតិខ្លះអ៊ីរុបជ្ញាប់ប្រើកំឡាំង ហើយយកកំឡាំងជាប្រធានក្នុងកិច្ចការទាំងពួង ។ តែដោយពិតនោះ ប្រទេសឥណ្ឌូចិនធ្លាប់ជាវត្តន៍យ៉ាងសំបើមអស្ចារ្យ ឥតមានមនុស្សស្លាប់ឡើយ ។ ប្រជាជនបានស្រុះស្រួលធ្វើតាមដំបូន្មានរបស់លោកមុនីនយោបាយ (Saint Politique) ប៉ុន្តែប្រជាជនដែលមានពួកក្រមនតបាលនៅសៅរីសារ៉ៅ (Schauri Scharau) ធ្លាប់ជ្ញាំងឥតព្រំបាន ។ លោកគន្ធីក៏បានជួយផ្សះផ្សារឿងនោះដោយប្រាជ្ញាយោបល់ក៏ងវៃ ដើម្បីកំចាត់ការបលាចលនោះចេញ ។ កិច្ចដែលលោកគន្ធីធ្វើនេះ មានពួកខ្លះដែលមិនបានយល់ហេតុបញ្ជាស់ស្មានថា លោកកាន់ចរិយាទន់ខ្សោយទៅវិញ តែលោកប្រកាន់ថា មិនត្រូវប្រកាន់ប្តីធ្វើនយោបាយដោយការឈ្លោះទាស់ទែងគ្នា, ដោយប្រើកំឡាំង

ម្តងដោយខាងណាក៏ម្តង តែត្រូវធ្វើតាមនោលការដោយសប្បុរស, ដោយធម៌ ដោយសុចរិតនឹងដោយកិរិយាថ្លៃថ្នូរ ពីព្រោះតាមមតិលោកគន្ធីខាង, បើនយោបាយណាធ្វើតាមនោលការខាងលើនេះ ប្រាថ្នាសម្រេចដូចបំណង ផលដែលបានពីពួលខាង នឹងតែតែចំរើនវិសេសស្ថិតស្ថេរបានកាលតទៅ ។

សព្វថ្ងៃនេះតមក ក្នុងថ្ងៃ ១០ ខែមីរ៉ាឆ្នាំ ១៩២២ ឆ្លៀតបានលោកគន្ធី តាត់ទោសដាក់គុក ៦ ឆ្នាំ ។ នេះជាអំណាចកិច្ចក្នុងថ្នាក់ទី ១ នៃរឿងក៏ដូច ក្នុងដីដែលត្រូវចំលោកគន្ធី ដែលជាមេតំនិតដ៏វិសេស ។

លោកគន្ធី ដែលត្រូវជាប់ឃុំ ធ្វើឲ្យប្រជាជនមានចិត្តស្រងូតស្រងាត់ជាម្តងជាខ្លាំង ប្រជាជនខាំគ្នាខ្លះស្ងៀមស្ងាត់ឥតធ្វើការចលចលអ្វីឡើយ ។ ខ្លះទៀតសំដែលមានការយោសា មិនឲ្យប្រជាពស្ត្រសេពគប់ជាមួយនឹងភ្នាក់ចាស លោកគន្ធីក៏បានពួនាខប្រដៅប្រជាជនមិនឲ្យប្រកាន់យកសកម្ម កុំឲ្យតវ៉ាក្តីដែលមានសំណុំរឿងមៅសាលាតង់ត្រូស, កុំឲ្យប្តឹងប្តល់គ្នាឡើយ ឲ្យលែងក្តើសមាជិកសភាដំណាងឯកស្ត្រ, កុំឲ្យបញ្ជូនកូនចៅរៀនក្នុងសាលារៀនរដ្ឋចាស ហើយត្រូវនិយមប្រើតែសំពត់ដែលពលរដ្ឋគ្បាញអាយប៉ុណ្ណោះ ។ នយោបាយបែបនេះប្រសើរណាស់ តែគួរឲ្យស្តាយតំនិតនេះណាស់ ដ្បិតឥតនណាធ្វើតាមទៀត

ក្នុងខណៈដែលលោកគន្ធីជាប់ឃុំ ។ មានកើតគណបក្សម្ខ័យថ្មី មាន
លោក ជ.រ. ដាស (D.R.Das) ជានាយកគណបក្ស, បណ្ឌិតមូតិ
ឡាល់នេហ៊ូ (Moti Lal Néhru) ជាលេខាធិការ ។ គណបក្ស
នេះហៅថា គណបក្ស «ស្វ័យភាព» ។ នៅសកាសន្និបាតសម័យ
នោះ មានស្ថាបតីតើស្ថាបមួយ ភាគពួតដែលមិនចូលចិត្តកែប្រែច្បាប់
(les non - réformistes) ទំនងពួកចូលចិត្តភាគខាងកែប្រែច្បាប់ចាំងមួល
មិនត្រមះបះរួមនឹងគណៈរដ្ឋាភិបាល (Radicaux de Ia non - coopération)
ស្ថាបមួយទៀត គឺគណបក្សអ្នកចូលចិត្តកែប្រែច្បាប់ឬគណបក្ស «ស្វ័យ-
ភាព» (Réformistes ou Swarajiste) ។ គណបក្សថ្មីនេះ ឥត
មានបេតនាទំនងកែប្រែច្បាប់ឡើយ តែមានចំណងទំនងបង្កើរដ្ឋាភិបាលឲ្យ
ចុះបង់ក្បួនបុកណាលទ្វិសម្បូណាជ្រាសិទ្ធិពលឲ្យត្រឡប់ទៅជាស្វ័យភាព
វិញប៉ុណ្ណោះ ។

វិធីដែលពួកនេះបានផ្តើមឡើង គឺធ្វើមិនឲ្យដំណាងក្រសួងក្នុងរដ្ឋសភា
ជជែកកិច្ចការអ្វីបាន ហើយនយោបាយពួកនេះ គឺធ្វើឲ្យត្រឿងបក
នៃរដ្ឋាភិបាលឈប់ស្រួមឥតកំណើតក្នុងខែត្រចង់កាល់ ទីចរត្តកណ្តាល
ដែលគណបក្សពួកនេះមានចំនួនច្រើន; កិច្ចការដែលធ្វើចាំងប៉ុន្មានបាន
សម្រេចប្រយោជន៍ជាបង់តួ ។ រដ្ឋសភាខេត្ត (parlements provinciaux)
ខ្លះត្រូវបិទទ្វារចោលមិនធ្វើការ ហើយរឿងកំរែដែលរដ្ឋសភាត្រូវពិនិត្យ

នោះសឹងសម្រែចទៅតាមក្រែគ្រ ក្នុងសភានីតិបញ្ញត្តិ (Assemenblée législative) ។ ពីឆ្នាំមុន ពួកស្វ័យភាជ្យ មានចំនួនតិចជាងបងស្ថាន មេត្រី ទំងពួកឯករាជ្យ (Indépendant) ហើយគ្នាយៅជា «គណៈបក្សជាតិនិយម» (Pacte Nationaliste) ។ គណៈបក្សនេះ ជាងបងសោធ ថវិកាប្រចាំឆ្នាំពីខែមីរាមុន ទាល់តែឡរ៍តរូអាឌីង (Lord Ruading) សម្រែចពុំព្រមតមុតិ ។ នៅពេលនោះ ពួកនេះជាងបោះឆ្នោតយោង តាមការចែង សម្រែចឲ្យប្រើរបៀបពីរយ៉ាង គឺ ១ - តាំងឲ្យបង្កើតឲ្យមានរដ្ឋបាលប្រកបដោយរដ្ឋសភាមួយរំពេច (Gouvernement parlementaire) រដ្ឋសភានេះ ក្នុងសម័យប្រជុំហាមមិនឲ្យដាច់ អំពីរឿងនយោបាយ. រាណាជ្ញ, ហើយឲ្យមានស្វ័យភាជ្យប្រចាំការខេត្តផង ។ ๒ - សូមឲ្យដោះលែងលោកគន្ធីជាប្រញាប់ ។

រឿងនេះកើតឡើងមុន គណៈបក្សកម្មករ (Travailliste) កាន់តាប់ការពារជាមុនក្រសួងខាងប្រទេសអង់គ្លេស ។ ដល់លោកម៉ាក់ - ដូណាលដ៍ (Mac-Domald) ឡើងកាន់តាប់ការ ក្រសួងមហាឧបាជ្ញ អំណ្លៃ ក្រែវាការបន្ទរបន្ទាយឲ្យដោះលែងលោកគន្ធី សឿរតែដែលលោក រ៉ូម៉ាំងរ៉ូឡង់ជានរៀបរឿងពីរឿងលោកគន្ធី មានសេចក្តីពណ៌នាដោយ ច្បាស់លាស់បំភ្លឺរជ្ជកិច្ចលាល់តែគេដោះលែងរដ្ឋបុរសនេះទៅ ។ តាមដោយពិត មានគណកម្មការស៊ើបសួរពិនិត្យទៅសឹមឡា តែបំណងរបស់

តម្លៃការនេះមិនមែនធ្លើសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ពិនិត្យវិធីការដែលគេបានអនុញ្ញាត ឲ្យប្រទេសឥណ្ឌៀថៅជា «ស្វ័យភាព» នោះទេ ។ តណៈដែលតាំងឡើងនេះ មានបំណងនឹងតាំកែប្រែកន្លងក្នុងកន្លងសម័យបច្ចុប្បន្ន តំនិត នេះធ្វើឲ្យចិត្តពួកគណៈជាតិនិយមការកែស្ទាក់ស្ទើរដោយយល់ថា គណៈកម្មការថែបនេះបានតាំងឡើង ដើម្បីជាកិច្ចបោកបញ្ឆោតប្រជាជនស្តួនឯងពួកក្រុម ។ ប៉ុន្តែពួក "ស្វ័យភាព" បានសម្រេចថាខឹងធ្វើនយោបាយតទៅទៀត ៣ លំតែបានសម្រេចខ្លួសុភផល ។ ពិតមែនតែចិត្តពួកនេះជាការចេញពីលោភគន្ធ ចំពោះស្ថានការណ៍ផ្សេង ។ ពួកស្វ័យភាពនេះបានបើកក្លែកក្រឡែកមើល មកចំលោកហើយមានសង្ឃឹមមាំមកលើលោក ដោយយល់ថារបៀបយោបល់មិនចូលរួមរួមខឹងផ្តាកិច្ចការ (Non-Copération) ហើយកិច្ចដែលមិនតបតចំពោះរដ្ឋាភិបាល (Non-résistance) ជាហេតុនាំឲ្យពួកនេះមានភាគច្រើនខាងរដ្ឋសភា (Parlément) ខឹងខាងក្រុមប្រឹក្សាខេត្ត (Conseils proviciaux) ។

ពួកស្វ័យភាពនេះ មិនមែនតក់ស្លុតដោយពាក្យកំហែងតម្រាម ឬដោយការបះពាជ័យ ក៏ឥតអង្គឹមានសោះ ដូចជាការខាស់ខែងចលាចលរវាងពួកហិណ្ឌូនឹងមហាហ្មត ដែលជាហេតុនាំឲ្យលោកគន្ធីអត់អាហារអស់រវាង ២១ ថ្ងៃ ។ ពួកនេះយល់ថា ហេតុវិវាទកើតមកពីអង់គ្លេសចាក់រុកដើម្បីបញ្ឆាក់ឲ្យសកលលោកយល់ថា ពួកឥណ្ឌៀមិនទាន់មានគំនិតល្អម

ត្រួតត្រាខ្លួនឯងបានទេ ហើយដើម្បីបញ្ចាក់ដល់ប្រជាពលរដ្ឋឲ្យឃើញថា មានវត្តមានរៀបរាល់កិច្ចការបច្ចុប្បន្ន នៅត្រាមសិទ្ធិគាត្តិនេះហើយ ដែលនាំប្រទេសទៅជាន់សេចក្តីចំរើនបាន ។

សេចក្តីប្រកាសឃោសនា របស់ពួកស្វ័យជញ្ជូសស្ងួតខ្លួនទៅតែប់តំបន់ក្នុងប្រទេស ពួកប្រជាជនពុំឮលភាពដែលធ្លាប់តែឮលឮអូសក៏បានក្លាក់ខ្លួនក្រវើតក្រតើនឡើង ដោយសារសេចក្តីខ្នះខ្នែងជួយតទល់បំភ្លឺរបស់លោកតន្ទី ។ លោកតន្ទីបានសម្រេចថា ទំនិរំលុបអណ្តូងដែលជីកនៅឯណាលស្ងាចទាំងពីរនៃមហាសន្និបាត (Congrès) ចោលចេញហើយបានរៀបចំកម្មវិធីឲ្យមានសម្ពន្ធមិត្តហ៊ិណ្ឌូមហាហ៊ីតឡើង ដែលមានគោលសំខាន់ គឺហាមឃាត់មិនឲ្យសំពត់នានាប្រទេសចូលមកលក់ក្នុងប្រទេសវណ្ណៀ ទំនិការបំបាត់មិនឲ្យមានត្រកួលខ្ពស់ទាប ។ ឯគោលឯទៀតៗក្នុងកម្មវិធីត្រូវបង្ក្នំទៅថ្ងៃក្រោយសិន ដើម្បីទំនិធ្វើហេតុឈ្មោះនោះឲ្យប្រញាស្ទើរព្រាងឡើង ។ អនាគតនៃមហាសន្និបាត (Congrès) ទំនិធ្វើនៅស្រុកបេលកូន បើនសម័យប្រជុំជាថ្មីមានលោកតន្ទីជាប្រធាន ហើយត្រូវសម្រេចតាមផ្លូវនយោបាយណាដែលនាំឲ្យប្រទេសជាតិមានដំណើរដើរទៅជាន់សេចក្តីចំរើន ។

នេះហើយ គឺប្រវត្តិនិងរឿងខ្លះនៃការផ្តួមតាំងស្ងួយជញ្ជូនៅប្រទេសវណ្ណៀ ដែលខ្ញុំបានពោលមកដោយសង្ខេបនេះ ។ ឥឡូវយើងនិងនិ

ចាប់ពណិនាអំពីផលវិជ្ជ ដែលផ្តើមកើតឡើងពីហេតុបោះផ្លោតរបស់
អង់គ្លេស ក្នុងស្ថានភាពប្រទេសឥណ្ឌាបច្ចុប្បន្ននេះ ។

«នៅប្រទេសឥណ្ឌា មានស្ថានការណ៍មួយយ៉ាងដែលជាហេតុនាំ
ឲ្យប្រទេសអង់គ្លេសកាន់តែ ប្រើឃ្លុងវិធី ដើម្បីប្រមូលសិទ្ធិអំណាចឲ្យមកនៅ
ក្នុងកណ្តាប់ដៃរបស់ខ្លួន» ។ ពាក្យនេះគឺលោកឡត តុរសុង (Lord
Curzon) បាននិយាយ ធ្វើឲ្យប្រជាជនមានសេចក្តីជឿជាក់ច្រើន ក្នុង
ពេលបោះផ្លោត, បើតាមយោបល់, បំណងលោកនេះ នឹងរំលំ
រដ្ឋាភិបាលកម្ពុជាបេញ ។ នេះជាហេតុដំបូងបង្អស់ ដែលគេបាន
ឃើញថា រដ្ឋបុរស (Homme d'Etat) មានឋានន្តរៈដូចជាលោកឡត
តុរសុងបាននិយាយដោយចិត្តស្មោះត្រង់ ឥតលាក់ញាក់ញ៉ីតនឹងឃាតក់ខន
ដែលព្រះមហាក្សត្រយ៉ាអង់គ្លេស នឹងប្រទេសឥណ្ឌាឡើយ ។

នៅប្រទេសចក្រពត្តិសៃស យើងបានយល់ឃ្លាងអំពីការប្រែប្រួល
នៅប្រទេសឥណ្ឌាហើយ យើងពុំបានឃើញដោយច្បាស់លាស់ ចំពោះ
ពួកគណជាតិនិយម ដែលបានធ្វើកិច្ចការខាងនយោបាយតាំងពី ឆ.ស.
១៩១៤ តើប្រទេសឥណ្ឌាបានបម្រើនឡើងដូចម្តេចខ្លះ ? — ខ្ញុំនឹង
និយាយអំពីដំណើរប្រែប្រួលឲ្យឃើញពិតច្បាស់ ហើយនឹងបញ្ជាក់នៅ
ខាងមុខ ។

ស្ថានការណ៍នៅប្រទេសឥណ្ឌូ ក៏ដូចជាស្ថានការណ៍នៅប្រទេសអេស៊ុប្ត៍ដែរ ។ ប្រសិនបើប្រទេសអង់គ្លេសបានត្រួតត្រាប្រទេសអេស៊ុប្ត៍ ទឹងឥណ្ឌូតាមបែបពួកម៉ាមីលុក (មហាក្សត្រិយ៍អេស៊ុប្ត៍) ឬពួកមហាមួតុល (មហាក្សត្រិយ៍មន) ប្រហែលជាប្រទេសអង់គ្លេសនៅតែធ្វើជានាយទៅហ្មាយ គ្មានតង្វល់រវល់អ្វីឡើយ រហូតមកដល់សម័យសព្វថ្ងៃនេះ ។ ប៉ុន្តែកិច្ចដែលអង់គ្លេសទំនុះខ្នែង ដើម្បីនឹងបានជាជាតំបន់នោះ ឲ្យចូលទៅក្នុងចំណោមអារ្យធម៌ចម្រុងប្រទេស នាំបង្កើតឲ្យមានជាពួកក្រុមឡើង ដែលសព្វថ្ងៃទៅជាបច្ចាមិត្តយ៉ាងសំបើមគ្មានទុសថអ្វីយកមកកែកាន់ឡើយ ។

គួរយល់ឃើញថា តាមដំណើរឿងកំរដែលបានមក, សិទ្ធដែលបានប្រគល់ឲ្យទៅប្រទេសពាំងពីរ មិនដែលបានពេញចិត្តប្រជាពលរដ្ឋទេ ហើយសិទ្ធិណាថ្មី ដែលរដ្ឋាភិបាលអង់គ្លេសបានអនុញ្ញាតឲ្យ នោះរឹតតែនាំឲ្យប្រជាពលរដ្ឋកាន់តែចិនវែចមែងភាំយ៉ាងម្ដងម៉ាត់ ពាល់តែកង់អាសោន ហ៊ានដល់ទៅតយុទ្ធដើម្បីតាមការយកស្វ័យភាព ។

យើងមិនបានយល់ដោយស្មានៗថា ពួកពលរដ្ឋនៅប្រទេសឥណ្ឌូនៅស្លន់ស្លៀកពិតមែន ប៉ុន្តែខ្លះនិយាយភាសាអង់គ្លេសបានពេញលេញល្អ ហើយមានខ្លះទៀតបានសិក្សារៀនសូត្រតាមរបៀបបស្ចិមប្រទេស ។ ចំពោះពួកត្រួតត្រាឲ្យ, មេធាវី, មេនយោបាយ, អ្នកសារសេរសៀវភៅ,

ពួកនេះ បើពុតជាបានធ្វើតាមក្រែសួងអ្វីនិមួយហើយ ក៏គង់មានបន្ទា
១ ដុះជាប់កន្ទិចិត្តជានិច្ចថា ក្រែសួងណាខ្ពស់ៗគេទុកឲ្យតែជាតិអង់គ្លេស
មិនព្រមឲ្យយើងចូលទៅរួបរួមជាមួយផងទេ ។ នេះហើយជាដើម
ហេតុ ១ ដែលនាំឲ្យពួកមេគណជាកិនិយមខាងឡាយចាប់ដៃគ្នាទៅវិញ
ទៅមក រួបរួមសាមគ្គីយ៉ាងមាំមួនបាន ។

មានតួក់ជាតិអង់គ្លេសជាច្រើនយល់ថា អំណោយស្វ័យភាពក្នុង
ព្រះពុទ្ធសាសនេះ ចាំតែពេលវេលានឹងបាត់ការប៉ុណ្ណោះទេ ។ ប៉ុន្តែ
មានតែតឿងឿងដូចនៅប្រទេសអៀរឡង់ ក៏បំរែនឹងសម្រែចដូចបំណង
ហើយ ស្រាប់តែរដ្ឋាភិបាលអង់គ្លេសគណៈវក្យាសណ្តាប់ធ្នាប់ចេស់ជាតិ
(Gouvernement Conservateur) បានឡើងកាន់កាប់ការងារ តាំងរំលែងនឹង
មិនឲ្យការនោះបានសម្រែចដោយងាយក៏មាន ។

ឥឡូវនេះ ឡរ៍តគ្រុសុង់បានចំកំហែងគ្រាមពលរដ្ឋឥណ្ឌា ដោយ
ប្រើកំឡាំងកងទ័ពកំឡាំងការពារ ប្រទេសអង់គ្លេសនឹកសង្ឃឹមថា មុខ
ជានឹងមានជោគជ័យក្នុងស្ថានការណ៍នេះ ដូចជាកាលបលោបលព័ន្ធ
១៨៥៧ - ៥៨ ប៉ុន្តែបើពុតជាប្រជាពលរដ្ឋឥណ្ឌាព្រមចុះចាញ់ក៏ដោយ
ក៏រដ្ឋាភិបាលអង់គ្លេសត្រូវតែប្រគល់ស្វ័យភាពឲ្យដែរ ដោយហេតុពួក នេះ
បង្ខំតាមការយ៉ាងតឹងតែងណាស់ ។ យើងបានយល់ឃើញហេតុការណ៍
នេះ ប្រហែលនឹងហេតុគេទៅតាណាតិមកាប្រកាន់ក្បួនខ្នាតនោះដែរ

កាលគ្រាយោចចាំងបូអែរ (Boërs) ។ អារ្យធម៌អឺរុបបានចូលមកកាន់ប្រទេសអាហ្វ្រិក ក្នុងបច្ចុប្បន្នកាល មានក្រមក្រសួងខ្លះចាត់យកតម្រាប់តាមអឺរុប ដូចជាក្រសួងនមនានម ។ សាហាកម្ម, ពាណិជ្ជកម្ម ហ៊ាយក្នុងក្រសួងនេះមានពួកប្រជាជាតិបានបូលធ្វើការជាច្រើន ។ ការតបកម្លៃចំណូលដោយសន្ធិវិធី ពុតដូចជាការតម្រាមមួយដែលនាំឲ្យមានគ្រោះថ្នាក់ដល់អង់គ្លេស ជាដើមការផ្ទុះចេញនូវការបះបោរលើកក្នុងស្រុកទៅវិញ ។

ដោយហេតុពួកពលរដ្ឋអង់គ្លេស មានចរិយានយោបាយប្រកបដោយសេចក្តីសុខរួត យើងយល់ឃើញថា គណរដ្ឋមន្ត្រី គណៈរក្សាសណ្តាប់ធ្នាប់ចេស់ជាតិក្តី គណៈសេរីភាពក្តី កម្មករក្តី ក៏មិនមានវិធីអ្វីផ្សេងគ្នាខ្លាំងពោះរឿងវ៉ាវប្រទេសអាហ្វ្រិក ។ ប៉ុន្តែគេតែងពោលជាញឹកញាយថា មូលដ្ឋានយោបាយដ៏ធំសេដ្ឋកិច្ចមុខជាផ្លាស់ប្តូរខ្លាំងពីសម្បូរអគ្គិនីទឹក ទៅជាធំសម្បូរចំប៉ីហ្វ្រិកវិញ ។ ទ្វារខាងកើតមហាសាគរនេះ តំរែតែជាកំពង់ណាមាំ ដូចពីការត្រួតត្រាពលការអង់គ្លេសទៅខាងក្នុងណាមួយដែរ ។ ទ្វារខាងលិចគឺផ្លូវសម្រួចពីប្រទេសអាហ្វ្រិក រហូតទៅដល់អូស្ត្រាលី, ពិតមែន សម្បូរនេះនបានបិទមិនឲ្យចេញចូលដូចជាតំរែតែជាកំពង់ណាមាំ ដោយប្រឹក្សាភ្លើងធំឡាញ់បានឆ្ងាយ ទើងជាក់ស្តែងបំផុតណាទេ ។ គេយល់ឃើញ

ថា សង្គ្រាមសមុទ្រសម័យបច្ចុប្បន្ន បានធ្វើឲ្យដៃសមុទ្រម៉ាឡាកា មានតែជាខ្នាតឆ្លងបន្ទាត់ទឹកខាងលិច ហើយសម្រែចន្លាស្ថានឆ្ងាយម្ល៉ាងក្នុងមហាសមុទ្រថ្ងាស៊ីហ្វិក ។

ហេតុដូច្នោះ ការធ្វើនាវាស្ថាន (bose navale) នៅក្នុងសង្គ្រាមប្រឆាំងតែម៉ាមួនឡើង ជាការខាងប្រយោជន៍សំខាន់ណាស់ដល់ប្រទេសអង់គ្លីតែរ ដែលមានចំណាន់ធំធ្ងន់ក្នុងនេះ ជាបង្អែកបង្គោលសម្រាប់ពួកនាវាក្នុងពិជ័យសង្គ្រាម ។

នៅចុងក្រោយបំផុត ដូចជានៅប្រទេសវណ្ណៈក្បឿនៅមុខក្នុងពេលនាប់ ៗ នេះ ហើយនឹងបានឃើញហេតុការណ៍សម្រែចនាប់ខាង នៃនយោបាយរបស់ប្រទេសនេះ ។

យើងសូមឲ្យហេតុការនេះធ្វើឲ្យមានសិទ្ធិទាំងពាខាង ទាំងខាងប្រទេសអង់គ្លេស ទាំងខាងប្រទេសវណ្ណៈ តាមច្បាប់ប្រពៃណីដែលត្រូវបាន ។

ឃុនសុន្ទរមេធី ញ្ជូង-សឿង ប្រែ
លោក ហង់-គឹមសេង ពិនិត្យ

(ត្រឡក)

កាលពួកក្មេងត្រឡប់ទៅវិញគស់ហើយ នៅសល់តែមនុស្សម្នាក់ក្នុងផ្ទះតែប៉ុណ្ណោះ លោកមគ្គុមហាសេនាបង្គាប់ពួកអ្នកបំរើឲ្យនាំខ្លួនខ្ញុំ-គស់ ទៅកន្លែងដែលគេហើយឲ្យផ្តួតខ្ញុំកដុសលាងខ្លួនប្រាណឲ្យស្អាតបាតកាលខ្លួនខ្ញុំ-គស់ចូលទៅដល់ក៏ឃើញសំលៀកបំពាក់ថ្មីៗ ដែលគេមិនធាន់ឃើញប្រើប្រាស់ម្តងសោះ ហើយមានសាប៊ូស្អាតម៉ាកផងដែលជាទីបំផុតត្រមាំងគ្រឿងក្រអូបប្រណិតឯទៀតៗគ្រប់បែប ។ លុះគេបានដុសលាងសំអាតកាយរួចហើយ សាមីខ្លួនការនោអារចាស់វែងខ្លួនយកមកស្លៀកពាក់ឲ្យ ប៉ុន្តែមនុស្សបំរើយគស់សំលៀកបំពាក់ថ្មីផ្សេងទៀតយ៉ាងល្អស្រស់លេចមួយមកឲ្យគាក់តែងខ្លួន ព្រមទាំងយកគ្រឿងក្រអូបគន្ធតាំងផ្សាយក្លិនហុំងឈ្ងុយឈ្ងប់មកលុបលាបស្រឡាបសព្វសព្វាង្គកាយទៀតផង ។ បន្ទាប់អំពីនោះ ខ្ញុំ-គស់ ចូលទៅគាលោកមគ្គុមហាសេនាជាបិតាក្មេង, លោកក៏មានសេចក្តីពេញចិត្តណាស់ខ្លាំងរួបល្អស្រស់ថ្លៅស្កូនប្រសាថ្មីថ្មោង, លោកហៅឲ្យចូលទៅអង្គុយក្បែរ

លោកហើយក៏សាគស្សរលងគំសាន្តថា "កូនប្រុសគុតក, អ្នកបាន ប្រកាសប្រាប់គុតកថា ខ្លួនអ្នកជាកូនមន្ត្រីអ្នកមានពួរអម្ប្រាន់ប្រទេស អេសុប្តី ហើយបានទាំងនិយាយប្រាប់ថាអ្នកមានសេចក្តីថ្នាំងថ្នាក់អាក់ អន់ខាស់អធ្យាស្រ័យនឹងបងប្រុសខ្លួន ទើបដើរចោលស្រុកមកហួត ដល់ទីនេះឯង; ពេលនេះ គុតកសុំឲ្យអ្នកប្រាប់កំប្លែងអោយក៏កំភ្លាំងទាំង អស់ដល់គុតក ព្រមទាំងប្រាប់ឲ្យដឹងអំពីដើមចមនៃជម្លោះជាមួយនឹងបង នោះផង, ក្រែអ្នកមានសេចក្តីខុសចិត្តផ្សឹងគុតយ៉ាងស្មោះត្រង់ប៉ុនកុំបី ណាក់លៀមអ្វីឡើយ" ។

លំដាប់នោះ ខ្លួរេខិន-អស់ កំប្លែងរឿងពីអតិតរណ៍របស់ខ្លួន ជាមួយបិតាក្មេកហួរហែតាំងពីដំបូងរហូតដល់ចប់សព្វគ្រប់ ។ លោក អគ្គមហាសេនាបានស្តាប់ហើយ អត់ទ្រាំទប់សំណើចមិនបាន ក៏តាំង សើចក្អាកៗ ព្រោះរឿងនោះតុំដែលមានសោះ, រួចហើយលោក និយាយថា "រឿងរ៉ាវនេះ ជាការចំឡែកណាស់ប៉ាំ! កូន ប្រុសគុតក, ដំណើរវិវាទរបស់អ្នកជាមួយនឹងបងអំពីអាពាហ៍ពិពាហ៍ ដែលគ្មានតែតិតខ្មុកសើចយ៉ាងនេះ តើអ្នកស្មានថា មុខជាឪពុកបាន សម្រេចដូចពាក្យនិយាយដូច្នោះមែនឬទ្ធដូចម្តេច? មិនសមបើសោះ កូន ឯងបង្កហេតុឈ្លោះជាមួយនឹងបងប្រុសខ្លួន ពីព្រោះតែរឿងឥតប្រ-យោជន៍ដូច្នេះ; ប៉ុន្តែគុតតែមើលទៅឃើញថា ខ្លួសលើបងនោះ

ជាច្រើនជាតិ ព្រោះគេចាប់ផ្តាក់ប្រគាន់ទំនិសព្វបើរឿងដែលកូនឯងនិយាយ
សេនជាល្បែងសោះ ,ម្យ៉ាងទៀត ទុកដូចជាតិព្វសំណាងរបស់ឪពុក
ព្រោះបើកុំតែកូនឯងកើតហេតុពាស់ខែងគ្នា ក៏ឪពុកមិនបានអ្នកមកធ្វើ
ជាកូនច្រមាដែរ, ហេតុនេះឪពុកសូមអានុភាពជាអនេកចំពោះទេព្តាដែល
ថណ្តាលឲ្យអ្នកកើតរាល់ទោះឯង ។ ល្អើយ, យើងជាដែកលង្ហប៉ុណ្ណឹង
ប៉ុះកូន ព្រោះខ្លាចតែយប់ផ្តៅរាសដែរហើយ អ្នកល្មមថយខ្លួនទៅវិញ
ដេកតួនបុះ, កុំយោអ្នកកំរើលាំអ្នកយូរយារដែរ ចូរទៅឲ្យឆាប់ៗទៅ,
ចាំដល់ថ្ងៃស្អែកឪពុកនឹងនាំអ្នកចូលទៅតាល់ស្តេច ហើយឪពុកមាន
សេចក្តីសង្ឃឹមខ្លាំងចិត្តជាមុនថា ព្រះអង្គម្ចាស់ជានិនែងនិត្យពុជាខ្លាក
តាមចំណងដែលយើងបានតិតាំងនោះពុំខាន ។ ឯរេឌិន-អលី ក៏
ជំពាក់ចាប់តាក្មេកចូលទៅកាន់បន្ទប់កិយោរបស់ខ្លួន ក្នុងពេលនោះឯង ។

រឿងឯរេឌិន - អលី ស្មុះខុកត្រឹមនេះសិន, តតំនេះទៅនិងចាប់
និយាយអំពីសេមសេឌិនម៉ូហាម្មេវិញ រឿងនេះគួរឲ្យអស្ចារ្យចំណែក
ពេកណាស់ ព្រោះកុងថ្ងៃដែលឯរេឌិន - អលីការប្រពន្ធនោកុនជាប់
សូរ៉ាំនោះ សេមសេឌិនម៉ូហាម្មេវិញ ក៏រៀបការប្រពន្ធដំណាលគ្នា
នោកុនកែវដែរ; ឯដំណើរដើមទងនៃអាពាហ៍ពិពាហ៍របស់សេមសេ
ឌិនម៉ូហាម្មេទំនោះដូចសេចក្តីតទៅនេះ :

គ្រែឈើដែលនួរេខិន - អលី ចេញពីក្រែងគ្រែទៅជាន់ទៅ
ដោយឥតមានបំណងនឹងត្រឡប់មកវិញនោះ, សេមសេខិន ម៉ូហាម្មេ
ជាចងដែលជួនព្រះពុទ្ធជំ ណុះនៃស្តេចប្រទេសស៊ីប្តូ ទៅប្រពាតវៃ
ដើម្បីបង្ក្រាបម្រឹត អស់កាលយូរណាស់គឺចំនួនមួកនៃទើបត្រឡប់
មកដល់ផ្ទះវិញ; កាលមកដល់ហើយក៏តំណាងប្រញាប់ប្រញាល់ជួល
ទៅកងជួនួរេខិន - អលីជាប្អូន, ប៉ុន្តែស្រាប់តែឃើញចន្ទប់ស្ងាត់
សូន្យឈឹង ទើបមានសេចក្តីងឿងឆ្ងល់ណាស់ សួរបានព្រាក្នុងផ្ទះក៏
បានដំណឹងថា នួរេខិន អលីជំនួញដូរដុំណើរទៅខាងត្រែទីក្រុង
តាំងពីក្នុងថ្ងៃដែលស្តេចចេញទាហ៊ានវៃម្ល៉ះ, កាលចេញទៅបាន
ប្រាប់ថាទៅតែតិច - បីថ្ងៃទេ ប៉ុន្តែបាត់សូន្យឈឹងតាំងពីពេលនោះមក
រហូតឃើញវិលត្រឡប់វិញឡើយ ។ គ្រានោះ សេមសេខិន - ម៉ូហាម្មេ
តើតសេចក្តីក្តៅក្រហាយស្តាយគ្រាបខ្លាំងណាស់ ព្រោះឥតចាប់ភ្ញឹក
ទឹកមាសដ៏ក្រៃថាភាក្យសំដីដែលខ្លួនឧយាយតំកាមនោះ ទៅជានាំ
បណ្តាលឲ្យប្អូនអាក់មនចិត្តហួតឆ្ងល់ទៅតំរោលស្រុកចោលទេសជួបជុះ
សោះ ទើបប្រើប្រុសម្នាក់ឲ្យទៅតាមរកក្នុងក្រែង ជាម៉ាស៍ ហួតដល់
ក្រែង អាឡើយ, ប៉ុន្តែចំណែកខាង នួរេខិន - អលី នោងក្រែងបាល់សួរ
ឯណោះសោះ ។ កាលប្រុសនោះត្រឡប់មកវិញ ឥតបានដំណឹង
បន្តិចបន្តួចឡើយ, ឯសេមសេខិន ម៉ូហាម្មេ បានតាំងចិត្តថា ចាំការ

ប្រពន្ធហើយទើបជាតិមនុស្សឲ្យទៅរួចក្នុងដែរ ។ ក្រែងលោបួបប្រទះ
ហើយក៏រៀបចំអាពាហ៍ពិពាហ៍ ខ្លួនជាមួយនឹងកូនក្រមុំខ្ចីជាន់ខ្ពស់ម្នាក់
នៅក្រុងកែវដំណាលគ្នានឹងថ្ងៃដែលខ្លួនរេឌុិន - អាល័ជាប្អូនការប្រពន្ធនៅ
ក្រុងបាល់សូរ៉ាដែរ ។

និយាយដល់ត្រង់នេះ លោកឧត្តមហាសេនាយ៉ាហ្វ៍ក្រាបទូល
ព្រះបាទកាល់ហ្ស៍ថា បពិត្រព្រះសម្មតិទេព រឿងនេះមិនទាន់អស់ហើយទេ
នៅមានសេចក្តីប្លែកមួយទៀតជូនតទៅនេះគឺ កាលរៀបអាពាហ៍ពិពាហ៍
ទទួលទៅបាន ៨ ថ្ងៃ ភរិយារេចស់រេមមរេឌុិន - ម៉ូហាម្មេឌប្រសូតកូន
ស្រីមួយទៅក្រុងកែវ ហើយក្នុងថ្ងៃដំណាលគ្នានោះ ភរិយារេចស់ខ្លួនរេឌុិន.
អាល័ នៅក្រុងបាល់សូរ៉ា ក៏សម្រាលកូនប្រុសមួយដែរបានដាក់នាម
ឲ្យថា «រេឌ្វែនឌុិន - ហាស្សុន» ។ លោកឧត្តមហាសេនាក្រុង
បាល់សូរ៉ា មានសេចក្តីត្រេកអរកើតឡើងណាស់ហើយបានជប់លៀង
បណ្តាជនជាច្រើន ដោយបានឃើញចៅដែលទើបនឹងប្រសូតមកនោះ,
តាំងពីនោះទៅ, ដើម្បីនឹងបំពេញឧជ្ឈាស្រេយកូនប្រសា ដោយសេចក្តី
ពេញចិត្តរេចស់លោកៗក៏ចូលទៅក្នុងព្រះពន្ធវាំងក្រាបទូលព្រះពន្ធ សូម
ព្រះពន្ធានុញ្ញាតឲ្យខ្លួនបំប្រាសនូវតំណែងឧត្តមហាសេនាដែលលោកកំពុង
កាន់តាប់នោះទៅឲ្យកូនប្រសាវិញ ហើយលោកសូមលាជាឈប់
ព្រោះខ្លួនឈឺនឹងចាស់ជរាណាស់ហើយ ។

ព្រះពជា ខ្ញុំសូមព្រះពជាឫទ្ធិដ៏ខ្លាំងក្លានៃព្រះអង្គ-អស្ចារ្យ ដោយព្រះអង្គជ្រាបច្បាស់តាយើញក្នុងកាលដែលអគ្គមហាសេនាជាឪពុកក្មេកនាំទៅថ្វាយបង្គំតាល់គ្រែឃ្លេលដែលរៀបការហើយថ្មីៗនោះផង ដោយខ្ញុំបានព្រះសណ្តាប់កិត្តិស័ព្ទដ៏ពីរោះពិសាដែលអ្នកផងនិយាយអួតសរសើរថាជាមនុស្សប្រុសដើម្បីសុភាពាបសាផង ទើបព្រះអង្គខ្ញុំព្រះពជាខ្មាញ់តាមសេចក្តីសូមរបស់ឪពុកក្មេក ហើយក៏បំភ្លេចការសិក្ខាយសស្រាប់អគ្គមហាសេនាប្រទានឲ្យខ្លួនឯង - អស្ចារ្យក្នុងទំពាំនោះព្រះអង្គក្នុងពេលនោះឯង ។

ថ្ងៃស្អែកឡើង លោកអគ្គមហាសេនាជាឪពុកក្មេក កាលបានឃើញកូនប្រសាឡើងសក្តិយសជាអគ្គសេនាបតី ត្រួតត្រាការពារការគ្រប់គ្រងជំនួសលោកតាញបន្ទុកហើយ ក៏មានចិត្តអណ្តែតអណ្តូងរកការសប្បាយយ៉ាងក្រៃលែង ។ ខ្លួនឯង - អស្ចារ្យចំពោះការពារការបានសព្វគ្រប់ហាក់ដូចជាធ្លាប់បានគាន់ការនោះថ្នឹកយូរស្រាប់មកហើយតែងចូលគាន់ទំនុកបូតប្រឹក្សាការពារការគ្រប់ៗ ពេលដែលលោកអគ្គមហាសេនាជាឪពុកក្មេកចាស់ជក ខ្លះទៀមលែងគាន់ការនោះកើតគ្រែឃ្លេលដែលរៀបចំការពារហើយបាន ៤ ឆ្នាំ លោកអគ្គមហាសេនាក៏ខ្លួលអនិច្ចកម្មទៅ ដោយពេនជក ។ ឯការដែលលោកខ្លួលមរណភាពនោះ មានដំណើរសុខស្រួលណាស់ ឥតមានសេចក្តីក្តៅ

ក្រហាយស្តាយក្រោយខ្លាយ ព្រោះលោកមានសេចក្តីពេញចិត្តសង្ឃឹមកត់ក្តៅ ថាកូនចៅលោកនឹងអាចរក្សាការពារលើកដំកើងវង្សត្រកូលរបស់លោក ឲ្យបានវុឌ្ឍរឿងតរៀងតទៅក្នុងអនាគតកាល ។ ខ្ញុំរវេឌិន-អលី ទំរ្រឹងទ្រែងយកចិត្តទុកដាក់ធ្វើកិច្ចផ្សេងៗដាក់តបញ្ជាតរវើចំពោះបិតាក្មេកដែលលោកមានសេចក្តីស្នេហា នឹងសេចក្តីសង្ឃឹមដល់ខ្លួនយ៉ាងក្រៃលែង ។ លុះចេរ្ញែនឌិនហាស្សានជាកូនមានអាយុ ៧ ឆ្នាំ លោកខ្ញុំរវេឌិន-អលីក៏យកទៅផ្ញើនឹងត្រូម្នាក់យ៉ាងចំណាន, អាចារ្យនោះបានចាត់មេបច្ចាចារក្សាបង្ហាត់បង្រៀនឲ្យត្រូតាមហានៈនៃសិស្ស ហើយបានសង្កេតពិនិត្យមើលទៅឃើញថា កុមារនោះមានប្រាជ្ញាឆ្លៀវឆ្លាតវាងវៃអាចនឹងសិក្សាចំណេះវិជ្ជាត្រង់ប៉ងបានដោយឆាប់រហ័ស ។

ត្រូបង្រៀននោះឯង បង្ហាត់តែពីរឆ្នាំប៉ុណ្ណោះ ចេរ្ញែនឌិនហាស្សានក៏បានចេះគម្ពីរ អាល់ក៊ូរ៉ានស្ទាត់ជំនាញប្រាកដជាមែន ហើយយល់សេចក្តីសព្វត្រង់ឥតសល់ចន្លោះ ។ លោកខ្ញុំរវេឌិន-អលីជាបិតា បានយកកូនទៅប្រគល់ឲ្យត្រូដទៃទៀត ដើម្បីឲ្យជួយបង្រៀនចំណេះវិជ្ជាសិល្បៈសាស្ត្រផ្សេងៗទៀត ត្រឹមតែអាយុ ១៦ ឆ្នាំកុមារនោះចេះចប់ខ្ពស់វិជ្ជាចាំន-ឡាយ ។ ត្រានោះឯងរូបសម្បត្តិរបស់ចេរ្ញែនឌិនហាស្សានក៏ពេញលេញបរិបូណ៌, អត្តចរិតទាំងពួងបានឃើញហើយ ក៏គោរពស្ងើចសរសើរពេលទាក់ ។

កន្លះរៀន ១២ ឆ្នាំលោកឧត្តមហាសេនា ខ្លូវ ឌុន-អលី តំណែង
ក្នុងបន្ទីកកូនឲ្យហាត់រៀនតម្រែវិញតែម្យ៉ាង លោកមិនចាំបាច់បង្ហាញឲ្យអ្នក
ផងស្គាល់កូនលោកថាជាអ្វីឡើយ ។ មានកាលមួយដងលោកនាំកូនចូល
ទៅកាន់ព្រះពន្ធរាំង ដើម្បីឲ្យថ្វាយបង្គំតាល់តារៈប្រណិប័តន៍ព្រះពន្ធ
តាមទំនៀម; ព្រះពន្ធក៏ទទួលកាត់ពាក់ដោយព្រះវិស័យសោមនស្សរីករាយ ។
ជនទាំងឡាយដែលបានចូលប្រទះឃើញ ដោះទ្រង់ឌុនហាសូន្នែន នៅ
កណ្តាលផ្លូវក្តី ក្នុងទីណាក្តី សុទ្ធតែនាំគ្នាក្រុកក្តីកជញ្ជក់មាត់ស្ងើចសរសើរ
នឹងរូបនោមរោមពណ៌ដែលក្អមបំឡុងត្រកាលជាមួយអស់ពាំរមនុស្សក្នុង
ទីក្រែង ហើយនាំគ្នាឲ្យពាក្យសំដីបានធុកាត្រែបៗគ្នា ។

ក្នុងសម័យថ្ងៃមួយ លោកខ្លូវ ឌុន-អលី តំណែងបានកូនទៅបង្ហាត់
ឲ្យដេះដូរការក្នុងមុខក្រសួងរបស់លោក ដើម្បីទំនុំជួយលោកនៅថ្ងៃ
ណាមួយ; ឯបតិតយើញថ្លូថ្នូរហើយ លោកឥតបង្អែបង្អង់ឡើយ ក៏តាំង
នាំកូនទៅបញ្ចូលក្នុងសាលាសម្រាប់ធ្វើការពេជការនោះ បើយដាក់ការ
ដែលលំបាកៗឲ្យគេការ្តី ដើម្បីនឹងឲ្យកូនចេះគោរពថ្នាក់ស្មាតំណាញ
តាំងពីបឋមវ័យឲ្យហើយ ។ ក្នុងទីបំផុត លោកខ្លូវ ឌុន-អលីមិនដែល
ប្រហែសធ្វេសហោះ ចំពោះសេចក្តីចំរើនវុឌ្ឍរឿងរបស់កូនសំឡាញ់
ហើយលោកសប្បាយចិត្តណាស់ ដោយឃើញថាសេចក្តីព្យាយាម
ប្រឹងរៀនរបស់លោកមានផលប្រយោជន៍យ៉ាងសំខាន់គាន់តែសឿនទៅ

មុខហើយ ប៉ុន្តែមិនដឹងគ្រោះកម្មដូចម្តេច លោកកំពុងតែសប្បាយរីករាយ
ដូច្នោះ ស្រាប់តែចាប់ឈឺដាច់មួយ ហើយលោកក៏ដឹងខ្លួនជាក់ថាទឹងមិន
ឃាននៅយូរអង្វែងតទៅទៀតទេ មុខជាទឹងស្លាប់កន្លងគ្មានពុំខាន,
សម្បូរីមានដម្លឹងដូច្នោះ ក៏លោកឥតភ្លេចកូនប្រុសសំឡាញ់របស់លោក
ឡើយ, ខណៈនោះលោកឲ្យគេហៅកូនមកហើយនិយាយផ្តែផ្តាំថា «កូន
ស្ងួនមាសឪពុកអើយ, ចូរជ្រាបថាឈាមដ៏លប្លុះ ជម្ងឺឈាមក្តៅលោកនេះតែង
រីឯសសាបសូន្យទៅជាឯម្តង; មានតែបរលោកដែលឪពុកទុំនឹងទៅក្នុងគ្រា
ឥឡូវនេះ ទើបជាកន្លែងឥតតាំងនៅបំតេះបំតោល គ្រាតែកូនចាប់ផ្តើម
រៀបចំខុសជាក់ខ្លួនជ្រុលតាមរបៀបដែលឪពុកបានប្រព្រឹត្តមក គឺត្រូវ
ប្រឹងរៀបដើរតាមគម្រោងឪពុកកុំស្តាយ ត្រង់កុំឲ្យខ្លួនឯងតិះដៀលខ្លួនឯង
ឃានចំពោះធម៌នៃទុច្ចសកអ្នកកាន់សាសនាមហាយ៉ាន ចាំនឹងចំពោះធម៌
របស់មនុស្ស អ្នកកាន់សេចក្តីសុចរិតរៀងត្រង់ ។ ចំពោះសាសនារបស់
អ្នក, អ្នកក៏មានការចេះដឹងល្មមគោរពប្រតិបត្តិឃានគ្រប់គ្រាន់ ព្រោះគ្រូ
របស់អ្នកបានបង្រៀនអ្នករួចហើយ; ចំណែកខាងកិច្ចដែលទឹងធ្វើខ្លួនឲ្យ
ឃានដោយមនុស្សសុចរិតវិញ នោះ ឪពុកទឹងឲ្យដំបូន្មានពីរបីម៉ាត់ដល់កូន
ក្នុងគ្រាលេងឥឡូវនេះ ដើម្បីឲ្យកូនចំប្រឹងធ្វើបាតសង្ឃឹតក្បួយតាសេចក្តីចំរើន;
ម្យ៉ាងទៀតអ្នកត្រូវតែដឹងដើមកំណើតឫសគល់របស់ខ្លួនឯង ព្រោះអ្នកមិន

ទាន់ឃាននដឹងច្បាស់ថា ខ្ញុំនឹងពុកនេះជាមនុស្សប្រៃបណាទៅឡើយទេ, ឥឡូវនេះនឹងពុកនឹងប្រាប់អ្នកឲ្យឃាននដឹងជូបតទៅនេះ :

"នឹងពុកកើតនៅប្រទេសអេស៊ីប្ត៍ ជាតាកូនឯងធ្លាជាអគ្គសេនាបតីនៃព្រះពជាកូនប្រទេសនោះ, កាលអំណើះអំពីជាតាកូនឯងទៅ ខ្ញុំនឹងពុកនេះក៏ឃាននខ្លួលដំណែងកិត្តិយសជាអគ្គសេនាបតីនៃព្រះពជាជដែលជាមួយនឹងបងប្រុសតឹងពុនធំបេស់កូនឯង ឈ្មោះថាសេមសេខិនម្ប៉ូហាម្មេខសព្វថ្ងៃនេះបើតាមនឹងពុកស្មាន ម៉ែលទៅប្រហែលជាតាត់នៅសេះទៅឡើយទេ ។ ដោយមានរឿងហេតុអាក់អន់ចាស់អញ្ជាស្រ័យនឹងបងនោះ ទើបនឹងពុកដើរចាលស្រុកកំណើតមកនៅក្នុងស្រុកនេះហើយក៏ឃានឡើងយសសក្តិជាអគ្គមហាសេនាជាបម្រាស់សព្វថ្ងៃនេះឯង; ប៉ុន្តែប្រតិព្តិចាំងអស់ប្អូកូនឯងដឹងច្បាស់ៗ សំតាមសៀវភៅ ដែលនឹងពុកនឹងប្រគល់ឲ្យអ្នកកូនកាលឥឡូវនេះ" ។

លុំជាប់នោះ លោកឧប្បវេខិន-អលី ចាញ្ជាយកសៀវភៅនោះដែលលោកឃាននសរសេរដោយដៃបេស់លោកពិតៗ មកហុចឲ្យបេក្ខខិនហាស្ស័នកូនសំឡាញ់ហើយមានវាចាថា «កូនប្រុសពន្ធុក, ចូរកូនយកសៀវភៅនេះទៅហើយ ចូរម៉ែលកងពេលនុកាសដែលចំនេះៗ; អ្នកនឹងឃានដឹងកិច្ចការគ្រប់ជំពូកជូបយ៉ាងថ្លៃ. ខ្ញុំ-ឆ្នាំដែលនឹងពុកវៀបអាពាហ៍ពិពាហ៍នឹងថ្លៃ ខ្ញុំ-ឆ្នាំកំណើតបេស់អ្នក ។ កិច្ចការទាំងនេះគឺជារឿងដែលអ្នកគង់នឹងឃាន

មានសេចក្តីត្រៃការនៅក្នុងអនាគតពុំមានហើយអ្នកត្រូវថែរក្សាសៀវភៅនេះទុកឱ្យល្អកុំឱ្យបាត់បង់» ។ ចេះទ្រង់ជិនហាស្សរៃ មានសេចក្តីរីឆ្អល់អួលអន់ជាទីបំផុត ដោយបានឃើញខ្លួនពុកឃ្លាមខ្លាំងណាស់, ខឹកស្រែណោះស្រែណាកគាំណាបអាធ័មនឹងពាក្យបណ្តាំនោះតន់ពក ឆ្ងាយលួកដៃទទួលយកសៀវភៅនោះឯងទាំងទឹកភ្នែកហូរហៀរដូនជារដាកមុខទាំងមួល ហើយក៏ទទួលថ្លែងចំពោះខ្លួនពុកថានឹងប្រតិបត្តិតាមដំបូន្មានទាំងឡាយនោះយ៉ាងម៉ឺងម៉ាត់ខ្ជួនឥតប្រហែសឡើយ ។

ឯណោះនោះឯង លោកនូរេដ្ឌិន-អាលី ចាន់តែក្បាយកំឡាំងដុនជាបខន់ទៅហួតដល់ភ្លុកសន្ធប់ចាត់ជ ឆ្លឹមសួទ្បាលឹង; ប៉ុន្តែលុះមួយស្របក់លោកក្មេងខ្លួនបានស្មារតីឡើងវិញ ទើបទ្រង់ឱ្យនុកជាទីបំផុតដល់កូនសំឡាញ់ថា «ប្រុសស្ងួនខ្ញុក, កូនចំបុងនេះខ្ញុកឱ្យនុកនូវ ៥ យ៉ាងដល់កូនដូចសេចក្តីខាងក្រោយនេះ គឺ:

๑ - កុំសេពគប់កប់ប្រសព្វទំនឹងមនុស្សគ្រប់ជែបចាំងអស់ពេក ។ ខ្លះយោបាយដែលខ្លួនចិញ្ចឹមដើរតបខ្លួនដោយដៃក្បាលក្បាខ្លួនោះ គឺខ្លួនឯងត្រូវខំពឹងខ្លួនឯងឱ្រាញជន្លក ហើយកិច្ចការអ្វី ។ មិនត្រូវអើលមាត់ផ្សាយប្រាប់គ្នាឯ ។ ល ។

๒ - កុំតាំងការជាដាក់តំរិត ជង្ឃិតជង្ឃុំ ជៀតជៀនគេចាំងអំណាចព្រោះកាលដែលអ្នកធ្លើដូច្នេះ មនុស្សចាំងពួនទំនងដេរឿងក្បត់ចំពោះអ្នក

វិញពុំមានហើយអ្នកត្រូវខុសមនុស្សចាំដណ្តើមដូចជាម្ចាស់ប៉ុណ្ណោះ ដែលអ្នកគួរតែមានសេចក្តីយោគយល់, សេចក្តីអាណិតអាសូរ ទើបសេចក្តីសន្តោសត្រាស់ប្រាណី ។

๓ - កាលបើមានគេតិះដៀលប្រទេចផ្តាសាអ្នក។ កុំតបឆ្លើយសងវិញដូចមានសុភាសិតថា គេអាចរុបអំពីគ្រោះថ្នាក់បាន លុះត្រាតែបិទចិត្តឲ្យជិត, នេះឯងហើយជាកិច្ចយ៉ាងឯក ដែលអ្នកត្រូវប្រព្រឹត្តតាម; រឿងនេះអ្នកបានចេះដឹងស្រាប់ហើយដូចមានន័យតែម្នាក់ (អ្នកប្រាជ្ញសុភាសិត) និយាយថា សេចក្តីស្ងៀមជាគ្រឿងទល់ភ្លើងនឹងជាគ្រឿងការពារដ៏វិសេស; ពេលនិយាយមួយ។ កុំប្រើសំដីឲ្យដូចជាភ្លើងឆាយៗដែលចំផ្លាញបេះត្រូបដំពូក ។ គេមិនដែលត្តៅក្រហាយស្តាយក្រោយពីព្រោះតែស្ងៀមទេ ។

๔ - កុំដឹកទឹកស្រែរំងឹ ព្រោះជាដើមចមនៃអំពើទុច្ចរិតចាំដណ្តើន ។

๕ - ត្រូវចេះលៃលកសំចៃទ្រព្យសម្បត្តិ; បើអ្នកអាចរក្សាទ្រព្យទុកបានកុំឲ្យវិនាសខូចអស់តែការ, ទ្រព្យចាំដណ្តើនោះនឹងបានជាផលប្រយោជន៍ក្នុងពេលដែលអ្នកមានកិច្ចធុរៈ ។ ម្យ៉ាងទៀតមិនត្រូវធ្វើខ្លួនឲ្យទៅជាមនុស្សកំណាញ់ត្រកាតម្លេះទេ ត្រូវតែចេះលៃលកចាយវាយ ទោះបីតិចច្រើនតាមសមត្ថភាពដល់ធនធានរបស់យើងិ, កាលបើធ្វើយ៉ាងនេះ អ្នកនឹងមានមិត្តសំឡាញ់ច្រើន, ប៉ុន្តែប្រសិនបើអ្នកមានទ្រព្យសម្បត្តិច្រើន

រឿងព្រៃ

ពេទ្យសំណាង

ឃុនសុវត្ថិវេទ្យ ហ្សូ-ស៊ីន រៀបរៀង

កន្លងកាលដ៏កន្លងឃ្លេមតហើយ មានបុរសម្នាក់ឈ្មោះ សំណាង ជាមនុស្សក្រីក្រអាត្មក មានតែម្តាយជាគំរប់តែ១ ទៅស្រុកបច្ចន្តតាមកន្លងតបុរីមេឃ ជាអ្នកភាល់ក្រែពាសមត្តុ ត្រមាំងលួងខ្លៅ មិនមានវិជ្ជាចំណេះអ្វីក្នុងខ្លួន សូម្បីតែអក្សរនឹងសេរក៏មិនចេះផង ។ ជីវិតនាយសំណាងប្រតិត្តមកបាន ២០ ឆ្នាំហ្នាឃហើយ មិនដែលប្រទះសេចក្តីសុខស្រួលម្តងសោះ ជួបតែសេចក្តីទុក្ខយហត់ លុះតែខំប្រឹងរក ថែងភ្ញើសតាងចិត ទើបបានអាហារថវិកាគត្រឹងល្មម, ឯសំលៀកបំពាក់មានត្រាន់តែបិទបាំងកេរ្តិ៍ខ្មាស ថែមទាំងមានបំណុះប្រើនជាន់ប្រើនពាណិ, មុខអួរឲ្យសង្វើតពេកណាស់ ។

មានកាលថ្ងៃមួយ នាយសំណាងបានតែក្តក្តាំង ជាហេតុនាំឲ្យចិតមុខស្រពោនមិនភ្លឺរស្មីរស្មោះតែអង្គុយសំកុក មិនធ្វើយាយស្តីរកអ្នកណាឡើយ ។ ក្នុងខណៈនោះ មានគ ជាស់ម្នាក់ មានឆាមនឹងតោត្រមិនច្បាកដ ស្មាស្តាំឆ្លងយាម ដៃគាន់ឈើច្រត់ បានដើរមកជួបនឹងនាយសំណាង ក៏សួរថា នែខៅ មុខខៅក្រៀមក្រស់មិនស្រស់ស្រាយសោះ

ចំនង់ជាមិនសប្បាយដោយហេតុអ្វីមួយឬទៅ? ។ សូមជំពប់ប្រែសាសន៍លោកតា ខ្ញុំចាត្រូវចិត្តជាខ្លាំង ។ ហៅត្រូវនៅព្រោះរឿងហេតុអ្វី? ។ ចាទ, ព្រោះខ្ញុំចាគាល់តំនិតមិនជឿជាន់តិតឆ្កែហែបណា គ្រាន់តែចិញ្ចឹមដំរែតឲ្យធ្វើនស៊ុនស្រួល កុំឲ្យមានលំបាកដូចសព្វថ្ងៃនេះ ។ អាយុហៅថ្លុនប៉ុន្មានឆ្នាំហើយកើតថ្ងៃអី ខែអី ឆ្នាំអី? ។ ជំពប់ប្រែសាសន៍លោកតា ខ្ញុំចាអាយុ ៦៦ ឆ្នាំហើយ តើតថ្ងៃព្រហស្បតិ៍ ខែពិសាខ ឆ្នាំច ។ ចានជាតាសួរដូច្នេះ ព្រោះតាចានស្តាប់ពាក្យហៅឯងមក គួរឲ្យអាណិតណាស់ តាចង់ពិនិត្យមើលដោតជតាពស៊ីហៅឯង តែក្នុងមួយចប់ដំរែហែស់ហៅប្រព្រឹត្តទៅបែបណា ។ ចានលោកតាមើលឲ្យខ្ញុំចាអរគុណាកែប្រែបន្តិច ។ តាចាស់ចានឆងលេខថ្ងៃខែឆ្នាំនង់អាយុកម៉ាមនពិនិត្យតន់គួរមើល សង្កេតតាមតម្លើរវែដែលចេះពាំមកសព្វគ្រប់ហើយ ទើបពិនិត្យមើលលក្ខណៈខ្ញុំដែលតាយរូបនោមរបស់ហៅសំណាង មកផ្គូតានឹងលេខថ្ងៃខែឆ្នាំ ហើយតាយថា នែហៅ! ចំនាយហៅឯងថា ទង់ចានសេចក្តីសុខ មានកេរ្តិ៍ឈ្មោះដោយសារវិជ្ជាមួយ ។ វិជ្ជាអ្វី? លោកតា! ។ វិជ្ជាពេទ្យផ្សំថ្នាំព្យាបាលរោគគ្រប់ជំពូក ហៅ! ។ ខ្លាលោកតាអើយ! ខ្ញុំចាខង់ចេះផ្សំថ្នាំធ្វើជាគ្រូពេទ្យដូចម្តេចកើតចើខ្ញុំចាខ្លៅម្ល៉ះ សូម្បីតែអក្សរលេខាក៏ខ្ញុំចាមិនចេះឆង ។ តាចាស់ញញឹមហើយថ្លែងថា មានមនុស្សច្រើនមាក់ណាស់ ហៅ! ដែលមានខ្លួនឯ

សម្បត្តិ ព្រមទាំងមានកេរ្តិ៍ឈ្មោះ ក្រែះណែវិជ្ជាផ្សំថ្នាំ គេក៏មិនបេះអស្រ័
ដូចចៅដែរ ។ ចៅថ្មែនដូចលោងតាមានប្រសាសន៍មែន ខ្ញុំឯង
អរណាស់ ។ បន្ទាប់មក តាចាស់ហានាយសំណាងដើរក្បួសទៅ
មិនដឹងជាទៅកាន់ទីណា ។

ឯលតាចាស់នោះទៅបាត់, ចៅសំណាងអង្គុយគិតតែ១ស្រ-
ចក់ ក៏ស្រាប់តែរំលែកមុខថ្លាស្រស់ ដោយនឹកយល់ថា នុលោកកា
នេះទាយហាក់ដូចជាបើកមុខវែងផ្លូវឱ្យអញឆ្ពោះតាមទុកជាដោះហើយ ។
កាលកន្លងមកមិនយូរប៉ុន្មាន, ចៅសំណាងគោងមាត់សមុទ្រ ដើរគេ
រើសឆ្នឹងត្រី, សំបកលៀស. សំបកគ្រែ, ស្លកអណ្តើក-បបែល-កន្ធាយ
កុយ ភ្លុក សែ្បក ស្នែងបេះសត្វផ្សេង។ ទំនិងសំបុកឆ្អែញាំដាដើម,
កាលត្រឡប់ពីមាត់សមុទ្រមកវិញ ជាន់ខ្សែនឹងទៅកាប់ព្រៃក្តុំ រកកាប់
ដើម, ឫស សំបកនៃឈើវិសេស។ ក្រៃ ដែលចំនានរៀងអាយ
ទំនិងលតាស្ងៃផ្សេង។ ហើយយកមកតម្រៀបជាតំលាក់តណ្តាលផ្សារនៅ
ស្រុកបច្ចន្តគ្រាម ព្រមទាំងនិយាយបញ្ចុះបញ្ចូលមនុស្សទាំងពួង ឱ្យជឿ
ជួលពិក្តជាថ្នាំយកទៅប្រើម្ចាស់កេតទាំងពួង ។ រីឯពួកបុរសស្ត្រីដែល
មានកេរ្តិ៍ព្រោះកេតត្រូវសង្គត់រឹតជាន់ពន់កាយ សឹងតែនាំគ្នាខ្វល់ខ្វាយ
ជួលជាវនូវចំពីនាយសំណាង គ្រប់ៗគ្នា ។ ចាប់ដើមពីថ្ងៃដែល

តាយសំណាងតាំងថ្នាំលក់ អ្នកផងនាំគ្នាហៅថា "ពេទ្យសំណាង" ជាប់រហូតរៀងមក ។

ទៅនុកាសដែលពេទ្យសំណាងកំពុងផ្សាយថ្នាំនុសថ, ពួកចៅហ្វាយស្រុកគ្រប់ដងខ្នងកន្លែងតាប៉ុរមេ្យ សឹងតែទាំងខ្វល់ខ្វាយចាត់តាវឲ្យភ្ជាក់ងារចិនៗ ទៅស៊ើបរកពេទ្យពូកែៗ ក្នុងដងខ្នងដែលខ្លួនគាន់គាប់, លុះស៊ើបទៅឃើញមាន ក៏បញ្ជូនពេទ្យទាំងនោះទៅថ្វាយព្រះករុណាម្ចាស់ជីវិតនៃនគរប៉ូរីមេ្យ តាមព្រះពាជនុជ្ញាត្រៃស់បង្គាប់ ។ ចំណែកឯពួកកស្ត្រីអ្នកស្រុកបង្កួនគ្រាម កាលមានពួកភ្ជាក់ងារពេជគារស្រុកទៅស៊ើបរកពេទ្យពូកែ ចូនធ្វើយដាក់ទៅលើពេទ្យសំណាងទាំងអស់គ្នា ។ ចៅហ្វាយស្រុក ឬ បច្ចន្តគ្រាម ក៏ឲ្យហៅពេទ្យសំណាងមកសាលាស្រុក ហើយថ្កាប់ថា នែពេទ្យសំណាង! អ្នកផងក្នុងស្រុកនេះនិយាយថាអ្នកឯងចេះផ្សំថ្នាំយ៉ាងចំណាន, ពុះអ្នកឯងដឹងទេ? ឥឡូវនេះព្រះមហាក្សត្រដែលសោយរាជ្យទៅនគរយើងនេះ មានព្រះសោយរោគក្អកវេង ទ្រង់បានឲ្យពួកពេទ្យទៅចិត្រឹងទាំងអស់ល្មាំន មកព្យាបាលរោគនោះហើយ តែមិនបានជូរស្រាកស្រាន្តសោះ ទើបទ្រង់ចាត់ព្រះពាជនុជ្ញាវង្គាប់មកចៅហ្វាយស្រុកគ្រប់ស្រុកក្នុងព្រះនគរ ឲ្យបញ្ជូនពេទ្យក្នុងស្រុកម៉ួយៗ ទៅមើលរោគព្រះអង្គ, ហេតុនេះ យើងនឹងបញ្ជូនអ្នកឯងឲ្យទៅមើលព្រះរោគស្តេចនោះ ក្នុងកាលឥឡូវនេះ ។

ចានឮថា ពេលស្រីសំណាងនោះ ក៏ដើរដេកក្នុងរថដ៏មានឈ្មោះ
ហើយដែរ តែរត់ទៅមើលដោយខ្លួនឯងមិនទាំងសោះ, លុះបានស្តាប់
ពាក្យចៅហ្វាយស្រុកតម្រែឲ្យដើរមើលពេលស្លេបដូច្នោះ ក៏កិតក័យជា
ខ្លាំង បានអង្វរចៅហ្វាយស្រុកថា សូមលោកមេត្តាកុំឲ្យខ្ញុំ
ច្រឡាំងទៅឲ្យខាន ព្រោះខ្ញុំច្រឡាំងគ្មានបើ ផ្សែរថ្ងៃណាពេលច្រឡាំងនោះ ពេ
លណាមួយខ្ញុំច្រឡាំងក៏តែងដេកលក់ដែរ ខ្ញុំបានដឹងទៅមើលថ្ងាយ
ស្លេបដូចម្តេចតែត ។

រីឯចៅហ្វាយស្រុកនោះ ជាអ្នកខ្លាចស្លេបឯណាស់ ដោយគិតឃើញ
ថាបើមិនបានបញ្ជូនពេទ្យណាមួយទៅថ្ងាយ ក្រែងស្លេបយកនៅសល់
ស្មៅសន៏ដ៏ព្រះពុទ្ធរូប តែនឹងត្រូវពេទ្យដទៃក្នុងស្រុកនោះស្តីតិពេទ្យ
សំណាងមិនបាន ដើរពុំត្រូមទទួលពាក្យអង្វរ, ទោះបីពេទ្យសំណាង
អង្វរយ៉ាងណា ក៏រឹងតែតែងដៃដែងអំណាចប្រើអាការបង្ខិតបង្ខំថាខ្លាំង
ដកបាលតែពេទ្យសំណាងលែងច្រើតែត ត្រូមទទួលទៅចាំងកិតក័យ ។
ចៅហ្វាយស្រុកបានចាត់បម្រើម្នាក់ ឲ្យយកវេះ ១ មកឲ្យពេទ្យសំ-
ណាងទៅថ្ងាយស្លេប ក្នុងពេលនោះភ្លាមដែរមានបរិច្ឆិបច្ឆិងខ្លាំង ។
ពេទ្យសំណាងជិះវេះទៅដល់ផ្សែរយៈផ្លូវប្រមាណឆ្ងាយ ក៏បានដល់ភ្នំមួយ
ដែលតាំងនៅពាក់កណ្តាលផ្លូវ បានជាតែវេះឈប់តែចំពីមុខភ្នែរដើមភ្នំ
តែះ ។ ដោយឃើញស្រែតខ្លាចពន់ពេក, គេះជាតុក្កដ្ឋិខ្លួនពេទ្យសំណាង

ក៏នេះជាលក្ខណៈដាច់ខាត ជាហេតុបណ្តាលឲ្យពេតអ្នកវិនិតែតែខ្លាំង ខ្លើងលើសដើមទៀត ។ ជួនជាពេលនោះ ជាដូវៃ្រជ្រាំង, សត្វ ច័ក្ខុមិកាតផែនដីស្បែរជើងក្តុំ សឹងតែវិនស្លូតហួតហែងនោះ ខ្លះអស់ពុំមានទឹកដក់នៅបន្តិចបន្តួចឡើយ, ពេលសំណាងដើរកេស្តើរជាច់ប្រាល់ពុំបានទឹកត្រែចសោះ, ដើរទៅដើរទៅបានឃើញរូងមួយ ដល់ដើរចូលទៅជិតឃើញមានពុះស្រែប្តីប្រពន្ធនៅកន្លែងរូងនោះ, ឯប្រពន្ធកំពុងលាងចង្ការ ច្រែនមុខ ក្នុងដើង ១ ដោយទឹកបន្តិចហើយល្អក់ខ្លះ ។ ពេលសំណាងនិយាយសុំទឹកថា ម៉ែអ្នក! មានទឹកទូលាន់ទេ, មេត្តាឲ្យខ្ញុំសុំទូលាន់ផង ១ ដែរ ។ ស្ត្រីនោះតបថា ឧ លោកអើយ! ខ្ញុំគ្មានទេ, នៅទីនេះត្រែទឹកណាស់, ខ្ញុំខំសំរេចដងអំពីអណ្តូងខាងក្រៅជូរបានល្មមតែស្លូដណ្តាំ, នៅសល់បន្តិចបន្តួច ខ្ញុំយកមកលាងចង្ការនេះអស់ទៅហើយ ។ ពេលសំណាងត្រែកទឹកខ្លះតេតក្រែអត់ពុំបាន ក៏សុំទឹកលាងចង្ការខ្ញុំអំពីស្ត្រីនោះមកផឹក រួចលាម្ចាស់ខ្លួនត្រឡប់មកខ្លើងជិះរេះធ្លើដំណើរតទៅមុខទៀត ។

លុះពេលសំណាងជិះរេះទៅដល់ទីក្រុង ក៏បររេះចូលទៅតាមថ្នល់កន្លែងក្រុង មើលឃើញថ្នល់ស្អាតៗ ខ្លាត់ខ្លែងជាក្រឡាចត្រង្គ ឃើញសសរតោមជាក់បន្តើងចំគ្នាវែលយល់ភ្នែក តាមដោយជិញ្ចើមថ្នល់ជាសង្កាត់ៗ, ឃើញផ្ទះល្វែងធំៗខ្ពស់ៗច្រែនជាន់ច្រែនល្អែងសង់ជាជួរ

តាមសង្ឃឹងថាវាន់ទំមួយ។ ខៅកន្ងផ្ទះផ្សារចាំងនោះ ឃើញសុទ្ធតែជាតំ
អ្នកនតរបុរីមកបើកលក់ទំនិញគ្រប់មុខ, ទំនិះឃើញសួនផ្កា ដាំផ្កាលា
ពណ៌ចម្រុះគ្នា រីចំគ្រជាកម្សាន្តភ្នែកគួរឲ្យមើលណាស់។ ពេលសំណាង
ជិះរទេះតន់ម៉ើលបណ្តើរ លុះបរទៅដល់ព្រះបរមរាជវាំង ឃើញកំពែង
វែងលន្ឋម ធ្វើអំពីឥដ្ឋខ្ពស់ព័ទ្ធជុំវិញជា ៤ ជ្រុង, ខៅជុំវិញកំពែងនោះ
មានកេងទទឹងដ៏ល្អរិចរិលគ្រកម្សាន្តបបានាប្លែកៗ។ ម៉ើលទៅខាងក្នុងឃើញប្រាសាទ
ដាច្រើន ខ្ពស់ទន្ទឹង ប្រក់សុទ្ធតែក្បឿងពណ៌ក្រូចឆ្អែត កំពូលមុខ
ព្រហ្មចួន, ខៅចំកែ្យខាងប្រាសាទមួយបរ មានសួនផ្កាល្អគ្រកាលទេព្យ
សំណាងឃើញហើយ ខឹកអស្ចារ្យស្ងើចស្ងប់ស្ងៀងខ្លាចរំខានពុលពស្ចើច
ផែនដី ដែលរៀបចំចំណែកនឹងព្រះពេជវាំងឲ្យរុងរឿងនេះដោយការនតឋការ។

កាលទេព្យសំណាងចុះពីរទេះដើរចូលទៅកន្ងព្រះបរមរាជវាំង ឃាន
ឃើញពួកទេព្យដែលមកអំពីស្រុកគ្រឹះ កំពុងតែរ៉ាំរែសថ្វាយស្តេច តែ
ស្តេចសោយឃ្លាំងាំងនោះទៅ ក៏ពុំឃានជាព្រះពេញឡើយ។ កន្ងកាលមុន
ខឹងចូលទៅគាល់ស្តេច ទេព្យសំណាងមានព្រួយចិត្ត ឆ្ងល់គំនិតជាខ្លាំង
ណាស់ ដោយឃើញស្រាវជ្រាវនឹងរកថ្នាំនឹងយកមកប្រឆាំងផ្សំថ្វាយស្តេច
ដើម្បីជោះពាល់ខ្លួន ព្រោះកាលចេញពីផ្ទះមកគ្មានដោយជាប់ថ្នាំបន្តិច
បន្តួចមកជាងខ, ដើរបណ្តើរគំរាកថ្នាំបណ្តើរ, កំពុងតែដើរគិតដើរគិត
ស្រាប់តែភ្ញាក់កន្ងចិត្តថា "ឃើ! កញ្ចឹមកាមផ្លូវ មិនបានពិនិត្យម៉ើលកេត

ខ្ញុំឯងដ៏ជាសោះ, ឥឡូវនេះក្នុងខ្ញុំនឹកឃើញដូចជាបានជួបច្រើនណាស់ បាត់ក្អក
បាត់ក្តៅស្ទេញអស់ហើយ, ចិត្តហាលពេតក្តីរបស់អញនេះបានសេរីយ
ដោយសារផឹកទឹកលាងជើងខ្ញុំដែលសុំពីស្រីនៅជើងភ្នំនោះទេដឹង? អញ
គួរមើលថ្វាយៈស្តេចតាមទំនងនេះចុះ" លុះគិតឃើញដូច្នេះហើយ ក៏ឲ្យគេ
នាំខ្ញុំចូលទៅក្រាបថ្វាយបង្គំតាល់ស្តេច។ ទ្រង់មានព្រះពាក្យសួរថា "ពេទ្យ
សំណាង! អ្នកឯងគាបមើលពេតយើងជាទេ? បើមើលជា, យើងនឹងឲ្យ
ភ្លើងជាច្រើន" ។ ពេទ្យសំណាងក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តា
ប្រោស! ខ្ញុំព្រះបង្គំសូមមើលថ្វាយតាមបន្ទាល់, តែសូមទ្រង់ព្រះ
ពាដានបន្ទះមួយដ៏ស្អាតនឹងមនុស្សប្រមឹពីនោក់ ដើម្បីនឹងបានចាត់ចែង
ឧសថថ្វាយ" ។ ស្តេចទ្រង់បានប្រថានតាមពាក្យសុំរបស់ពេទ្យសំណាង។
បានហៅអ្នកបម្រើទាំងពីរនាក់នោះ ឲ្យចូលទៅកន្លែងបន្ទះហើយបង្គាប់ឲ្យ
ទៅកេះស្ទឹកឈើ ផ្លែឈើ មើមឈើដែលគេស្ទាត់កោតបានចន្លុះ។
ត្រង់មុខអំពីស្រុកវៃសមគឲ្យ, គាលបានភ្លើយ ក៏យកចូលទៅកន្លែងបន្ទះ
នោះហើយយកទំលាងក្នុងបានដែកមួយ ធ្វើទំនងឲ្យដូចស្រីលាងជើងខ្ញុំ
ដែលខ្ញុំនេះឃើញ រួចយកទឹកនោះទៅត្រដាងដោយសំពាត់សស្អាត ហើយ
ចាក់ទៅកន្លែកមួយនាំយកទៅថ្វាយស្តេច។ សោយទឹកឧសថអស់នៃ
ថ្ងៃនោះ ព្រះអាពាធក៏បានធូរស្រេះស្បើយបាតព្រះអង្គ ។

ព្រះមហាក្សត្រាធិរាជ កាលបានជាព្រះពេតហើយ ខ្ញុំសោមនស្សរីករាយសប្បាយក្នុងព្រះពេជ្ញខ្លួនជាខ្លាំង ខ្ញុំបានធ្វើបដិការគុណពេទ្យសំណាង ឲ្យសមគួរដល់កិច្ចដែលគេបានស្រង់ជីវិតព្រះអង្គ គឺខ្ញុំប្រគានស្រីស្ងួនម្នាក់ឈ្មោះ សុគន្ធ អាយុ ១៨ ឆ្នាំ ដែលមានរូបឆោមល្អឆើតមានកូដពង្សខ្ពង់ខ្ពស់ ឲ្យជាកវិយា, ខ្ញុំប្រគានខ្ញុំប្រុសខ្ញុំស្រីច្រើននាក់ទៀតជាបាសប្ចាក់ច្រើនពាន់ ព្រមទាំងផ្ទះមួយដ៏មានប្រជាប់ប្រើប្រាស់ក្នុងនោះគ្រប់គ្រាន់ ហើយខ្ញុំប្រគានយសសក្តិខ្ពង់ខ្ពស់ទីឧកញ៉ាសំណាងមានកិត្តិ ។ ពេទ្យសំណាងតាលបានខួលព្រះពេជអំណោយដ៏ប្រសើរយ៉ាងនេះហើយ ក៏មានចិត្តត្រេកអរមហិមាបានដោះម្កាសនាជាមួយនឹងនាងសុគន្ធជាសុរសប្បាយ ថ្ងៃក្រោយមកបានប្រែគេឲ្យទៅនាំមាតាយកមកនៅជាមួយឯទីក្រុងវិញ ។

តាំងតែពីថ្ងៃដែលព្រះពេជាខ្ញុំសះស្បើយព្រះពេត, កិត្តិសព្ទដ៏ពិរោះក៏លាន់ឮខ្ទរខ្ទាយពេញទាំងនគរថា ពេទ្យសំណាងមើលស្លេចជា ។ មនុស្សទាំងឡាយជាអ្នកមានខ្លួនឈ្លុះ ដោយពេតផ្សេងៗ បានទាំងគ្នាចូលទៅសុំជាវេជ្ជាលោកសំណាងពាល់ថ្ងៃ ។ ទុស្សឋណាដែលលោកសំណាងផ្សំឲ្យ ទុស្សឋនោះតូចតែសក្តិស័ក្តិតាចរម្ចាប់ពេតបានជួចចិត្ត ។ លោកសំណាងបានជួបសេចក្តីសុខចន្ទិមមួន ។ តាំងពីថ្ងៃចេញលង់ថ្នាំ, រហូត

មកដល់មានៈកត្តិឈ្មោះជាគេទៀរសេស រឹងរឹតតែមានសេចក្តីសុខដ៏ធំ
ខ្លួលាយថែមទៀត, តួទ្រេអស្ចារ្យនឹងបុណ្យលោកដ៏ក្រៃលែង ។

ក្រៀងដែលដំណាលមកនេះ បំភ្លឺបានចាំងពីផ្លូវ តែចាំងផ្លូវលោក
ទំនងផ្លូវធម៌ ដូចមានសេចក្តីបន្ថែមជាពាក្យកាព្យតទៅនេះខ្ញុំ

បុណ្យកុំឲ្យតំណាប់ពីព្រៃនាយ តែងឲ្យតណ្ហាយនាលោកិយ
ដល់ជនជាប្រុសឬជាស្រី ដែលចំឃ្លាតខ្លីតសាងខុស ។
យើញាទេលោតសំណាងមានកត្តិ លឺឈ្មោះមានខ្លួនគេចប់មុខ
ផ្ទុំថ្នាំសក្តិសិទ្ធិតមានធុក នេះតែសាងសុខខុកពីមុន ។
មួយទៀតរឿងនេះសេចឲ្យឃល់ ថាកុំឲ្យលៃព្រោះគ្នានខុន
ប្រឹងនៃធ្វើការកុំស្តុកស្តុន សុខសាន្តខ្លួនឯងតែងតែមាន ។
ហេតុនេះអស់សាធុជនតែង បើក្តីត្រូតែបហើយត្រូវរៃធ្យាន
ប្រឹងប្រែបង្ហាញឲ្យកើតបាន ដូចគេចំណាននេះអ្នកតែយ ។

ចប់រឿងព្រៃន គេចសំណាង

អំពីកឋិនទាន

របស់សិស្សសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

ដំណើរកឋិនទានរបស់ពួកលោកមហាជាសិស្សនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញចាប់ផ្តើមធ្វើឡើងវិញ កាលនៅថ្ងៃ ៨ កើត ខែកត្តិក ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ វស្សា គឺថ្ងៃ ២០ ខែវិច្ឆិកា ឆ្នាំ ១៩៤៧ បានបៀតបៀនដល់ព្រះសង្ឃគង់ចាំវស្សា នៅវត្តសុវណ្ណបុម្ម ចម្ប៉ក់មាស ឃុំចម្ប៉ក់មាស ស្រុកមុខកំពូល ខេត្តកណ្តាល ។

កឋិនទាននេះ ជាទានមួយដ៏ថ្លៃថ្លាបំផុត ១ ក្នុងចំណោមអធិកអធមក្នុងព្រះពុទ្ធសាសនា ដែលមានជាប្រពៃណីតាំងមកហើយ ចាក់ឫសតស់កប់នៅក្នុងដួងវិញ្ញាណរបស់ពួកពុទ្ធបរិស័ទ អ្នកគាំពារព្រះពុទ្ធសាសនាទាំងអស់គ្នា ក្លាយទៅជាបុណ្យមួយសម្រាប់ថ្កែថ្កៃណែរបស់ខេមរជាតិ តែងធ្វើរៀងរាល់ឆ្នាំពុំដែលដាច់សោះឡើយ ។

ក្នុងរដូវសាលទានម្តង ៗ ដល់មកនៅថ្ងៃ ១ កេចខែអស្សុជនេះជាដើម ជាវេលាដែលព្រះអាទិត្យមានអរុណាទ័យរះឡើងមកពីទិសខាងកើត បញ្ចេញដួងរស្មីភ្លឺត្រចះថ្លា ចំពោះភ័ព្វវាសនានៃព្រះពុទ្ធសាសនាក្នុងតម្ពជរដ្ឋនេះ ជាប្រថមឫក្ស នាំឲ្យពួកភិក្ខុសាមណេរជាសិស្សសាលាបាលីជាន់ខ្ពស់នឹករលឹកដល់កឋិនទានជាប្រពៃណីរបស់ព្រះពុទ្ធសាសនាដែលធ្លាប់ធ្វើតមកនៅមន្ទីរសាលាបាលីជាន់ខ្ពស់ ទើបកែតនឹងអាក់ខានពុំ

ប្រាន់ធ្លើមកជាង ๘ ឆ្នាំហើយ, ដល់មកកាលឥឡូវនេះ អត់ត្រាំពុំបាន ដោយមានសេចក្តីជ្រះថ្លាកើតឡើងជាខ្លាំងពន់ពេក ពាំងបានឃើញ អាការៈរបស់ពួកពុទ្ធបរិស័ទសំដែងទឹកមុខស្រស់ប្រឹមប្រិយ សុទ្ធតែកាន់ត្រឿងបរិក្ខារគ្រប់ដៃ ហៅអង្គកឋិនទានដោយយានពាហនៈ បេញ្ចាតេហដ្ឋានផ្សេងៗ ទៅរោចំពោះព្រះសង្ឃក្នុងទីអាវាសមួយៗ ស្ទើរតែកាលថ្ងៃ សូម្បីជនណាៗ ក៏តែងតែជ្រះថ្លាចំពោះកឋិនទាននេះដែរ ។

តាមគម្ពីរព្រះពុទ្ធសាសនា សំដែងថាកឋិនទាននេះ មានផលានិសង្សធ្ងន់ឆ្ងល់ប្រសើរថ្លៃថ្លាណាស់ តែកាលជាន់ពុទ្ធសម័យគេពុំសូវធ្វើឲ្យអឺកងឺកគគ្រឹកគគ្រែងដូចជាសម័យបច្ចុប្បន្នយើងនេះទេ គេគ្រាន់តែយកតែចីវរណាមួយទៅរោចំពោះព្រះសង្ឃក្នុងទីអាវាសប៉ុណ្ណោះ ក៏ជាការស្រេច; ឥឡូវនេះ ពួកពុទ្ធបរិស័ទ ពង្រីតបុណ្យនេះឲ្យជាតំណសមសក្តិតាមថ្នាក់ព្រះពុទ្ធសាសនា ទឹងពុទ្ធសាសនិកជនឡើងជាលំដាប់ ទុកជាគោលបុណ្យមួយដ៏ប្រសើរថ្លៃថ្លាសម្រាប់ប្រទេសជាតិរបស់យើងខ្មែរៈ ។

ដោយហេតុនេះ កិច្ច-សាមណេរក្រុមសិស្សសាលាបាលីជាន់ខ្ពស់ មិនភ្លេចចោលច្បាប់ចាស់ប្រពៃណីរបស់បុព្វបុរសយើងទេ ចាំទុកហើយដាក់ជាប់នៅកន្លែងដ៏ដួងចិត្តគ្រប់ ។ គ្នាថា: បុណ្យកឋិនេះ ជាមតិកខ្មែរជាតិពីព្រេងនាយមក តាមទំនៀមទំលាប់ដែលព្រះពុទ្ធសាសនាបិតនៅ

ត្រឹមណា នាមឈ្មោះកិត្តិយសរបស់ពុទ្ធសាសនានឹងទេមរជនក៏បិតនៅ
ត្រឹមនោះ សិស្សទាំងនេះសូមប្រកាសខ្លួនចេញមុខថាជាអ្នកគោរពរក្សា
ពុកក្បើមតិកនៃបុត្តបុរសទេមរជាតិនេះតទៅអនាគតជាជាងពុំខ្លះ ។

ថ្វីបើស្រុកខេសកំពុងទីទ័លក្រ ខ្វះភាគជោយវត្តុគ្រប់យ៉ាង ពុំសូវ
សម្បូណិសប្បាយដូចកាលជួបជាំមុនៗមក ទោះបីជាយ៉ាងនេះក៏ដោយ
ក៏សិស្សទាំងនេះ ខំប្រឹងប្រមូលគំនិតគ្នាប្រឹងកសាងតបិនថានេះ ដែលជាពេល
ត្រូវធ្វើមិនឲ្យមាន ព្រោះយល់ឃើញថា មនុស្សយើងកំពុងរស់នៅត្រូវ
ខំប្រឹងធ្វើអ្វីមួយឲ្យខុសឲ្យល្អ ឲ្យគាល់តែសំរេចប្រយោជន៍ ខុសជាងំនៀម
តទៅ ទើបបានឈ្មោះថាជាអ្នកបែកសេចក្តីសុខ-ចំរើនឲ្យដល់មនុស្ស-
លោក តែថាសេចក្តីសុខ-ចំរើនដែលកើតឡើងបាន លុះណាតែអាស្រ័យ
"សាមគ្គីធម៌" សេចក្តីព្រមព្រៀងរួបរួមគំនិតគ្នា ជាឫកាន់ហានគោលចិត្ត
នៃមនុស្ស ទើបនាំឲ្យសំរេចប្រយោជន៍ធំនឹងសេចក្តីសុខ-ចំរើនទៅបាន
ព្រោះសាមគ្គីធម៌ មានអំណាចវិជ្ជានុភាពអាចធ្វើមនុស្សឲ្យមានដំហរវែងប៉ុន
កន្លែងដែលធ្វើការអ្វីមួយមិនឲ្យរលំរលោយអន្តរាយទៅបានឡើយ ដូច
ជាសត្វកណ្តៀរអស្រ័យសាមគ្គីធម៌ នាំគ្នាកសាងដំបូកពុកជ្រកកោនជា
ទីលំនៅរបស់វាការពារសេចក្តីអន្តរាយបាន; ទេមរជាតិយើង ឥឡូវបើ
មានសាមគ្គីធម៌ជាប្រមុខហើយ ធ្វើអ្វីក៏កើតបានទាំងអស់ ទីនំរលោយ

សេចក្តីអាត្រកំដែលប្រកាន់ខុសជាសឹកសត្រូវធំដល់សាមគ្គីធម៌នោះ ឲ្យ
សាបសូន្យទៅវិញ ។

ឥឡូវនេះ កឋិនទាននេះ កើតឡើងដោយអំណាចសាមគ្គីធម៌របស់
សិស្សនៃសាលាចុលីជាន់ខ្ពស់ហើយ មិនមែនកើតដោយលាក់មុខទេ គឺ
កើតដោយការព្រមព្រៀងរួបរួមគំនិតគ្នា ប្រារព្ធធ្វើឲ្យកើតឡើង នៅថ្ងៃ
៨ កើតខែកត្តិកនេះ ។ មុនខ្ញំនាំកឋិនទានទៅវេរប្រគេនព្រះសង្ឃគង់
នៅវត្តសុវណ្ណចុមចម្លាក់មាសនោះ ក្រុមសិស្សនៃសាលាចុលីជាន់ខ្ពស់
បានរៀបចំគ្រឿងបរិក្ខារមានត្រៃចីវរជាដើមដាក់ពុកលើតុ ១ យ៉ាងធំ; ធ្វើ
ជាពិធីសូត្រមន្ត ទេសនា ក្នុងវេលាយប់ថ្ងៃ ៧ កើតខែកត្តិក នៅមន្ទីរ
ភេនថែរនៃសាលាចុលីជាន់ខ្ពស់ ដែលមានក្តៅអគ្គិសនីបំភ្លឺត្រចំខ្នងគាត់
តាក់តែងដោយគ្រឿងលំអ ដោយស្មឹកខ្សែនឹងមែកដែលជង់ផ្កាបូរស្រោច
ដើងសសរ ខ្ញំដើងផ្កាដាក់លើរៀបជារបៀបសក្ការបូជាព្រះតេជគុណ
ដែលជាស្នាដៃពួកសិស្ស ខ្ញំលោក (សរ - សៀង) ជាស្មៀនសា-
លាចុលីជាន់ខ្ពស់ខ្ញំលោក សក្តជានុសិទ្ធិ (ហង់ - ឌឿ) ត្រូវជំនួយ
នៃសាលាចុលីជាន់ខ្ពស់ ជួយចំណុតបំរុងចាត់ចែងក្នុងកិច្ចការពួកអ្នកខ្ញំនោះ
ផង ។

លុះវេលាម៉ោង ១៩ នឹង ៣០ នាទី ជួបជុំគ្នាលោក-អ្នកសប្បុរស
ខ្ញំលោកជាភាហានក្រុមការប្រទេស ក្រុមសប្បុរសដទៃ ជាន

ទាំងត្រឿងក្នុងមកលេងកំដរបុណ្យកបិទនេះ ដោយសេចក្តីជ្រះថ្លា ចាប់ផ្តើមលេងកំសាន្តពីពេលព្រលប់ដល់ម៉ោង ៦ ០ នឹង ៣ ០ នាទីឈប់ផ្អាក ទើបភ្ជួរសិស្សនឹងឧបាសក - ឧបាសិកា នាំគ្នាឧទ្ទិសកុសលផលបុណ្យតាមលំដាប់សង្ឃដោយឡែក ឧបាសក - ឧបាសិកាដោយឡែក រួចហើយ និមន្តព្រះសង្ឃ ២ ០ រូបចប់រោងព្រះបរិត្ត និមន្តព្រះតេជព្រះគុណព្រះពុទ្ធវង្ស (សោម - ឈុន) សំដែងព្រះសទ្ធម្មទេសនា; មុននឹងសំដែងព្រះសទ្ធម្មទេសនានោះ ព្រះតេជព្រះគុណព្រះពោធិវង្ស ចាត់ហ្វាងសាលាថ្វាយជាន់ខ្ពស់ លោកក៏បានធ្វើជាវាកថាសន្ទនាដោយមធុរកថាដ៏សុភាពទន់ភ្លន់ បន្ទាប់មកលោកគ្រូកុមហា ជា - ខន់ សិស្សថ្នាក់ធំទី ៤ ក្រោកឈរឡើងសូត្រសុន្ទរកថាពិស្តារថ្វាយនូវសេចក្តីពណ៌នាអំពីកបិនទានដែលលោកជាក្រុមសិស្សសាលាថ្វាយជាន់ខ្ពស់ចាំងឆ ថ្នាក់ បានព្រមព្រៀងរួបរួមគំនិតគ្នាធ្វើកើតឡើងនេះ ដើម្បីបន្តពូជកុំឲ្យបាត់កេរ្តិ៍ដំណែលសិស្សចាស់ដែលបានធ្វើមកហើយ ខុតឲ្យតវង្សទៅខាងមុខតទៅ ឲ្យសិស្សខាងក្រោយយកតជាគំរាប់តាមធ្វើតាមតទៅអនាគត នៃដែលផ្តើមធ្វើឲ្យកើតជាឋ្ងកន្ទឹងនេះ ដោយសេចក្តីកំសត់ទេសន៍យើង មិនបានជាវុឌ្ឍរឿងធំដុំប៉ុន្មានទេ ធ្វើឲ្យតែតើតឡើងជាដំបូងប៉ុណ្ណោះសិនចុះ តទៅខាងមុខបានធ្វើឲ្យថ្កុំថ្កាជាងនេះបន្តិចឡើងខ្លះ ។ល។ រួចហើយ ព្រះតេជព្រះគុណព្រះពុទ្ធវង្សទេសនាសារ៉ាស័ព្ទពីរឿងកបិនទាន ដែលព្រះសម្ពុទ្ធជាម្ចាស់ត្រៃ

លោកខ្ញុំបានគ្រាស់ប្តូលក្នុងរវាងមជ្ឈិមពោធិសាលហើយ ទើបខ្ញុំអ.
ខ្ញុំញាតឲ្យមានកើតឡើងក្នុងសាលនោះរហូតដល់ចប់រឿងនេះដោយសេចក្តី
សង្ខេប ។ លោង "ចាថា" ចប់, ឧបាសក ឧបាសិកាសូត្រ "យំកិញ្ចិ..."
ចប់រួចពិធីសូត្រមន្ត ទេសនាហើយ ទើបត្រមតាហានក្បាច្រៃទេសចាប់
ផ្តើមលេងក្មេងម្ខាងទៀត តាក់តែងស្មូតសម្ងាត់រួចកន្ត្រកាយដោយត្រឹង
អាតណោះ ក្បាយទៅដាក្រេទ្រីសប្រុស ដើរអរគ់រៀងគ្នាជាគូ ជាជួរ
ចាក់ក្បាច់ស្រែតច្រៀង រៀបចប់អំពីដំណើរខ្លួនដាតាហានជួយយកអាសា
ទឹកដី ចប់, ច្រៀងសំណោះសំណាលតារជ្រាថ្នាតាមជាលោកិយរបស់
ប្តូរស្ត្រីកន្ត្រកលោកនេះ ចប់, មានរាបរៀបរៀបរយល្អមើល ឯក្មេង
ខ្លៀកដួយលេងចខ្លះកំដរតង់ពិធីបុណ្យនេះដែរ ហូតដល់ម៉ោង ៦ ព្រឹ
សិចប្តូនាទី ទើបលែងលេង ។ អស់លោក-អ្នកសប្បុរសក៏លែងត្រឡប់
ទៅគេហដ្ឋានរបស់ខ្លួនវិញ ។ ចំណែកពួកអនុសិស្ស ក៏ទាំងគ្នារុះរើតុតាំង
ព្រះពុទ្ធរូប គ្រឿងសក្ការបូជា មួរគន្ធលាសារៀបចំនាំយកអង្គកឋិនទាន
ត្រមាំងបរិក្ខារទៅដំកល់ទុកនៅវត្តឧណ្ណាលោម, ព្រឹកឡើងថ្ងៃ ៨ កើត
ខែកត្តិកមាំង ៩ ជួបជុំអនុសិស្ស ឧបាសក . ឧបាសិកា កំពង់ផែវត្ត
ឧណ្ណាលោម រៀបចំដំណើរបុះកប៉ាល់ ១ យ៉ាងធំថ្នូស្អាតជាងគេ
ទៅកែប្តូអ្នកមានសទ្ធាជ្រះថ្លាធ្វើបុណ្យ ដឹកនាំដង្ហែ
កឋិនទាននេះដោយឥតយឺតថ្ងៃ ។

ពេលនោះ ព្រះតេជព្រះគុណ ព្រះពោធិវង្ស លោកក៏ទំមន្តទៅ
ជួយមើលការរៀបចំដំណើរចុះកប៉ាល់នោះដែរ រួចហើយ កប៉ាល់ស្រាយ
ក្បូរដាកក្បាលវេចភ្លោះទៅតងណ្តាលទន្លេ ឈរមុខបែរភ្លោះទៅបុង
កោះផ្សារយួនវិញ ឯតាឡាល់ចត់ចោកមកតាមទីសមាធិដ៏ប៉ះត្រូវខេត់ដ៏ឃ
ខ្ពង់ស្ទឹកទន្លៃដែលចង់ហៅតាមសង្ឃាធិកប៉ាល់ចត់រៀប ។ តួតាហានត្រួម
ក្បាស្រុកលេងភ្លេងភ្លាយស្គរឮសូរខ្ទរកណ្តាលទន្លេ កប៉ាល់តាប់ស្ទាប
បក្រៀក្រៀនលៀនស្ទៅសំរៅបុងកោះផ្សារយួនវិញ ។ ព្រះសង្ឃទំង
ខ្មាសក-ខ្មាសិកាហោកដូចជាអណ្តែតត្រៃសត្វខ្លួនទៅលើអាកាស ក្រ-
ខ្សែកមើលទៅមខ្មុស្សម្នាក់នេសាទត្រីមើរដេរជាសកណ្តាលទន្លេ បែរមុខ
មើលមកកប៉ាល់ទាំងដៃកាន់មង - អួន - ថ្នង ហាក់ដូចជាប៉ុនប៉ងត្រាប្តូ
បង់ចាន់សេចក្តីសប្បាយរីករាយ ដោយកុសលផលបុណ្យនេះទំងនេះដែរ;
កប៉ាល់ចើតក្រៀនលៀនជល់កោះទេតញ៉ាតី ចត់បែរបួលតាមខ្នងទន្លេទាង
ខ្នងដែរ ក្រុមតាហានក្បាច្រៃសេលេងភ្លេងភ្លាយស្គរឮសូរសន្ធឹកគគ្រឹង
គគ្រែង មនុស្សច្រៃសស្រីចាស់ក្មេងតែលែមករឈរចាំមើលដោយសេចក្តី
រីករាយគ្រប់គែកូមដែលនៅតាមត្រើយមាត់ទន្លេទាំងសងខាង សូមម្បីតែ
ប៉ន - ឃ្លួនក៏ម្ល៉ះដើងខោលាត់ករន្ទើញ ដៃយួរកញ្ចេះឈរបែរមុខមើលមក
ពីត្រើយនោះៗដែរ នេះជាសេចក្តីអស្ចារ្យ អំណាច បុណ្យកមិនមានគួរ
ឲ្យមានសេចក្តីសោមនស្សដ្រែះថ្ងា គ្មានពាក្យចិត្តសាស្ត្រណា ជាតិណា

ស្តុទ្ធសីនតែជ្រាជ្ញាគ្រប់ប្របូប គួរឲ្យស្ងើចតេជានុភាពពុទ្ធសាសនានៃ
ព្រះសាក្យមុនីចរមគ្រូជាម្ចាស់នៃយើងនេះណាស់ ។

នៅព្រមាណជាង ១ គីឡូម៉ែត្រទៀត ខ្ញុំឯងដល់វត្តសុវណ្ណបទុម
បម្ពក់មាស កប៉ាល់បើកសន្ធឹមៗ កូនសេនតគ្រឹម ស្រាប់តែឃើញ
ទូកបែរប្រណាំង ៣ បែរដែរម្ខាងគ្នាខ្លីតមកតាមក្រោយចូលមកដល់ស្រែក
ហោចទួលបដិសណ្ឋារៈ ប្រទក្សិណកប៉ាល់ដោយសេចក្តីរីករាយ ចែជូន
ដំណើរដល់ទៅផែមុខកំពង់វត្ត ដែលលោកគ្រូចៅអធិការខ្ញុំឯងកិត្តិ - សាម-
ណេរ - ចុះសិក្ខាឈរធ្វើចាំទទួលបដិសណ្ឋារៈ នៅទីនោះពេល
ម៉ោង ១០ គត់ ។

យើងបានរៀបចំក្បួនហែកឋិនទាន ដោយពាក្យប៉ាល់ឡើងទៅកាន់ទី
វត្តសុវណ្ណបទុមបម្ពក់មាសនោះ ដោយការចាត់ចែងជាក់ក្តែងក្រមការហាន
ក្បួនស្រុតពីខាងមុខ ឲ្យលោកអាចារ្យនាម នុត ជាអាចារ្យសម្រាប់
វត្តនុណ្ណាលោមជាអ្នកបរិត្តជុំឯកូស ពីខាងលើដើរពីខាងមុខនៃសិស្ស
សាលាបាលី, ខាងក្រោយចំផុតចុះសិក្ខាកាន់ក្រឿងបរិក្ខារ
គ្រប់ដៃ ចុះចតនាវាតប៉ាល់ ហែកឋិនទានទៅដំកល់នៅមន្ទីរសាលា
បាលីវត្ត ដែលលោកគ្រូចៅអធិការរៀបចំទទួលទុកឲ្យ, លុះដំកល់
កឋិនទានទុកជាក់ស្រេចហើយ លោកគ្រូចៅអធិការនាម ស៊ូ និមន្ត
ពួនសិស្សពាំនោះឲ្យចូលទៅសម្រាតកាយនៅកុដិចំពេះលោកដែល

មានត្រាស់ទន្ទេលខុសមុនខ្លួនស្រែច, ចំណែកឧបាសក-ឧបាសិកាក៏ឱបបួលទៅសម្រាកតាយទៅតន្លឹបាកំដែលគេប្រគំពាសសុទ្ធតែសំពត់ត្រមាត្សាញស្រុកអាយ ខ្លះក៏បួលទៅអង្គុយលើកៅអី ដើងខ្លា តាមសេចក្តីត្រៃគារវេចស់ខ្លួនទីនៃ។ លុះដល់ម៉ោង ១១ លោកគ្រូទៅអធិការ ពាយក-ពាយិកា និមន្តសិស្សពាំងនោះឲ្យឆាន់បង្ហាន់តន្លឹបាកំនោះ។ រួចហើយ ទើបរៀបអាហារជូនអស់លោក-អ្នកប្រុសស្រីក្រឹងក្តុំពេញ តាមសេចក្តីសប្បាយត្រប់ៗគ្នា ឆ្អែតស្កប់ស្កល់ហើយក៏សម្រាកសាយដល់ម៉ោង ១៣ ទើបនាំគ្នាហែកបិនទានប្រទក្សិណ ៣ ជុំវិហារ នាំយកតបិនទានទឹងត្រឿងបរិក្ខារបួលទៅដំតល់ចំពោះមុខគំនុសង្ឃ រួចហើយលើកតំបង់អញ្ជលីនមស្សការព្រះរត្នត្រ័យ ដោយសេចក្តីគោរព ។

ពេលនោះ លោកគិកុមហា ជា-ខន់ សិស្សថ្នាក់ឆ្នាំទី ៤ ត្រៃកាងខ្សើងឈរសូត្រសុន្ទរកថា សារស័ព្ទអំពីតបិនទានដែលហែបួលមកថតក្នុងវត្តសុវណ្ណចុមចម្ប៉ាក់មាសនេះ ដោយសេចក្តីអនុគ្រោះចំពោះព្រះសង្ឃដែលតំពុងកសាងសាលាចាលីរងនោះឲ្យបានរឿងសូត្រតាន់ពេលខ្សើង ។ល។ លុះសូត្រចប់ហើយ លោកមហា ហ៊ាន-ធេងអូ ជាឧបាសកវត្តនោះ ជាសិស្សសាលាចាលីជាន់ខ្ពស់ពីដើម បានថ្លែងសុន្ទរកថា តបមកវិញដោយសេចក្តីសុភាពគួរឲ្យរំពឹងគ្រែចង្អាថា : "ខ្ញុំព្រះករុណា ខ្ញុំព្រះបាទជាអ្នកដំណាងពួកពុទ្ធបរិស័ទវត្តសុវណ្ណចុមចម្ប៉ាក់

មាសនេះ ទានសេចក្តីត្រូតអរគុណសប្បុរសចំពោះព្រះករុណាត្រង់អង្គ ឧត្តមអស់លោក-អ្នកសប្បុរសភាំនឡាយ ដែលបានហែកបិទបូលមកថតត្តនេះអំណើតរៀងត្តនេះនឹងបានថ្កុំថ្កើងរុងរឿងដោយសារព្រះករុណាម្ចាស់ត្រង់អង្គ ឧត្តមអស់លោក-អ្នកជួយចំនុកបំរុង ៗ មួយទៀត សូមព្រះករុណាត្រង់អង្គ ឧត្តមអស់លោក-អ្នកសប្បុរសមេត្តាឧត្តមតិយោសចំពោះយើងខ្ញុំ ដែលបានរៀបចនូលទានឧយគោជនីយាហារ ពោះបើគោជនពាំងនេះតុំសូវមានឧជារសហើងណា ៗ ក៏សូមមេត្តាជល់យើងខ្ញុំ ដែលមានភាពជាមនុស្សកំសត់ខ្សោយ ស្រុកស្រែចម្ការ" ។ល។ ហើយលោកអាចារ្យ ខ្ញុំ ប្រកាសឲ្យពួកសប្បុរសទាំងអស់ជ្រាបសព្វ ចាំទទួលបាលីវេរកបិទទាន ជាតាមត្រមាគ្នាទាល់តែចប់ ត្រមទាំងប្រកាសអំពីចាត់ញ្ជាត្តសម្រាប់ជួយចំនុកបំរុងកសាងវិហារនិងសាលាបាលីនេះចំនួន ៤,០០០,០០ តាមសមត្ថភាពដល់ខេយ្យទាន ជាអាសោនបង្ហើយបុណ្យ ដើបទុកសក ទុកាសិកានិងពួកសិស្សសាលាបាលីជាន់ខ្ពស់ថ្វាយបង្គំលាលោកត្រូវនឹងធម្មតា ចំរើនពរលាភាយកភាយិតាចំណុះត្តនោះ ចុះសំដៅមកកាន់ចំលៃត្រឡប់មកក្រុងកំពង់ឆ្នាំវិញ ។

លោកត្រូវនឹងធម្មតា តិក្ខ ហាមណោ ឧត្តមអស់លោក-ទុកាសិកានិងសិស្សលោកក៏ជូនដំណើរចុះមកឈរត្រៀបត្រាហែតាមមាត់ទន្លេមុខវត្តបែរ

មុខមើលមកយើងពាំងអស់គ្នាឡើងដិះតប៉ាល់វិលត្រឡប់, រៀលោះដាក់
ពេលវេលាសៀលម៉ោង ១៥ កន្លះ គួរឲ្យយើងនឹកស្រណោះអាណោះអាល័យ
លោកគ្រូចាស់ជាអធិការ ទើរៈបាសកទាំងសងខាងដែលជួនដំណើរឡើងតប៉ាល់
មុខគួរឲ្យស្រឡូតរៀងទៅ ព្រោះតំពូនតែរំពងដោយសប្បាយដោយបានធ្វើ
បុញ្ញកុសលយកចិត្តទុកថ្មី ទើរវត្តនោះ ស្រាប់តែនឹកសង្វេញចាងចោល
ឆ្នាំកំពូនសោមនស្ស ហាក់ដូចជាមិនចាន់អស់ចិត្តជ្រះថ្លាសោះ; យើង
ពាំងអស់គ្នាក៏ស្រែកឮគ្នាជាបន្តុះ លឺតប៉ាល់ ចាស់តែតប៉ាល់ស្រាយ
តូចតាញសាម្រែតវែស្រកលា ព្រះសង្ឃទើរអ្នកស្រុក ៣ ជន ក្មេងលេង
តែមរោងព្រំតែងលើកប៉ាល់ៗ ចង់ក្បាលដែរៅកណ្តាលទន្លេ; យើង
ក្រឡេកមើលទៅពួកគ្មួចរំលង ដែលជួនដំណើរយើងនោះ ត្រឡប់
ពីមាត់ច្រាំងទន្លេឡើងចូលទៅក្នុងឆ្នេរញែ ហាក់ដូចជារសេះរសោះអស់
កម្លាំងទន់ដៃជើង; ពួកយើងអ្នកភ្នំពេញមិនឮយូរស្ងៀមស្ងាត់ឈប់
សប្បាយ គ្រាន់តែញឹកៗ ខឹកសង្ឃឹមតែបុណ្យដែលបានធ្វើរួចហើយ
នោះឯង លុះតប៉ាល់ចេកលឿនលឿនមកដិតនឹងតាក់កណ្តាលទន្លេបន្តុ-
ម្តុះ; លោកគាចារ្យខុត ទិមន្តសង្ឃាពាំងអស់ឲ្យសួរគ្រូធម៌ «ដល់ខ្លោ...»
ឆ្លើយថា ជួនកុសលចំនោះទៅយ៉ាងប៉ិច ទើរពួកអ្នកកម្មករទៅតប៉ាល់ពាំង
អស់ ផ្សាយឲ្យបានច្បាស់ដោយសេចក្តីសុខ. ចំរើន ព្រោះតែអ្នកមាន
សទ្ធាជ្រះថ្លាបានឲ្យតប៉ាល់នេះដឹកទាំងបិណ្ឌបាតទៅសង់យើង; ព្រះសង្ឃ

សូត្រធម៌ «ដយន្តោ...» ឮខ្លះរំពង់ក្នុងកប៉ាល់ចប់ ៣ ដងហើយ ទុកសក
មានលោកអាចារ្យ ខុត ជាដើមសូត្រធម៌ «យំ កិញ្ចិ...» ទុំដូសផល
ជូនទៅថៅកែ ប៊ូ រឹងមុតកម្មការចប់ហើយ ទើប កុមារាហានក្សត្រប្រទេស
លេងក្នុងគ្រឹតគ្រែងកណ្តាលទន្លេហូតមកដល់ផែកប៉ាល់; អស់ពួក
បិនយួន - ខ្មែរនៅក្បែរខាងតំទន្លេ សុទ្ធតែងាកមុខបែរមើលមកគ្រប់ៗ គ្នា
ដល់ផែកប៉ាល់ចតនឹងស៊ីប់ហើយ កុមារាហានក្សត្រប្រទេសលេងក្នុង
រៀបជូនដំណើរពួកសិស្សទាំង ១ចាសក - ១ចាសិកាជុំគំពីកប៉ាល់ឡើងទៅ
ឆាន់មីលំនៅបស់ខ្លួន ពាល់តែអម្បាលើយល្ងាចលង ។ គួរអស្ចារ្យ
ពេកណាស់ ខានមនុស្សប្រុសស្រីចាស់ក្មេងចាមភាមមើលគ្រប់គ្រា
តាមមាត់ទន្លេកុំពាក្យ ក្នុងពេលថ្ងៃលេងឡើងទៅឆាន់មីលំនៅរៀង
ខ្លួនខ្លះទៀត ឃើងលាគ្នាថាសូមឲ្យបានប្រកបដោយសេចក្តីសុខ - ចំរើន
គ្រប់ៗ គ្នាហ្ន៎! សាធុ សាធុ!

ព្រះគ្រូបញ្ញាលិទ្ធ (កៅ-សឹម)

អាចារ្យសាលាបាលីវត្តខ្ពស់ ជាអ្នកវាណិនាតាមហេតុនៃកបិនទាន

សុភាសិតខ្លះ នារសោភន

លោកមហា "ស្រៀវ-លីវ"

វត្តសោយ ឃុំមៀនស្រែកកោះសូទិន ខេត្តកំពង់ចាម

(តទៅ)

បកេសហាសរួមរ្យ សមាគតាំ
កន្ធេយ្យ តេ វស្សសតំ អបញ្ញា
ឯតោវ សេយ្យោ បុរិសោ សបញ្ញោ
យោ ភាសិតស្ស វិជានាតិ អត្ថំ ។

ជនអប្រាជ្ញាខ្លាំងហ្មឺនពាន់ព្រឹន ប្រដុំគ្រើនគិតដោះប្រស្នា
អស់សតវត្សតក្នុងដំណើរ ខ្លឹកខ្លួលសោតការផ្សាស្តៅប្រមាំ ។
រីជនតែម្នាក់បញ្ញាណបញ្ញា សាបគិតបញ្ញាវាយអាថ៌នោះខ្លាត់ ដំណឹង
ពាក្យសួរសៀតអាចត្រៀតធ្វើយភាត់ ប្រសើរលើសក្តាត់បវិស័ទ្យពាល ។

អច្ចុក្កតា អតិពលតា អតិវេលំ បភាសិតា
វាចា ហោតិ ទុដ្ឋេន តិត្តរំវាតិវស្សិតំ ។

វាចាសាំដែលខ្ពស់ហួសលុបក្រៃណា ខាំឲ្យរំខានកណ្តាអ្នកស្តាប់
ចេះតែរុំវ៉ាន់ហួសពេលហួសស័ក្តិ រមែងសម្អប់ផ្តន់ពាលាសក្តិ ។ ដូច
ដាវគាំលើដំបូក រងរ៉ូកៗដោយក្តីស្មោះស្មេរ ត្រែវដែលព្រាន់ព្រៃខាត់
ជាន់វាយមរណ៍ ព្រោះតែចំហាត់តែបរបា ។

๒๑- ពាលសក្ខរតែងមរណ៍ទីឆ៍ពាថា ដែលអង្គអាត្មាថាខ្ពស់ហុបជ្រុណ
ពោលសាំដែលៗឲ្យតែរំខាន ដេះតែថ្លែងភាទក្លេសកាលហួសបទ កំពុង
ជួបជាទាទំលើដំរូក រងារថ្លុកៗក្រែងហួសកំណាត់ ត្រូវដៃព្រានដៃ
កំណាត់ ពាក់ជាន់សង្កិត់តកាត់ដីពី ។

សុភាសិត

មានំសម្ងាប់ជង្គ្រាមជ្ញាជាតិ ខ្ញុំរាតិយាជញ្ញកវ៉ែកចក្ស សំដីតិយាជជន
ពាលមោហា ខេះថាវាចាបុកណស្រែដី ។ ពាលពោលមួយពាក្យខូច
ខ្ញែរសម្បត្តិ បើពោលរាប់ខន"តំណាញ្ញាតិនាគ្នា ជ្រាបផ្ទះពោលមួយ
ពាក្យតែតស្រែសក្តា ពោលច្រែងវាចាតែលាតលើសលន់ ។

វគ្គទី ១

បណ្ឌិតប្បរេទ

បណ្ឌិតជាតិមារយោធថ្លៃវៃជ្រុះ បណ្ឌិតឥតប្រើអំណាចអាជ្ញា
បណ្ឌិតពោះពុទ្ធឥតឥតប្រែធា បណ្ឌិតពោះទីលម្អាពុំថ្លែងខុក្ខ ។ បណ្ឌិត
ឃុតជមិល្ហជាទែយ៍ បណ្ឌិតពោលសំដីសច្ចជាមុខ ។ បណ្ឌិតតែងក្សន
ជាមតិកខុក បណ្ឌិតមានសុទ្ធជាអានិសង្ស ។ បណ្ឌិតមិនលះធម៌ល្អ
ឧល្យាណ បណ្ឌិតមិនបាទធ្លើច្បាបភាមង៌ បណ្ឌិតមិនឆ្លើង អីដំដឹងអ្នក
អង្គ បណ្ឌិតឥតអលះបង់គុណថ្លៃថ្លា ។ បណ្ឌិតមិនស្តាប់ឆ្កែតព្រះសទ្ធម្ម
បណ្ឌិតគេពុំសួរសួទ្យបញ្ហា បណ្ឌិតឥតឲ្យអង្គអំប្យសក្ខា បណ្ឌិតព្យា-

ឃាមសៈកដ៏មសា ។ បណ្ឌិតមិនដៅរទោចដៅយលោភធម៌ បណ្ឌិតដឹត
លំអក់តណាភាព បណ្ឌិតមិនស្ងើលរំរើយ បណ្ឌិតដឹតអោត្តបន្ទីត្យវ ។
បណ្ឌិតឃើញទោសក្នុងដួចជាភ្នំ បណ្ឌិតឃើញទោសឆ្ពោះចំដៀសទៅ
បណ្ឌិតមិនខាំជាតិខ្យាស្រែវ បណ្ឌិតមិនសូរតើតនៅសព្វសព្វន ។
បណ្ឌិតមិនវុកក្នុងជនណា ។ បណ្ឌិតសាន៏សីលជាថ្កល់ស្ថាន បណ្ឌិត
ស្ងែងធម៌ជ្រះថ្លាដូចគ្នា បណ្ឌិតជាឃានហោន៏ក្លាតិឃ្លាតភ័យ ។ បណ្ឌិត
សេពអាហារប្រព្រឹត្តដូច បណ្ឌិតត្រែតតានធីនតាំងចៃ បណ្ឌិតមាន
ចិត្តអំណាត់ខន្តី បណ្ឌិតថ្កុំថ្កើសម្បុលសុខ ។ បណ្ឌិតដឹតធ្វើឥន្ទ្រិយ
អសារ បណ្ឌិតដឹតប្រហារជនជាតិស្មុក បណ្ឌិតដឹតនាំជនឲ្យសោយ
ទុក្ខ បណ្ឌិតដឹតសុខកន៏អាយ័ត ។ បណ្ឌិតពេញចិត្តរួមបណ្ឌិតជាតិ
បណ្ឌិតដឹតប្រទាបជនខវៃស ។ បណ្ឌិតតាំងចិត្តសុបុដ្ឋចិត្ត បណ្ឌិតមិន
កាត់ប្រយោជន៏បី ។ បណ្ឌិតស្ងែងវិជ្ជាដឹតតិតមរណ៏ បណ្ឌិតស្ងែងធម៌
ដឹតតិតជ្ញក្ស័យ បណ្ឌិតដឹតអប្បយសព្រោះដៃស្រែ បណ្ឌិតតិតដៃលៃ
លកមុនធ្វើ ។ បណ្ឌិតប្រព្រឹត្តចិត្តកាយបរិសុទ្ធ បណ្ឌិតតមផុតការដឹត
អំពើ បណ្ឌិតច្ចេជ្ញាម្តេចស្រែចមិនរើ បណ្ឌិតធ្វើតែអំពើកគ្រា ។ បណ្ឌិត
មិនលុចច្រែះគុណាវង្សញាតិ បណ្ឌិតមិនពិឃាដសត្វនានា បណ្ឌិតមិន
លន៏តាមទុកវិយោ បណ្ឌិតតណិនាតែម្ត៏ង ពិត ។ បណ្ឌិតតាំងបញ្ជាប់
ត្រាប់តាំងខ្លួនឯង បណ្ឌិតខ្ចីមខ្ចាបត្រែងចុចខ្ចុចត បណ្ឌិតមិនចង់ដឿ

ឥតគំនិត បណ្ឌិតមិនស្ងើមិត្តចិត្តពុជ្ជ ។ បណ្ឌិតចំណូលបួលខាងកុសល បណ្ឌិតមិនសល់ចាញ់កលពាលា បណ្ឌិតយកក្បួនជាអាទាសា បណ្ឌិតថ្កាំថ្កែយោជន៍ខ្ជួរខ្ជៅ ។ បណ្ឌិតកំម្រៃព្រៃកុំកែថ្ម បណ្ឌិតជាលំអនៃលោងជាគុរូ បណ្ឌិតជាម្រែទឹបគ្រែលថ្កាប់ផ្លូវ បណ្ឌិតប្រជៀនីវរណសុខ ។ បណ្ឌិតតតែប្រយោជន៍ជាធំជាក់ បណ្ឌិតតតែរង្គាជាប្រមុខ បណ្ឌិតតតែប្រយោជន៍ពុកឲ្យស្រុត បណ្ឌិតខេសន៍ជមិពុតឲ្យជាពាន ។ បណ្ឌិតចិត្តរាន់តុណាសក្ខុបក្ខ បណ្ឌិតខំតាំចិត្តដោយមគ្គឈាន បណ្ឌិតវិស្ទុទ្ធស្តែរកេចាន បណ្ឌិតពាំសេសគ្រាស់ញាណ ឆ្នាះមាហ៍ ។

វគ្គទី ២

មិត្តប្បវេទ

កុំសេពមិត្តបច្ចាចិត្តប្រពុស្ត កុំសេពមិត្តគោសរូសខ្ជូសឥច្ចា កុំសេពមិត្តល្អតែមាត់ជាចោ កុំសេពមិត្តចណ្ឌាំាលាញ្ញធន ។ កុំសេពមិត្តតតែប្រយោជន៍តែ កុំសេពមិត្តរវៃគ្នែរគុណាធ្ងន់ កុំសេពមិត្តកំណាញ់ស្វាញធន កុំសេពមិត្តលាក់ខន្ធសិល្បាសស្ពា ។ កុំសេពមិត្តនាំប្រព្រឹត្តបាបខ្ចៅ កុំសេពមិត្តនាំទៅអបាយា កុំសេពមិត្តលក់ជាតិវង្សសម្ងា កុំសេពមិត្តប្លាញយកធ្លីខ្ញុំ ។ កុំសេពមិត្តក្បាច្រៀកចោកប្រើប្លែស់ កុំសេពមិត្តផ្តាសប្រុងប្លួមរំលំ កុំសេពមិត្តចិត្តមិនស្ម័គ្រស្មោគម កុំសេពមិត្តពូតផ្តុំផ្សែងជាភ្លើង ។ កុំសេពមិត្តនិយាយ

ហែកកេរ្តិ៍មិត្ត កុំសេពមិត្តប្រែប្រួតគំនុំលោលលើកជើង កុំសេពមិត្តចង់
បានតែពីយើង កុំសេពមិត្តក្លែងដុតអំណៀងគ្នា ។ កុំសេពមិត្តស៊ីប្រៃបុច
ប្រវែង កុំសេពមិត្តថ្លៃធ្លេមធ្លែងទុច្ចរិត កុំសេពមិត្តដោះដែលបំណាលកំណាច
កិត កុំសេពមិត្តមិនគិតជួយខុសគ្នា ។ កុំសេពមិត្តឆ្នើនឆ្នៃកាលគេមាន
កុំសេពមិត្តពាប់អានកាលវេទនា កុំសេពមិត្តមិនជួយជុះគ្នា កុំសេព
មិត្តប៉ងយាយីតិយោជ ។ កុំសេពមិត្តប៉ងខ្ចីស្តុកវិយោ កុំសេពមិត្ត
ប៉ងញាប់ចង់ញ្ញាតិ កុំសេពមិត្តបិទគំនិតគ្រាតគ្រាង កុំសេពមិត្ត
ថយជាតិអប្បីសក្តា ។ កុំសេពមិត្តប្រែព្រឹត្តអង្គាយមុខ កុំសេពមិត្ត
ដាក់ការកៀនធីតស្រា កុំសេពមិត្តឆ្កួតស្រីចោរពេស្យា កុំសេពមិត្ត
មោហាពាលសាមាន្យ ។ កុំសេពមិត្តចរគ្មោមកញ្ជ្រុំ កុំសេពមិត្ត
ពំរូដើមជាន់ច្បាណ កុំសេពមិត្តមើលងាយញាតិសន្តាន កុំសេពមិត្ត
កុំជាន់ដើរធ្លើណាស់ កុំសេពមិត្តខ្ជួយលាយចរយហួសមាន កុំសេព
មិត្តឈានពានធ្លើផ្តេសផ្តាស កុំសេពមិត្តច្បាន់តែមាត់ហេសហាស
កុំសេពមិត្តឥតខ្មាសក្តីសន្តាន ។ កុំសេពមិត្តឆ្លៀសកិលវិលវេចគូថ
កុំសេពមិត្តកកេរគូតអួរឥតស្រាន្ត កុំសេពមិត្តគំនិតតិរច្ឆាន កុំសេព
មិត្តជាក់ច្បាន់ខ្ជាក់ជ្រោះ ។ (មាឧត)